00831352

E1/101.1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Aug-2012, 14:03
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី៨៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក វ៉េន ពៅ

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ទី ស្រ៊ីនណា

លោក ឡោ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ច័ន្ទ តារាវស្មី | ខ្មែរ |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក អេនឌ្រូ អ៊ីន្ទូហ្វ៊ី | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក រ៉ចាម តុន (TCW-564) | ខ្មែរ |
| លោក ស្លួង ស៊ីគឿន (TCW-694) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ម៉ែចាម តុន ហៅ តី តួន** (TCW-564)

សួរបន្តដោយលោក អាកទួរ វែកគែន ផ្ដើមពី៖ ..........ទំព័រ ២

**ការសួរសំណួរទៅសាក្សី៖ លោក សួង ស៊ីគឿន** (TCW-694)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖ ..........ទំព័រ ៤៧

សួរដោយលោក លោក ច័ន្ទ តារាវស្មី ផ្ដើមពី៖ ..........ទំព័រ ៥២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅព្រឹកនេះ កិច្ចពិភាក្សាដេញដោលដែលនឹងបន្តការតាំងសំណួរចំពោះសាក្សីដោយក្រុមមេធាវីអន្តរជាតិការពារក្តីឲ្យលោក ខៀវ សំផន។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវី សូមលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះ មានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួន ខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិ តាមរយៈមេធាវីរបស់គាត់ក្នុងការចូលរួមដំណើរការនីតិវិធី ដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់រយៈពេលពេញមួយថ្ងៃ នៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ដោយឡែកសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ពីសាក្សី រ៉ចាម តុន គឺ សាក្សីដែលមានរហស្សនាម TCW-694 មានវត្តមាននៅបន្ទប់រង់ចាំ។ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី ជាមុនសិន។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២ ខែសីហា ឆ្នាំ ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ សុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

[០៩:០៥:៥៣]

វេជ្ជបណ្ឌិត អួយ សំណាង គ្រូពេទ្យទទួលពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះ ហើយកត់សម្គាល់ឃើញថា លោក អៀង សារី អាការៈហត់ខ្លាំង និងវិលមុខនៅពេលធ្វើចលនា និងមិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា លោក អៀង សារី គួរតែត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់មួយខាងក្រោមសាលសវនាការនេះ។

អង្គជំនុំជម្រះយល់ឃើញថា ពេលនេះលោក អៀង សារី ដែលលះបង់សិទ្ធិចូលរួមសវនាការក្នុងកិច្ចដំណើរការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយមានបញ្ហាសុខភាព ដូចគ្រូពេទ្យបានពិនិត្យ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈឧបករណ៍សោតទស្សន៍ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ហើយគាត់អាចទំនាក់ទំនងជាមួយនឹងមេធាវីរបស់គាត់បានគ្រប់ពេលវេលា។

[០៩:០៦:៥១]

ហេតុដូច្នេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី សុំលះបង់សិទ្ធិចូលរួមនៅកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។ ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលនៃដំណើរការសវនាការពេញមួយថ្ងៃនេះ។

បាទ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាកទួរ វែកកែន៖**

បាទ សូមអរគុណលោកប្រធាន។

ជម្រាបសួរអស់លោក លោកស្រីចៅក្រម។ ជម្រាបសួរលោកសាក្សី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក អាកទួរ វែកកែន៖**

**ស៖** ខ្ញុំចង់ចោទសំណួរមួយទាក់ទងទៅនឹងមន្ទីរ ស-៧១ ហើយនិងសុំសួរលោកថា លោក ហ៊ូ

យន់ និង ហ៊ូ នឹម នោះមានវត្តមាននៅទីនោះដែរឬទេ?

**លោក វ៉ាចាម តុន៖**

**ឆ៖** លោក ហ៊ូ នឹម និងហ៊ូ យន់ គឺអត់នៅមន្ទីរ ស-៧១ ទេ។ គាត់នៅមន្ទីរផ្សេង។

**ស៖** មន្ទីរណាទៅ?

[០៩:០៨:៤៤]

**ឆ៖** មន្ទីរហ្នឹងគឺក្បែរមន្ទីរ ស-៧១ ដែរ ប៉ុន្តែគេអត់មានដាក់ឈ្មោះអីផង វានៅក្បែរហ្នឹងដែរ ប្រហែលជាបួនប្រាំរយម៉ែត្រពីគ្នាហ្នឹង។

**ស៖** តើលោកធ្លាប់បានជួបពួកគាត់ដែរឬទេ?

**ឆ៖** នៅកន្លែងនុ៎ងខ្ញុំអត់បានជួបទេ។

**ស៖** តើលោកបានឃើញគាត់នៅកន្លែងណាទៅ?

**ឆ៖** ខ្ញុំបានឃើញគាត់នៅកន្លែងជិតគ្នាហ្នឹង។ ខ្ញុំអត់បានឃើញទេ ប៉ុន្តែពួក្រុមពួកខ្ញុំហ្នឹងគេទទួលខុសត្រូវចំណែកខាងផ្នែកនុ៎ង គេដឹង។ គេនិយាយប្រាប់គ្នាអ៊ីចឹងទៅ។

[០៩:១០:២២]

**ស៖** សូមអរគុណ។ លោកបានពន្យល់ម្សិលមិញថា ដើម្បីការពារមន្ទីរហ្នឹង គឺថាលោកផ្លាស់វេនគ្នាដោយក្រុមមួយដែលមានមនុស្ស១០នាក់មួយក្រុម ហើយខ្ញុំសួរលោកថា តើចំនួនមនុស្សដែលចាត់តាំងឲ្យយាមពេលមានប្រជុំនៅក្នុងមន្ទីរហ្នឹង តើមានក្រុម មានចំនួនអ្នកយាមនោះប៉ុន្មាននាក់ដែរ?

**ឆ៖** ក្រុមដែលយាមហ្នឹងគឺថា យើងគិតទៅវាបួនទិសៗហ្នឹងគឺ មួយទិស គេហៅថាមួយទិសមួយពួក។ មួយពួកហ្នឹងបីនាក់។

**ស៖** ហើយវិធាននេះមាន -- គឺថាគេប្រើ -- គេអនុវត្តនៅមន្ទីរស-៧១ នៅស្តុកតោលហ្នឹងតែប៉ុណ្ណឹងទេ ឬក៏យ៉ាងម៉េច? ឬក៏មានគេអនុវត្តនៅកន្លែងផ្សេងៗទៀតដែរ?

[០៩:១២:០១]

**ឆ៖** មិញនេះ ខ្ញុំជម្រាបប្រាប់ថា អាហ្នឹងគឺចំពោះតែនៅមន្ទីរស-៧១ ទេ។

**ស៖** ហើយគេធ្វើអ៊ីចឹងដែរឬទេនៅក្នុងមន្ទីរដែលក្រោយពីមន្ទីរស-៧១ នោះ ឧទាហរណ៍ដូចជាមន្ទីរប-៥ ហើយនិងនៅស្តុកតោលជាដើមនោះ?

**ឆ៖** ប្រហែលៗគ្នាហ្នឹងហើយបាទ។

**សៈ** ទាក់ទងនឹងប-៥ លោកបានជម្រាបជូនថា លោកត្រូវបានបញ្ជូនទៅទីនុំងជាអចិន្ត្រៃយ៍នៅឆ្នាំ១៩៧៤ ឬក៏ដើមឆ្នាំ១៩៧៥។ តើលោកនៅពេលដែលលោកនិយាយថា អចិន្ត្រៃយ៍នោះមានន័យយ៉ាងម៉េច? ចង់និយាយថាលោកចាប់ពីពេលទៅដល់ប-៥ហ្នឹង លោកបានបញ្ឈប់ការងារជានីរសារ ឬក៏យ៉ាងម៉េច?

**ឆៈ** ចំណុចនេះគឺថាកាលយើងទៅនៅមន្ទីរប-៥ នេះ អចិន្ត្រៃយ៍នេះគេចង់និយាយថា គឺយើងៗរស់នៅគឺថានៅកន្លែងហ្នឹងជាអចិន្ត្រៃយ៍ អត់មានអ្នកហ្នឹងគឺ -- គឺថាខ្ញុំមានវត្តមានជាមួយនៅនុំងហ្នឹងគឺថា មួយក្រុមហ្នឹងគឺវានៅជាអចិន្ត្រៃយ៍ហ្នឹង គឺនៅៗៗក្នុងមន្ទីរហ្នឹង អ៊ីចឹង។

[០៩:១៤:១៩]

**សៈ** ដូច្នេះដើម្បីបញ្ចប់ សូមចម្លើយទៅនឹងសំណួរនោះ ថានៅពេលដែលនៅមន្ទីរប-៥ ហ្នឹង តើលោកនៅតែបន្តសកម្មភាពជានីរសារបន្ថែមលើការងារលោកជាកងការពារដែរឬទេ?

**ឆៈ** នៅកន្លែងហ្នឹងគឺថា នៅបន្តជានីរសារដែរ គឺថានាំសារពីគាត់ទៅសមរភូមិ ឬមួយនាំសារពីគាត់ទៅភូមិភាគនិរតី ឬមួយនាំសារទៅពីគាត់ទៅមកៗសមរភូមិក្រោយមកខាងមន្ទីរ៧៧៤ នោះ គឺមានអ៊ីចឹងដែរ។

**សៈ** តើលោកអាចជម្រាបជូនបានទេពីមូលហេតុដែលមន្ទីរ ប-៥ ដែលត្រូវបានគេបង្កើតឡើងនោះ តើមូលហេតុអីបានជាគេបង្កើតមន្ទីរក-៥ នេះ? អ៎! ប-៥ សូមទោស។

**ឆៈ** មូលហេតុដែលនាំឲ្យបង្កើតមន្ទីរប-៥នេះ គឺសម្រាប់បញ្ជាសមរភូមិវ៉ៃសម្រុកចូលភ្នំពេញហ្នឹងហើយបាទ។

**សៈ** នៅពេលដែល ប-៥ ត្រូវបានបង្កើតឡើងនោះ តើគោលដៅយោធាដែលជាប្រញាប់បន្ទាន់នោះគឺថាត្រូវដណ្តើមយកទីក្រុងភ្នំពេញ តើអ៊ីចឹងមែនទេ?

**ឆៈ** បាទ អ៊ីចឹងហើយបាទ។

**សៈ** បើតាមលោកចាំនោះ តើលោកអាចរំឭកអំពីកាលបរិច្ឆេទនៃការបង្កើតមន្ទីរប-៥ ដែរឬទេ?

[០៩:១៧:២០]

**ឆៈ** ថ្ងៃមុនខ្ញុំបានបញ្ជាក់គឺថា មុននឹងទៅបង្កើតមន្ទីរ ប-៥ហ្នឹង គឺនៅមន្ទីរគេហៅថា ច្រកស្តេចៗ។ ហើយអង្កាល់ហ្នឹងគឺ ក្នុងឆ្នាំ៩៣(ស៊ីក)។

**ស៖** បាទ ខ្ញុំសូមចោទសំណួរម្តងទៀត។ តើមន្ទីរ ប-៥ ត្រូវបង្កើតឡើងនៅពេលណា? កាលបរិច្ឆេទ ឬក៏ប្រព្រឹត្តការមួយដែលថាអាចឱ្យលោកកំណត់ពេលដែលមន្ទីរ ប-៥ នេះបង្កើតឡើង?

**ឆ៖** ក្នុងមន្ទីរ ប-៥ ដូចខ្ញុំបានបញ្ជាក់ហើយអំមិញថា ពេលខ្ញុំថាក្នុងឆ្នាំ៩៣(ស៊ីក)។ ក្នុងឆ្នាំ៩៣(ស៊ីក)អ៊ីចឹង។ កាលហ្នឹងដូចខ្ញុំចាំដូចជាក្នុង -- នេះគឺថា--

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** ចុងរដូវវស្សាទៅហើយ ចុងរដូវវស្សាវាអត់សូវមានទឹកភ្លៀងអង្កាល់នុ៎ង។ ដែលខ្ញុំចាំអ៊ីចឹង។

**ស៖** តើលោកអាចនិយាយឆ្នាំឡើងវិញបានដែរឬទេ?

**ឆ៖** ខ្ញុំអាចនិយាយបានឆ្នាំហ្នឹង គឺនៅក្នុងឆ្នាំ៧៣ ហ្នឹងហើយ។

[០៩:១៩:៥២]

**ស៖** លោកបានឆ្លើយនៅទំព័រ គឺថាទំព័រទី២០ ថ្ងៃទី២៦ កក្កដា ឆ្នាំ២ -- ម៉ោង១០:០៥នាទី លោកថា ប-៥ នេះគឺជាកន្លែងសម្រាប់ការពារយុទ្ធសាស្ត្រហើយនិងកន្លែងទីលានប្រយុទ្ធ -- ជាសមរភូមិ តើកាលនុ៎ងសមរភូមិអីគេ មន្ទីរ ប-៥នុ៎ង?

**ឆ៖** ត្រង់ហ្នឹងខ្ញុំបញ្ជាក់ថា គឺថាទីបញ្ជាសមរភូមិ -- ទីបញ្ជាការសមរភូមិដែលត្រូវរើសម្រុកចាប់ពី៧៣ ហ្នឹង ត្រូវរើសម្រុកគ្រប់មុខសញ្ញាសំដៅទៅទីក្រុងភ្នំពេញហ្នឹងបាទ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីហាក់ដូចជា ការដកស្រង់របស់លោកមិនត្រឹមត្រូវទេ តាមដែលយើងបានស្តាប់កន្លងមកមិនមានព័ត៌មានអីថា ស្តុកគោលហ្នឹង ឬក៏មន្ទីរ ប-៥ ហ្នឹងជាសមរភូមិប្រយុទ្ធគ្នាទេ។ លោកគប្បីដាក់បង្ហាញនូវសម្រង់នៃកំណត់ -- នៃប្រតិចារឹកដើម្បីឱ្យភាគីទាំងអង្គជំនុំជម្រះបានឃើញផង។ ចៀសវាងការដកស្រង់ខុស ហើយយកទៅសួរដល់គោលដៅដែលត្រូវសួរ មិនទំនងជាសមរម្យទេ -- សមស្របទេ។ លោកគប្បីរៀបចំនូវប្រតិចារឹកច្បាស់លាស់ទៅ!

[០៩:២២:០២]

**លោក អាកទួរ វែកកែន៖**

សូមទោសលោកប្រធាន។ ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែហើយ ធ្វើអ៊ីចឹងយើងអាចមិនយល់គ្នា។ អ៊ីចឹងហើយខ្ញុំមិនបាននិយាយថា ស្តុកគោលទេអម្បាញ់មិញនេះ អ៊ីចឹងជារឿងមួយភ័ន្តច្រឡំ

បាត់ហើយ ខ្ញុំនិយាយអំពីមន្ទីរ ប-៥ អម្បាញ់មិញ។ ខ្ញុំមិនដឹងថាគេបកប្រែទៅជាភាសាខ្មែរយ៉ាងម៉េចទេ ប៉ុន្តែសំណួរខ្ញុំគឺថា ទាក់ទងនឹង ប-៥នោះទេ។ នេះជាចំណុចទី១។

**ប្រធានអង្គជំនុំ៖**

ដូចគ្នា។ យើងយល់ថាគប្បីថា បញ្ជាក់ឲ្យបានច្បាស់លាស់។ ប-៥ ដែលយើងបានស្តាប់គ្រប់សក្ខីកម្មតាំងពីដើមរហូតមកមិនទាន់ពីព័ត៌មានណាថា ប-៥ជាសមរភូមិប្រយុទ្ធគ្នាទេ។ អ៊ីចឹងហើយបានយើងចង់បញ្ជាក់ឲ្យច្បាស់ កាលណាលោកដកស្រង់ត្រូវបង្ហាញឲ្យច្បាស់ ដើម្បីឲ្យមើលឃើញទាំងអស់គ្នា ថាចម្លើយហ្នឹង គឺបាននិយាយថា ប-៥ជាទីលានប្រយុទ្ធមែន។ ចៀសវាងយើងដកស្រង់មកវាអត់មានមូលដ្ឋាន។

[០៩:២៣:១៦]

**លោក អាកទ្ធរ វែកកែន៖**

បាទ ខ្ញុំសូមរៀបរាប់ពាក្យសម្តីរបស់សាក្សីឡើងវិញ។ ហើយខ្ញុំនិយាយម្តងទៀត -- ពាក្យថាមើលទៅឃើញថា មានការលំបាក -- គឺនៅទំព័រ២០ នៅក្នុងពង្រាងប្រតិចារឹកថ្ងៃទី២៦ កក្កដា គឺថា មុនម៉ោង១០:០៥នាទី សាក្សីបាននិយាយថា មន្ទីរ ប-៥ ជាកន្លែងជៀបទៅនឹងសមរភូមិ ហើយនិងទីលានប្រយុទ្ធ។ នេះ--

**ប្រធានអង្គជំនុំ៖**

លោកអាចដាក់បង្ហាញឯកសារជាភាសាខ្មែរ នៅលើអេក្រង់កុំព្យូទ័រមក!

**លោក អាកទ្ធរ វែកកែន៖**

បាទៗ គឺថាទំព័រទី១៨ ជាភាសាខ្មែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បង្ហាញ -- មន្ត្រីដែល -- បង្ហាញដូចភាគីដទៃទៀតដែលគេធ្វើអ៊ីចឹង។ កាលណាលោកចង់បង្ហាញឯកសារ លោកមានសិទ្ធិនៅក្នុងការស្នើសុំ ហើយយើងអនុញ្ញាតជានិច្ចក្នុងការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ។

[០៩:២៤:៤២]

**លោក អាកទ្ធរ វែកកែន៖**

បាទ គឺខាងខ្ញុំធ្វើហើយលោកប្រធាន។ ប្រហែលជា--

**ប្រធានអង្គជំនុំ៖**

លោកអាចសួរបានហើយ។ អាចៗតាំងសំណួរបានហើយ ហើយលោកមើលខ្លឹមសារឲ្យបានត្រឹមត្រូវ ព្រោះខ្លឹមអំមិញដែលលោកសួរ វាឆ្ងាយណាស់ វាខុសពីខ្លឹមសារនេះឆ្ងាយណាស់។ ទីលានប្រយុទ្ធ និងកន្លែងបញ្ជាការសមរភូមិមុខ ពាក្យហ្នឹងខុសគ្នាឆ្ងាយណាស់ បើលោកមិនច្បាស់លោកអាចពិភាក្សាជាមួយនឹងមេធាវីជាតិរបស់លោក ដើម្បីយល់អំពីពាក្យនេះ។

[០៩:២៥:៤១]

**លោក អាកទូរ វែកគែន៖**

បាទខ្ញុំអានប្រតិចារឹកអម្បាញ់មិញ ហើយប្រហែលជាមានការបកប្រែជាខ្សែចង្វាក់ហ្នឹងប្រហែលជាមានភាពខុសគ្នា។ ក៏ប៉ុន្តែអ្វីដែលខ្ញុំអានហ្នឹងគឺថា អានអ្វីលោកប្រធានកំពុងតែឃើញចំពោះមុខហ្នឹងឯង។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោកសាក្សី អ្វីដែលខ្ញុំសួរលោកនោះ គឺថាសូមឲ្យលោកប្រាប់ថា នៅពេលដែលប-៥ ត្រូវបានបង្កើតនោះ តើទិសដៅនៃ -- ទិសដៅចំពោះមុខនោះ គឺថាដណ្តើមយកទីក្រុងភ្នំពេញ ឬក៏យ៉ាងម៉េច? ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៣ នៅពេលដែលគេបង្កើតមន្ទីរប-៥ នោះ តើគោលដៅចំពោះមុខជាអ្វី?

**លោក វ៉ាចាម តុន៖**

**ឆ៖** ក្នុងឆ្នាំ៧៣ បង្កើតមន្ទីរប-៥ ហ្នឹងគឺថា ដើម្បីគឺថា ជាឈ្នាន់ ដើម្បីគឺថា ទៅរំដោះទីក្រុងភ្នំពេញហ្នឹង អាហ្នឹងពី៧៣, ៧៤, ៧៥ ចន្លោះហ្នឹង វាខ្លីណាស់ វាខ្លីគឺថាៗ យើងបង្កលក្ខណៈសម្បត្តិគឺថា ពី៧៣នោះហើយ ដើម្បី -- មកដល់៧៤ យើងរំដោះឧដុង្គ ដល់៧៥ យើងរំដោះភ្នំពេញទាំងស្រុង។ អ៊ីចឹងគឺថា គោលដៅដែលបង្កើតមន្ទីរហ្នឹងគឺថា ដែលខ្ញុំបញ្ជាក់ថាទីបញ្ជាការសមរភូមិរំដោះទីក្រុងភ្នំពេញហ្នឹងហើយអ៊ីចឹង។

[០៩:២៧:៤៤]

**ស៖** ហើយមុនពេលចូលទៅដល់ភ្នំពេញ តើមានក្រុងណាផ្សេងទៀតទេ ដែលត្រូវបានរំដោះមុនពេលវ៉ៃចូលទៅភ្នំពេញនោះ?

**ឆ៖** មុនចូលរំដោះភ្នំពេញហ្នឹង ទីតាំងការពារជុំវិញភ្នំពេញហ្នឹង គឺថាវាការពារក្រាស់ដែរ ដូចពីផ្លូវលេខ៥ ហ្នឹងគឺថា ពីឧដុង្គហើយ បានគេហៅថា កប់ស្រូវ ហើយភ្នំបាសិទ្ធហ្នឹង។ មួយជួរហ្នឹង ចន្លោះៗ

ផ្លូវលេខ៤ ហើយនិងផ្លូវលេខ៥ហ្នឹង គឺចន្លោះហ្នឹង។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចបញ្ជាក់អំមិញ ឥឡូវឯកសារដែលលោកបង្ហាញអំមិញនៅលើអេក្រង់កុំព្យូទ័រហ្នឹង សូមបញ្ជាក់អត្តសញ្ញាណឯកសារផង ព្រោះអត់មានប្រតិចារឹក។

**លោក អាកទួរ វែកគែន៖**

លោកប្រធានឯកសារនេះ មិនទាន់មានលេខទេ ព្រោះថាជាសេចក្តីព្រាងនៃប្រតិចារឹកប៉ុណ្ណោះ។ គឺជាឯកសារដែលបានផ្តល់ជូនយើង ជាលក្ខណៈបណ្តោះអាសន្នមុននឹងទទួលបាននូវឯកសារស្ថាពរនោះ។ ដូច្នេះឯកសារនេះ អត់ទាន់មានលេខទេ នេះជាសំណៅដែលមិនទាន់បានពិនិត្យមើលឡើងវិញនៃប្រតិចារឹក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២។

[០៩:២៩:៤១]

**ប្រធានអង្គជំនុំ៖**

បាទអញ្ជើញ ប៉ុណ្ណឹងក៏បានដែរណ៎ា។ ឲ្យច្បាស់លាស់ថា ប្រតិចារឹកចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១២ ម៉ោងគឺ 10:03:59។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកសាក្សី លោកបានឆ្លើយថា ប៉ុល ពត នៅប-៥ ជាញឹកញាប់ ក៏ប៉ុន្តែ ខៀវ សំផន មិនសូវទៅកន្លែងហ្នឹងញឹកញាប់ទេ គាត់នៅសមរភូមិក្រោយ។ ខ្ញុំចង់ដឹងច្បាស់ថា តើលោក ខៀវ សំផន ហ្នឹងគាត់នៅឯណាពិតប្រាកដ ដែលលោកនិយាយថានៅសមរភូមិក្រោយហ្នឹង តើនៅឯណា?

**លោក រ៉ោម តុន៖**

**ឆ៖** ចាប់ពី៧៣ហ្នឹង វាមានមន្ទីរចល័តមួយនៅខាងក្រោយហ្នឹង គេហៅមន្ទីរ២៤។

**ស៖** កាលដែលនៅមន្ទីរ២៤ហ្នឹងហើយ ជាកន្លែងដែលលោក ខៀវ សំផន ស្នាក់នៅមែនទេ?

**ឆ៖** បាទ។

[០៩:៣១:២១]

**ស៖** តើលោកអាចបញ្ជាក់ពីទីតាំងនៃកន្លែងហ្នឹងឲ្យបានច្បាស់បន្តិចទេ បានទេ? ឧទាហរណ៍ដូចជាអាចផ្តល់ឈ្មោះភូមិណាមួយ ដែលនៅជិតមន្ទីរហ្នឹង ឬក៏ស្រុក ឬក៏តំបន់អីដែលនៅក្បែរៗមន្ទីរហ្នឹងដែរឬទេ?

**ផ៖** មន្ទីរ២៤ហ្នឹង គឺនៅជិតភូមិ គេហៅភូមិសំរោង១ អាហ្នឹងវានៅក្នុងស្រុកស្ទឹងត្រង់ដដែល។

**ស៖** គឺថានៅជិតមន្ទីរ ស-៧១ដែរមែនទេ?

**ផ៖** មន្ទីរស-៧១ ឆ្ងាយពីគ្នាដែរ ឆ្ងាយ។ ព្រោះមន្ទីរស-៧១ ហ្នឹងវានៅជិតស្ទឹងជីនិតឯណោះ។ ២៤ នេះវានៅ បើពីភូមិសំរោងអំមិញ វានៅខាងកើតភូមិសំរោង។ បើនិយាយពីស្ទឹងហ្នឹង ស្ទឹងជីនិតដែរ ប៉ុន្តែវាឆ្លងពីគេហៅថា បង្គីតឹងរ៉េន ភូមិបង្គីតឹងរ៉េនហ្នឹងឆ្លងមកស្ទឹងជីនិតហ្នឹង បានចាក់មកបានគេហៅ វាលស្រង់ អ៊ីចឹង។ វាលស្រង់ អ៊ីចឹងហើយ។

**ស៖** តើលោកដឹងទេ ហេតុអ្វីបានជា ខៀវ សំផន គាត់នៅសមរភូមិក្រោយ ឯចំណែកអ្នកផ្សេងៗទៀត គាត់នៅមន្ទីរ ប-៥ នៅជិតមន្ទីរសមរភូមិខដុង្គនោះទៅវិញ?

**ផ៖** កាលគាត់នៅមន្ទីរហ្នឹង មិនមែនគាត់នៅម្នាក់ឯងទេ គឺថាពេលខ្លះអ៊ំ នួន ជា នៅជាមួយគាត់ដែរ។ ហើយពេលខ្លះគាត់នៅម្នាក់គាត់អ៊ីចឹងដែរ វាត្រូវតែចល័តអ៊ីចឹង។

**ស៖** ដូច្នេះ ខ្ញុំយល់បានន័យថា គឺលោកអត់ដឹងពីមូលហេតុជាក់លាក់នេះទេ មែនទេ?

**ផ៖** បាទ ខ្ញុំអត់ដឹងទេបាទ។

[០៩:៣៤:២២]

**ស៖** តើនៅពេលណាដែលខដុង្គ ត្រូវបានវាយយកបានជាលើកទី២នោះ?

**ផ៖** ខដុង្គទៅយកបានលើកទី២ហ្នឹងក្នុងខែមករា ឆ្នាំ៧៥ហ្នឹង។ មករា, កុម្ភៈ ហ្នឹងឯង ចន្លោះហ្នឹងឯង។

**ស៖** នៅពេលដែលវាយយកខដុង្គបាន តើ ប៉ុល ពត គាត់បានសម្រេចក្នុងការបង្ខិតទីបញ្ជាការសម្រាប់គោលដៅវាយយកបន្ត គឺវាយយកភ្នំពេញនោះ តើគាត់បង្ខិតទីបញ្ជាការហ្នឹងទៅមុខទៀតដែរឬទេ?

**ផ៖** គាត់ខិតទៅមុខ ដូចខ្ញុំថា មន្ទីរស្តុកគោលហ្នឹង។

**ស៖** តើនៅពេលណាដែល ប៉ុល ពត គាត់ផ្ទេរមន្ទីរ ឬក៏បង្ខិតមន្ទីរគាត់ -- ទីបញ្ជាការថ្មីរបស់គាត់នោះ?

**ផ៖** ពេលហ្នឹង គឺថារំដោះខដុង្គរួច។

**ស៖** តើប្រហែលជាប៉ុន្មានថ្ងៃ? ឬប៉ុន្មានខែ ក្រោយពីរំដោះខដុង្គរួច?

[០៩:៣៦:៤៥]

**ឆ៖** ខ្ញុំមិនចាំថ្ងៃ ខ្ញុំមិនចាំខែប៉ុន្មាន ប៉ុន្តែខ្ញុំគិតថា ចន្លោះន៎ៃ បើពីខែ២ -- ពីខែ១, ខែ២ ហ្នឹង នៅក្នុងហ្នឹង គឺថាមានតែចុងខែ៣ហ្នឹង ឬក៏ពាក់កណ្ដាលខែ៣ហ្នឹង វាចន្លោះហ្នឹង។

[០៩:៣៧:២៧]

**ស៖** ហើយចាប់ពីពេលនោះទៅ គឺប៉ុល ពត គាត់នៅមន្ទីរនៅស្តុកតោលហ្នឹង តើមែនទេ?

**ឆ៖** បាទ គាត់នៅនុ៎ង បាទ។

**ស៖** ហើយពស្តុកតោលហ្នឹង គឺលោកបានបញ្ជាក់ថា លោកឃើញ ប៉ុល ពត ហ្នឹង គាត់ជាអ្នកបញ្ជាការវាយយកទីក្រុងភ្នំពេញ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងហើយបាទ។

**ស៖** តើលោកដឹងអំពីគោលការណ៍សម្ងាត់ដែលមាននៅក្នុងចំណោមពួកខ្មែរក្រហម គឺរួមទាំងមុនឆ្នាំ៧៥ផងដែរ? គោលការណ៍សម្ងាត់នេះ គឺថាត្រូវបានគេបង្រៀន ហើយគឺថាគេប្រាប់ថា កុំគិតពីរឿងការងារគេ គិតតែរឿងខ្លួនឯងទៅ ហើយគឺថាគោលការណ៍សម្ងាត់នេះហើយ គឺថាជាមធ្យោបាយសម្រាប់ឈានទៅដល់ការវាយយកទទួលបានជ័យជម្នះនោះ។ តើលោកអាចប្រាប់បានទេ ថាគោលការណ៍សម្ងាត់នេះ លោកដឹងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** នៅថ្ងៃទី៣០ ខែកក្កដា នៅក្នុងសវនាការនេះ។ នៅពេលដែលលោកឆ្លើយនឹងភាគីដើមបណ្ដឹងរដ្ឋប្បវេណី គឺលោកស្រីមេធាវី ស៊ីម៉ុនណូហ្វត នៅម៉ោង ១៥:៣៥ និង១៥:៤០ លោកបានប្រាប់ថា នៅពេលដែលគេប្រាប់ឲ្យរក្សាការសម្ងាត់ គឺត្រូវតែរក្សាជាដាច់ខាត។

[០៩:៤០:០៥]

តើលោកមាននឹកឃើញទេ នៅពេលដែលលោកឆ្លើយថា ឆ្លើយសំណួរបែបនេះ ដល់ឥឡូវលោកប្រាប់ទៅថា លោកអត់ដឹងពីគោលការណ៍រក្សាការសម្ងាត់នេះទៅវិញ នៅក្នុងចំណោមសហគមន៍ខ្មែរក្រហមនោះ?

**ឆ៖** អំមិញលោកសួរថា នៅកន្លែង ដូចថានៅកន្លែងស្តុកតោលហ្នឹង។ ខ្ញុំយល់សំណួរហ្នឹង ខ្ញុំអ៊ីចេះទេ ខ្ញុំយល់ថា គឺថា មានន័យថាចង់សួរថា តើនៅស្តុកតោលហ្នឹង មានប្រជុំដើម្បីរក្សាការសម្ងាត់ហ្នឹង។ ដែលខ្ញុំដឹងអត់? ខ្ញុំឆ្លើយថាខ្ញុំអត់ដឹង គឺខ្ញុំយល់ថាអ៊ីចឹង។

**ស៖** បាទអ៊ីចឹងលោកប្រហែលជាយល់សំណួរខ្ញុំមិនច្បាស់ ដូច្នេះខ្ញុំសូមទោសផង ប្រហែលជា

ខ្ញុំប្តូរប្រធានបទលឿនពេក។ តាមពិតខ្ញុំនិយាយពីគោលការណ៍រក្សាការសម្ងាត់ហ្នឹង គឺថាជាទូទៅក្នុងបក្ស ដែលពាក់ព័ន្ធនឹងថា ត្រូវតែរក្សាការសម្ងាត់ តើលោកដឹងទេ ថានៅក្នុងបក្សហ្នឹង មានគោលការណ៍ដែលត្រូវតែរក្សាការសម្ងាត់? ហើយលោកក៏បាននិយាយពីបញ្ហានេះរួចមកហើយ។ អ៊ីចឹងសូមឱ្យលោកបញ្ជាក់បន្ថែមពីចំណុចនេះ។

[០៩:៤១:៤៧]

**ឆ៖** បើលោកសួរសំណួរអ៊ីចឹង អាហ្នឹងៗខ្ញុំយល់វិញទេ។ គឺថាជាគោលការណ៍ គឺថាក្នុងហ្នឹង គឺថាយកគោលការណ៍ការងារសម្ងាត់នេះជាការងារមូលដ្ឋាន ធ្វើអីក៏ដោយ ៗការងារសម្ងាត់នេះវាជាមូលដ្ឋាន។ អាហ្នឹងគឺថាអប់រំគ្នាជាគ្រប់ការប្រជុំ គឺថាត្រូវតែរំឭក អាហ្នឹងជាទី១តែម្តង គឺមានអ៊ីចឹង។ គ្រប់ៗគ្នាក៏ត្រូវយល់ សូម្បីតែធ្វើដំណើរតាមផ្លូវ ក៏យកអាការងារសម្ងាត់នេះជាទី១ដែរ។ អ៊ីចឹងបាទ។

**ស៖** សូមអរគុណចំពោះចម្លើយដ៏ច្បាស់លាស់នេះលោកសាក្សី។ ឥឡូវនេះខ្ញុំចង់សួរលោកថា តើជាមនុស្សដដែល ដែលជាអ្នកបញ្ជាកងអង្គរក្ស ស-៧១, ប-៥ ហើយនិងស្តុកគោលនោះ តើជាមនុស្សតែមួយទេ មែនទេដែលៗជាអ្នកបញ្ជាកង -- ក្រុមកងការពារនោះ?

**ឆ៖** ព្រោះខ្ញុំមកនៅមន្ទីរ ប-៥ មន្ទីរស្តុកគោលនេះ វានៅផ្ទាល់ហ្នឹង គឺមានតែបង ស្វរ ហុង ទេ ដែលគាត់នៅជាប់ជាមួយគ្នាហ្នឹង។ គាត់ជាមេរបស់ខ្ញុំពីលើខ្ញុំ។ គាត់តែងតែដាស់តឿនរំឭក គឺៗគាត់ជាមេនោះហើយ គាត់ចាត់ចែងអ៊ីចឹងបាទ។

[០៩:៤៤:១៣]

**ស៖** តើស្តុកគោលមានឈ្មោះជាកូដទេ? បើមានតើឈ្មោះអីដែរ?

**ឆ៖** តាមខ្ញុំចាំដូចជា ៗអត់មានលេខកូដអីទេ។

**ស៖** នៅមន្ទីរ ស-៧១ ឬក៏នៅមន្ទីរ ប-៥ ឬនៅស្តុកគោល តើលោកស្គាល់មនុស្សម្នាក់ដែលឈ្មោះ ហ៊ុន តាន់ ហៅ ស៊ូ តាន់ ដែរឬទេ?

**ឆ៖** ឈ្មោះនេះខ្ញុំអត់ដែលស្គាល់ទេ។

**ស៖** នៅក្នុងក្រុមកងការពារដែលលោកនៅក្នុងនុ៎ងដែរនោះ តើមានវិធានដែលត្រូវរក្សាការសម្ងាត់ចំពោះកងការពារដែលថាត្រូវនៅ ស្ថិតនៅឆ្ងាយពីមេដឹកនាំដែលខ្លួនត្រូវការពារ នៅពេលដែលមេដឹកនាំនោះមានការពិភាក្សា ឬក៏មានការប្រជុំអ្វីមួយនោះ តើគេមានៗឱ្យយើងនៅចម្ងាយសុវត្ថិភាពប៉ុនណាៗ ពីមេដឹកនាំទាំងអស់នោះទេ?

**ឆ៖** ពេលដែលគាត់បើកវគ្គរៀនសូត្រ យើងនៅមិនឆ្ងាយប៉ុន្មានទេ គេ -- យើងនៅយើងអាចស្ដាប់បានថាគាត់ឧទ្ទេសនាមអីហ្នឹង គឺយើងអាចស្ដាប់បាន មិនឆ្ងាយប៉ុន្មានទេ។ គ្រាន់ថាវាមិនបានទៅវាស់ម៉ែត្រវាស់អីទេ គ្រាន់ថាវាមិនឆ្ងាយប៉ុន្មានទេ។ បើគាត់ហៅយើង ក៏យើងឮដែរ បើសិនជា បើករណីកើតហេតុអី ក៏យើងអាចស្ទុះរត់ គឺថាទៅវាអាចទាន់ពេលវេលាដែលអ៊ីចឹង។ វាមិនឆ្ងាយប៉ុន្មានទេ។

[០៩:៤៧:១៩]

**ស៖** តើលោកអាចបញ្ជាក់បានទេថា អាចមានរឿងអីកើតឡើងនោះ? កើតឡើង -- មានរឿងអី? អាចមានខ្មាំងមកពីខាងក្រៅ ឬក៏យ៉ាងម៉េច? គ្រោះថ្នាក់ហ្នឹង គ្រោះថ្នាក់បែបណា?

**ឆ៖** យើងបង្ការហ្នឹង គឺយើងខ្លាចថា ដូចថាមានខ្យល់គរ មានអ៊ីចឹងទៅណ៎ា អ៊ីចឹង។ ព្រោះនិយាយ ពួកគាត់ឧទ្ទេសនាមឯកសារច្រើន ហត់ហេវក្រែងវាមានអាហ្នឹងមួយផ្នែក ចំពោះថ្នាក់ដឹកនាំ។ ប៉ុន្តែមួយផ្នែក ចំពោះសិក្ខាកាមអ៊ីចឹង គឺមានន័យអ៊ីចឹង។ អារឿងខ្មាំងហ្នឹង វាគឺថាកន្លែងហ្នឹងគឺថាយល់ថាទាន់តែ១០០ភាគរយ បានគេបង្កើតសាលាដើម្បីបង្រៀនកម្មាភិបាលបាន។ អ៊ីចឹង វាមានអីទេរឿងខ្មាំងពីក្រៅនោះ។ ហើយខ្ញុំថាយាមកាមហ្នឹង វាៗជាៗគោលការណ៍អ្នកដែលធ្វើបដិវត្តន៍ គឺវាត្រូវតែអ៊ីចឹង។ តែមានធ្វើការអីៗវាត្រូវតែមានការយាមកាមអ៊ីចឹង។ នៅផ្ទះក៏យាមកាម នៅឯសាលាបើកវគ្គរៀនសូត្រក៏យាមកាម។ អាហ្នឹងជារឿងជាគោលការណ៍មួយអ៊ីចឹងតែម្ដង។

[០៩:៤៩:០៧]

**ស៖** លោកសាក្សី ការងាររបស់កងការពារ ដើម្បីតែជួយមេដឹកនាំនៅពេលគាត់ហត់ទេ ឬក៏ជួយការពារកុំឲ្យមានគ្រោះថ្នាក់អីនោះ?

**ឆ៖** ភារកិច្ចរបស់អ្នកការពារ វាការពារទាំងអស់ហ្នឹងហើយ ទាំងសុខភាព ទាំងខ្មាំងសត្រូវ គឺគិតទាំងអស់ហ្នឹងហើយ។ ម៉េចគេហៅថាសន្តិសុខនោះ? គិតទាំងអស់ហ្នឹង។

**ស៖** លោកសាក្សី ខ្ញុំចង់បង្ហាញជូននូវចម្លើយរបស់លោក សួរ ហុង ដែលគាត់បានមកផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការនេះ។ ហើយលោកក៏បានទទួលស្គាល់ផងថា គាត់ជាអ្នកបញ្ជាកងការពារ ហើយលោកក៏ជាសមាជិកនៅក្នុងក្រុមការពារនោះ។ ដូច្នេះ ខ្ញុំសូមលើកឡើងនៅសវនាការថ្ងៃទី២ ឧសភា ឆ្នាំ២០១២ គឺលេខកូដ E1/71.1 ទំព័រទី១១ ជាភាសាបារាំង។ ERN ជាភាសាបារាំង 00806680, ERN ជាភាសាខ្មែរ 00805095, ភាសាអង់គ្លេស 00806758។ ខ្ញុំសូមអានឃ្លាដែលលោក សួរ ហុង ឆ្លើយ ប៉ុន្តែមុននេះ ខ្ញុំសូមបញ្ជាក់ប្រាប់លោកថា សួរ ហុង នោះបានបញ្ជាក់ថា៖ “អ្នកយាមនៅក្នុងកិច្ច

ប្រជុំមានមេដឹកនាំនោះគឺថា ស្ថិតនៅចម្ងាយពី ៥០ ទៅ ៦០ម៉ែត្រពីកន្លែងប្រជុំ”។ តើលោកអាចឆ្លើយទៅនឹងចម្លើយនេះបានទេ? ពី -- នេះជាចម្លើយរបស់មេរបស់លោក ដែលគាត់ឆ្លើយថាបែបនោះ។

**ឆ៖** ចំណុចនេះ ខ្ញុំឯកភាពដែលគាត់បានចាត់ចែងអ៊ីចឹង។ អាហ្នឹងវាមានជិត វាមានឆ្ងាយ។ អម្បាញ់មិញខ្ញុំនិយាយគឺនិយាយថា វាជិត អាហ្នឹងវាឆ្ងាយ វាមាន -- យើងមិនមែនយាមតែមួយជាន់ឯណា គឺមានយាមច្រើនជាន់ដែរ។ គាត់ថាហ្នឹងអត់ខុសទេ។

[០៩:៥២:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំមិនគិតថា តើមានការបកប្រែទៅជាភាសាបារាំងទៅអង់គ្លេសទេ ប៉ុន្តែសេចក្តីដកស្រង់ដែលមេធាវីបានលើកឡើងសម្តីរបស់ សួរ ហុង នោះ គឺសក្ខីកម្មគាត់និយាយថាចម្ងាយដែលអ្នកយាមត្រូវតែប្រចាំការនោះគឺ ជាទូទៅគឺ ១៥ម៉ែត្រនៅចម្ងាយហ្នឹង។ ហើយឆ្ងាយហ្នឹងគឺថា -- បើឆ្ងាយបំផុតត្រឹមតែ ៥០ទៅ៦០ម៉ែត្រ។ ហើយបើតាមតែឮបកប្រែ តាមសម្តីរបស់មេធាវីការពារនោះគឺមិនអ៊ីចឹងទេ។ ហើយប្រតិចារឹកជាអង់គ្លេសភាសា សម្តីរបស់ សួរ ហុង ដូចខ្ញុំបញ្ជាក់អម្បាញ់មិញនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មេធាវី ដកស្រង់តែចំណុចឆ្ងាយទេ ហើយចំណុចជិតហ្នឹងគាត់មិនដកមកសួរទេអំមិញហ្នឹង។ ភាសាខ្មែរគឺច្បាស់អ៊ីចឹង។ អ៊ីចឹងសាក្សីឆ្លើយរួចហើយ។

[០៩:៥៣:៤០]

**លោក អាកឡូរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ហើយក៏សូមអរគុណលោកសហព្រះរាជអាជ្ញាផងដែរ។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** អ្វីដែលខ្ញុំចង់ដឹងនោះគឺថា បើយោងតាមវិធានរក្សាការសម្ងាត់ដែលមាននៅសម័យនោះលោកខ្លួនឯងផ្ទាល់ដែលជាកងការពារនោះ តើលោកមានសិទ្ធិទៅជិត ទៅចម្ងាយជិត ដើម្បីស្តាប់ឮកិច្ចសន្ទនារបស់មេដឹកនាំទាំងអស់នោះ ឬក៏ដើម្បីស្តាប់ឮអំពីខ្លឹមសារនៃកិច្ចប្រជុំយុទ្ធសាស្ត្រដែលបានរៀបចំនោះ តើអ៊ីចឹងមែនទេ អ្វីដែលលោកឆ្លើយអម្បាញ់មិញនេះ? នេះជាចំណុចដែលខ្ញុំចង់ដឹង។

**ឆ៖** ចំណុចនេះគឺថា ដូចខ្ញុំបានបញ្ជាក់បន្តបន្ទាប់ហើយថា គឺកន្លែងខ្លះ វា -- កន្លែងប្រជុំខ្លះវាជិតដែរ ម្ខាងដំបូកម្នាក់ម្ខាងដំបូក។ បើកន្លែងៗដែលថា វាលដែលសាលារៀនធំដុំអីហ្នឹង សាលារៀនដែលរៀនរាប់សិប ឬមួយរាប់រយនាក់អីនុ៎ង វាទៅតាមសភាពការណ៍ជាក់ស្ដែងអីចឹង។ ជិតក៏បាន ឆ្ងាយក៏បាន។

[០៩:៥៥:០០]

ប៉ុន្តែក្នុងហ្នឹងជាធម្មតាគឺថា អ្នកជិតក៏មានដែរ អ្នកឆ្ងាយក៏មានដែរ អីចឹង គឺថាជាធម្មតាគឺរៀបចំអីចឹង។ អ្នកជិតហ្នឹងគាត់គួសវាស គាត់ឧទ្ទេសនាម ក៏យើងស្ដាប់បាន តែវាមិនបានអស់ទេ ពីព្រោះភារកិច្ចយើងវាពីរ។ ភារកិច្ចទីមួយ យើងផ្ដោតតែរឿងសន្តិសុខ នេះជារឿងទីមួយ។ រឿងទីពីរ ដែលយើងស្ដាប់គាត់ឧទ្ទេសនាម អាហ្នឹងជារឿងបន្ទាប់បន្សំ យើងអាចថាចំណុចណាដែលយើងចាប់អារម្មណ៍ វាអាចអីចឹង។

**ស៖** មានបញ្ហាពីរកើតឡើងពីចម្លើយរបស់លោកនេះ។ បញ្ហាទីមួយគឺពាក់ព័ន្ធទៅនឹង -- ទាក់ទងនឹងរឿងដំបូក ខ្ញុំចង់ដឹងថា តើហេតុអីបានជាលោកទៅរក្សាការពារដំបូកកណ្ដៀរនោះទៅវិញ? មានការវៃដំបូកកណ្ដៀរ ហេតុអីបានជាលោកនិយាយអំពីដំបូកកណ្ដៀរទៅវិញ ខ្ញុំដូចអត់យល់ចំណុចនេះ?

[០៩:៥៦:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមនៃអង្គសវនាការ។ ចំណុចនេះ ដូចជាសាក្សីអត់បាននិយាយអំពីគាត់ ទៅការពារដំបូកកណ្ដៀរនៅកន្លែងណាមួយទេ លោកប្រធាន។

**លោក អាកទ្ធូរ វែកគែន៖**

បាទ គឺជាភាសាបារាំងបកឲ្យខ្ញុំស្ដាប់នោះគឺថា ជាដំបូកកណ្ដៀរ។ អីចឹងបានខ្ញុំចង់សើចហ្នឹង ខ្ញុំសួរបញ្ជាក់ទៅកាន់សាក្សីរូបនេះ ថាគាត់បាននិយាយពីដំបូកកណ្ដៀរមែន ឬក៏អត់?

[០៩:៥៧:១៤]

**សួរដោយលោក អាកទ្ធូរ វែកគែន៖**

**ស៖** លោកសាក្សី តើដំបូក ឬក៏ដំបូកកណ្ដៀរហ្នឹងជាអ្វីដែរ?

**លោក វ៉ាចាម តុន៖**

**ឆ៖** អង្គាល់ចំណុចមួយនោះ ដែលនៅមន្ទីរ ប-៥ នោះ អង្គាល់ហ្នឹងខ្ញុំមិនៗ -- មានលើកឡើងថា គឺរោងហ្នឹងៗវានៅក្រោមម្លប់ដើមឈើ ដែលប្រក់ដោយស្លឹកត្នោត ហើយខ្ញុំយាមហ្នឹងគឺៗវាកំបាំងដំបូកអ៊ីចឹងណា៎ះ កំបាំងដំបូក។ ខ្ញុំឧទាហរណ៍ឲ្យឃើញអ៊ីចឹង។ កន្លែងខ្លះទេ ខ្ញុំថាកន្លែងខ្លះវាអ៊ីចឹង ប៉ុន្តែកន្លែងខ្លះទេ បើកន្លែងបើកវគ្គធំៗនោះ កន្លែងហ្នឹងវាស្រឡះ ហើយវាធំទូលាយ អាហ្នឹងគឺថាយើងមានយាមជិត យើងមានយាមឆ្ងាយ។ ក្នុងដែលយើងយាមជិតនេះ ខ្ញុំចង់និយាយថា ខ្ញុំបានឆ្លងកាត់ដែលយាមជិតនេះ គឺខ្ញុំភារកិច្ចទីមួយរបស់ខ្ញុំគឺយាមអ៊ីចឹងហើយ ផ្តោតថាយាមហ្នឹង ទាល់តែវៃឈ្លាសរឿងយាម។ ប៉ុន្តែក្នុងហ្នឹងខ្ញុំមានត្រចៀកពីរដែរ ដូច្នេះខ្ញុំត្រូវតែស្តាប់គាត់ឧទ្ទេសនាមខ្លះដែរ ចង់ដឹងក្នុងបើកវគ្គធំៗអ៊ីចឹង តើគាត់ត្រូវនិយាយពីរឿងអីខ្លះ? អាហ្នឹងខ្ញុំចង់និយាយចំពោះខ្លួនខ្ញុំអ៊ីចឹង បើថាខ្ញុំយាមជិតហើយខ្ញុំទីមួយ រឿងភារកិច្ចយាម។ ទីពីរ ខ្ញុំត្រូវស្តាប់ខ្លឹមសារដែលយាម -- ទន្ទឹមនឹងការយាមហ្នឹងគឺស្តាប់ការឧទ្ទេសនាមរបស់គាត់ខ្លះដែរ។ អ៊ីចឹងបាទ។

[០៩:៥៩:០២]

ព្រោះចម្លើយលោកសួរអំមិញ ថាយាមកណ្តៀរ យាមដំបូក។ ខ្មែរគេមាននិយាយតើ អារឿងដំបូក ហើយនិងកណ្តៀរហ្នឹង វាមានតើភាសាខ្មែរត្រង់ហ្នឹង។ អាហ្នឹងខ្ញុំត្រូវនិយាយឲ្យវាឃើញការពិតមានភាសាខ្មែរហ្នឹង។ ដំបូកកណ្តៀរហ្នឹងវាមាន--

**ស៖** បាទ ឥឡូវខ្ញុំយល់ហើយលោកសាក្សី។ អ្វីដែលខ្ញុំចង់ដឹងច្បាស់នោះ គឺថានៅពេលដែលលោកនិយាយគេបកមកឲ្យខ្ញុំស្តាប់អ៊ីចឹង។ ដូច្នេះខ្ញុំចង់ដឹងពីអ្វីដែលកើតឡើងក្នុងពេលប្រជុំ លោកនិយាយអំពីការចង់ដឹងពីការឆ្ងល់របស់លោកខ្លួនឯងផ្ទាល់ ឬក៏នេះជាភារកិច្ចចាំបាច់របស់លោក? សូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់ អំពីភាពចាំបាច់អំពីការដឹងអំពីខ្លឹមសារនេះ គឺថាមានគោលដៅអ្វី? ថាលោកចង់ដឹងខ្លួនឯង ឬក៏ថាជាកាតព្វកិច្ចក្នុងការងាររបស់លោក ដែលលោកត្រូវដឹង?

[១០:០០:០០]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបានឆ្លើយតបទេ។ សំណួរច្រំដែលទេ។ សាក្សីបានឆ្លើយរួចហើយអម្បាញ់មិញនេះ។

**លោក អាកទួរ វែកគែន៖**

លោកប្រធានភាសាបារាំង ខ្ញុំមិនបានយល់ទេ ដូច្នេះបានខ្ញុំសួរបញ្ជាក់ឲ្យគាត់ច្បាស់។ លោក

ប្រធានប្រហែលជាយល់ជាភាសាខ្មែរ ក៏ប៉ុន្តែជាភាសាបារាំង ខ្ញុំអត់ទេ ប្រសិនបើខ្ញុំមិនយល់ ខ្ញុំមិនអាចបន្តទៅទៀតបានទេ។ ខ្ញុំទាល់តែដឹងច្បាស់សិន។

[១០:០០:៣៥]

**ប្រធានអង្គជំនុំ៖**

សំណួរនេះសាក្សីឆ្លើយរួចហើយ ហើយច្រើនដងទៀតផង។ សំណួរច្រំដែល។ យើងកត់សម្គាល់ឃើញលោកសួរច្រំដែលច្រើនណាស់ព្រឹកនេះ។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំសូមរំឭកថា យើងធ្វើការជាបីភាសានៅទីនេះ ប្រសិនបើខ្ញុំៗមិនយល់ការបកប្រែរបស់ខ្ញុំនោះគឺថា ខ្ញុំមិនអាចបន្តការងារជាមេធាវីរបស់ខ្ញុំបានទៀតទេ។ លោកប្រធានអាចស្ដាប់បានច្បាស់ជាភាសាខ្មែរ យល់ច្បាស់ ប៉ុន្តែខ្ញុំជាភាសាបារាំង គឺអត់ច្បាស់សោះ។ ដូច្នេះ ខ្ញុំត្រូវការការបំភ្លឺអំពីសាក្សី។ បើសិនជាលោកប្រធានឲ្យខ្ញុំបន្តទៅមុខទៀត ហើយតយ៉ាងម៉េចកើតបើខ្ញុំអត់ទាំងយល់ផងហ្នឹង។ ដូច្នេះ ចំណុចកន្លែងនេះគឺសំខាន់ ខ្ញុំសួរគាត់បញ្ជាក់ឲ្យបានច្បាស់ ថាគាត់ស្ដាប់ឮនៅពីលើមាត់ទ្វារ ឬក៏ថានៅក្របខ័ណ្ឌ នៃការងាររបស់គាត់នោះ គឺថាគាត់ត្រូវតែដឹងពីខ្លឹមសារនៃកិច្ចប្រជុំរបស់គាត់តែប៉ុណ្ណឹងទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

យើងសម្រេចរួចហើយ។ លោកអាចតាំងសំណួរផ្សេងទៀត។ យើងបានកត់សម្គាល់ឃើញថាលោកតាំងសំណួរច្រំដែលច្រើន។ នេះជាវិធីសាស្ត្រថ្មី ដែលយើងបានកត់សម្គាល់តាំងពីម្សិលមិញមក។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន។ សហភាតាខ្មែររបស់ខ្ញុំ គាត់បានជួយប្រាប់ហើយ។ អ៊ីចឹង ខ្ញុំយល់ហើយ។ អ៊ីចឹងខ្ញុំសូមចូលទៅចំណុចផ្សេងទៀត។

[១០:០២:២៧]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកសាក្សីគាត់បានឆ្លើយថា នេះគឺជាការចាប់អារម្មណ៍ផ្ទាល់ខ្លួនទេ មិនមែនជារឿងការងារទេ។ នៅក្នុងសវនាការនេះលោកសាក្សី លោកបានឆ្លើយថា កិច្ចប្រជុំស្តីពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺនៅដើមខែមេសា ឆ្នាំ៧៥ ហើយការប្រជុំនេះ គឺធ្វើឡើងនៅមន្ទីរប-៥។ សំណួរ

ដំបូងរបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងទីកន្លែង។ អម្បាញ់មិញនេះ លោកបានឆ្លើយថា មន្ទីរបញ្ជាការវាយយកទីក្រុងភ្នំពេញ គឺមិនមែនប-៥ ទេ គឺនៅស្តុកតោល។ ខ្ញុំសូមរកមើលកំណត់ត្រារបស់ខ្ញុំសិន។ គឺប្រហែលជានៅខែមករា, កុម្ភៈ ឬក៏ពាក់កណ្តាលខែមីនា ឆ្នាំ៧៥ លោកបានឆ្លើយអម្បាញ់មិញនេះគឺអ៊ីចឹង។ សំណួររបស់ខ្ញុំគឺថា នៅខែមករា, កុម្ភៈ ឬក៏ពាក់កណ្តាលខែមីនា ឆ្នាំ៧៥ ប្រសិនបើមន្ទីរបញ្ជាការវាយយកភ្នំពេញនៅស្តុកតោល ហេតុអ្វីក៏កិច្ចប្រជុំសម្រេចការជម្លៀសប្រជាជន ចេញពីទីក្រុងភ្នំពេញនោះកើតឡើងពីកន្លែងផ្សេង គឺទៅជានៅប-៥ទៅវិញនោះ ម៉េចក៏មិននៅស្តុកតោល?

**លោក វ៉ាចាម តុន៖**

**ឆ៖** ចំណុចនេះគឺថា ខ្ញុំចង់បញ្ជាក់ថា ដែលខ្ញុំភ្លាប់បានហ្នឹង ដូចខ្ញុំបានរៀបរាប់ហើយថា កាលហ្នឹងនៅប្រជុំនឹងប-៥។ ប-៥ហ្នឹង គឺប្រជុំក្នុងខែ៤ ហើយចន្លោះអំមិញដែលខ្ញុំថា ក្រោយរំដោះឧដុង្គហ្នឹង ចន្លោះហ្នឹងវាក្នុងខែ១ ខែ២ ហ្នឹងចន្លោះហ្នឹងឯង ហើយផ្លាស់ពីប-៥ ទៅស្តុកតោលហ្នឹង វាមើល៍ថ្ងៃយើងរំដោះ គឺថ្ងៃ១៧ ៗ។ ដូច្នេះ ការដែលប្រជុំ ដែលខ្ញុំថាលើកៗដែល ដែលនៅ ប-៥ វានៅក្នុងខែ៤នៅឡើយ។ បានន័យថា មិនទាន់បានទៅប្រជុំហ្នឹង មិនទាន់បានទៅស្តុកតោលទេ គឺនៅ ប-៥ ហ្នឹងហើយ។ អង្កាល់ដើមខែមេសា ហ្នឹងមិនទាន់ទៅទេ ចន្លោះហ្នឹង -- កន្លែងហ្នឹង គឺខ្ញុំអាចនឹងច្រឡំ។ ច្រឡំខ្ញុំថា ដែលខ្ញុំរំដោះឧដុង្គអំមិញនោះ។ នៅរវាងខែ១, ខែ២ បែបខែ៣មិនដឹង។ ការពិតមិនមែនទេ គឺថាស្តុកតោលហ្នឹងវាខ្លីណាស់ ទៅនៅហ្នឹង វាខ្លី អត់មានអីវែងទេ ខ្លីមែនទែន។ ដែលប្រជុំនៅ ប-៥ ហ្នឹងហើយ ដែលនិយាយពីរឿងជម្លៀសប្រជាជនហ្នឹង នៅដើមខែមេសាហ្នឹង អ៊ីចឹង។ ដូច្នេះចង់បញ្ជាក់លោកឲ្យច្បាស់ចំណុចហ្នឹងគឺអ៊ីចឹង។ បើលោកឆ្ងល់អាត្រង់ថា រំដោះឧដុង្គហ្នឹង ខែ១, ខែ២, ខែ៣ ថាផ្លាស់ទៅ។ លោកឆ្ងល់ត្រង់ហ្នឹង ខ្ញុំបញ្ជាក់អ៊ីចឹងទៅ ដើម្បីឲ្យវាច្បាស់។

[១០:០៦:៣៧]

**ស៖** តើលោកដឹងថា ហេតុអ្វីបានជា ប៉ុល ពត នៅរក្សាទីបញ្ជាការនៅ ប-៥ នៅខណៈដែលក្រុងឧដុង្គ ត្រូវបានរំដោះហើយ ហើយហេតុអីក៏គាត់នៅ ប-៥ វិញ ហើយមិនបង្ខិតទៅមុខ ទៅដល់គោលដៅចម្បងដែលជាទីក្រុងភ្នំពេញទៅវិញ?

**ឆ៖** បើលោកសួរចំណុចហ្នឹង គឺខ្ញុំសូមជម្រាបថា កន្លែងស្តុកតោលហ្នឹង មុននឹងយើងទៅដល់ហ្នឹង កន្លែងហ្នឹងគឺថាលោក សុន សេន គាត់នៅកន្លែងហ្នឹង។ ដល់គាត់ខិតទៅ ខ្ញុំថានៅ បាត់គូនហ្នឹង កន្លែងហ្នឹងគឺថា ទៅឲ្យ ប៉ុល ពត ទៅនៅ -- ទៅជាន់ឈ្នាន់ហ្នឹង ដើម្បីគ្រាន់ឈានទៅមុខបន្តិចអ៊ីចឹង។

**ស៖** ហើយអ៊ីចឹង សុន សេន និង ប៉ុល ពត នោះមិនអាចធ្វើការជាមួយគ្នានៅទីបញ្ជាការទេ ឬយ៉ាងម៉េច? ខ្ញុំអត់យល់ចម្លើយលោកទេ លោកសាក្សី។

**ឆ៖** បើខ្ញុំបញ្ជាក់ប៉ុណ្ណឹង បើលោកអត់យល់។ ខ្ញុំមិនដឹងថាជានិយាយថាម៉េចទៀត។ ខ្ញុំអត់យល់ដែរ។ ខ្ញុំមានភារកិច្ចបញ្ជាក់ប៉ុណ្ណឹង។

[១០:០៨:៥៧]

**ស៖** នៅចំពោះមុខអង្គជំនុំជម្រះ គេបានជម្រាបជូនលោកថា មានសៀវភៅមួយដែលសរសេរដោយលោក ហ្វីលីព ស្សូត។ លោកយល់ស្របថា លោកបានជួបលោក ហ្វីលីព ស្សូត។ នៅក្នុងសៀវភៅគាត់នោះ គឺថាគាត់បានសរសេរ គឺថាលោកបានជួបគាត់ប្អូនដង គឺថានៅទំព័រទី១៨ ជាភាសាបារាំងដែលបោះពុម្ពនៅឆ្នាំ២០០៧ គឺថាទី៤, ទី៦ ខែឧសភា ឆ្នាំ២០០១ លោក -- គឺថាគាត់បានរៀបរាប់អំពីលោកនោះដល់ទៅ ៣៦ដង -- ៣៧ដង ថាវត្តមានរបស់លោកក្នុងសៀវភៅនេះ មានសារៈសំខាន់ណាស់ ហើយគាត់និយាយអំពីការបង្កើតមន្ទីរស្តុកគោល។ គាត់និយាយនៅក្នុងសៀវភៅហ្នឹងដែលមានលេខកូដ E3/9 នៅទំព័រ៣៣៩ ជាភាសាបារាំង ERN ជាភាសាបារាំង 00639794, ERN ជាភាសាអង់គ្លេស គឺ 00396471។ នៅទំព័រនុ៎ង គាត់និយាយអំពីការបង្កើតមន្ទីរស្តុកគោល ដូចដែលលោកបាននិយាយអម្បាញ់មិញហ្នឹង គឺថានៅដើមខែមីនា ឆ្នាំ១៩៧៥។ តើលោកយល់ស្របជាមួយនឹងលោក ហ្វីលីព ស្សូត ដែរឬទេ? ឬក៏លោកមិនយល់ស្រប? តើគោលជំហររបស់លោកយ៉ាងម៉េចដែរ?

**ឆ៖** ឥឡូវ បើថាលោកយល់តាម ខ្ញុំសម្ភាសជាមួយជនជាតិបារាំងហ្នឹង យកតាមហ្នឹង ក៏យកទៅ មានស្អី។ បើកន្លែងនេះហ្នឹង ដែលខ្ញុំពន្យល់អំមិញ លោកអត់យល់ហើយ ខ្ញុំមិនដឹងថាម៉េចទៀត។

[១០:១១:៣២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជឿថា មេធាវីគាត់បានយោងទៅលើសៀវភៅនេះ។ ដូច្នេះហើយគួរតែបង្ហាញសៀវភៅនេះ ដើម្បីឲ្យយើងមើលថាតើ ហ្វីលីព ស្សូត នោះ បានសរសេរលើបញ្ហាភូមិភាគ? ឬក៏អះអាងពាក់ព័ន្ធទៅនឹងសាក្សី? សាក្សីមានសិទ្ធិពិនិត្យមើលទៅលើចំណុចនៅក្នុងសៀវភៅ ហ្វីលីព ស្សូត នោះ ថាតើមានការពាក់ព័ន្ធទៅនឹងខ្លួនដែរឬទេ? ដូច្នេះ ហើយមេធាវីគួរតែបង្ហាញ

សៀវភៅនេះ ទៅដល់សាក្សី។

**លោក អាកឡូរ វែកកែន៖**

*(គ្មានការបកប្រែ)*

បាទខ្ញុំពុំមានចេតនាក្នុងការបង្ហាញទំព័រនេះ។ ខ្ញុំគ្រាន់តែបង្ហាញ ដើម្បីជាផលប្រយោជន៍តុលាការនោះទេ ហើយខ្ញុំមិនមែនចង់និយាយថា ការសម្ភាសនេះ បានកំណត់កាលបរិច្ឆេទ នៃការប្តូរទីបញ្ជាការទៅនៅខែមីនានោះទេ។ ខ្ញុំមិនមែនចង់ថាបង្ហាញព័ត៌មាននេះ ដើម្បីឲ្យគាត់និយាយទៅផ្ទុយបញ្ច្រាសពីខ្លឹមសារនោះទេ។

[១០:១៣:១៩]

**ប្រធានអង្គជំនុំ៖**

ឲ្យលោកដាក់បង្ហាញឯកសារហ្នឹង គឺមិនត្រឹមតែសាក្សីទេ ភាគីពាក់ព័ន្ធផ្សេងទៀត និងអង្គជំនុំជម្រះបានមើលឃើញផង ដូចអ្វីដែលយើងបានកំណត់ពីមុននេះ រវាងការប្រើពាក្យ "សមរភូមិ" -- "បេ-៥ សមរភូមិ" និង "បេ-៥ ជាទីបញ្ជាការសមរភូមិមុខ" ដូច្នោះដែរ ដើម្បីឲ្យច្បាស់។ ពីព្រោះភាសានិយាយទៅ វាខុសគ្នាឆ្ងាយពេក។ អ៊ីចឹង ដើម្បីបញ្ជាក់ឲ្យច្បាស់លាស់នេះ គឺឲ្យមានភាពជឿជាក់ព្រោះលោកដេញដោលក្នុងន័យចង់ភាពជឿទុកចិត្តលើសាក្សីនេះ។ សំណួរទាំងប៉ុន្មាននេះ មានភាសាខ្មែរអត់? លោកសូមបង្ហាញឲ្យបានច្បាស់លាស់ទាំងអស់ នូវគ្រប់ភាសា។ បើគ្មាន ប្រាប់ថាគ្មាន? មានភាសាអីខ្លះ? ដូចភាគីដទៃទៀត ដែលគេធ្លាប់ធ្វើពីមុនៗមកច្រើនលើកច្រើនសាហើយ។

[១០:១៤:១២]

**លោក អាកឡូរ វែកកែន៖**

លោកប្រធាន មិនត្រឹមតែមិនមានជាការបកប្រែជាភាសាខ្មែរនូវសៀវភៅនេះទេ ហើយលើសពីហ្នឹងទៅទៀតនោះ ខ្ញុំមិនចង់បង្ហាញភាពចម្រូងចម្រាសរបស់រវាងចម្លើយរបស់លោកសាក្សីនោះ ទៅកាន់ ហ្វីលីព ស្សូត ហើយនិងអ្វីដែលគាត់កំពុងតែនិយាយទៅកាន់តុលាការក្នុងពេលនេះទេ។ នេះមិនមែនជាគោលបំណងខ្ញុំទេ។ អ៊ីចឹង គឺថាមិនមានប្រយោជន៍អីក្នុងការបង្ហាញសៀវភៅនេះទេ។ ខ្ញុំមិនចង់ឲ្យគាត់និយាយបញ្ច្រាសពីអ្វីដែលគាត់បាននិយាយទេ ខ្ញុំគ្រាន់តែចង់រំឭកថា នៅពេលដែលគេបង្កើតស្តុកគោលនោះ គាត់និយាយថា ខែកុម្ភៈ មករា ឬក៏ពាក់កណ្តាលខែមីនា គឺនៅចំណុចនេះហើយ ដែលលោក ហ្វីលីព ស្សូត យល់ស្របជាមួយនឹងសាក្សីនេះ។

[១០:១៥:០០]

ក៏ប៉ុន្តែបន្ទាប់មកទៀត នៅពេលដែលខ្ញុំជម្រាបគាត់ថា កិច្ចប្រជុំសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលសាក្សីនិយាយថា កិច្ចប្រជុំនេះនៅមន្ទីរប-៥ នៅដើមខែមេសា ហើយគ្រាន់តែជាប៉ុណ្ណឹង គាត់ហាក់ដូចជាត្រឡប់មកដូរមកនិយាយបែបផ្សេងទៀត មកនិយាយទាក់ទងថា នៅ--

**ប្រធានអង្គជំនុំ៖**

លោកអាចបន្តសំណួរបាន។ លោកអត់មានមកវាយតម្លៃលើកណ្តាលទីអឺចឹងទេ។ យើងដូចរំឭកលោកច្រើនលើកច្រើនសាហើយតាំងពីភាគីមុន។ អង្គជំនុំជម្រះយល់ហើយពីគោលបំណងរបស់លោកនៃការដេញដោលសាក្សីរូបនេះ អំពីបញ្ហានេះ គ្រាន់តែឲ្យលោកបង្ហាញលើ -- បើសិនជាលោកអូសទាញនូវឯកសារ សូមលោកបង្ហាញឯកសារនៅលើកញ្ចក់ទូរទស្សន៍ ហើយប្រាប់អត្តសញ្ញាណ ហើយនិងភាសាដែលវាមានផង តែប៉ុណ្ណឹងទេ។ យើងមិនមឲ្យពន្យល់អំពីរឿងដំណើរការនេះឯណា! សូម្បីតែសាក្សីឆ្លើយរួចហើយ លោកថាអត់ៗដឹងផង។ ហើយលោកតាំងសំណួរសាជាថ្មីម្តងទៀត ហើយសាក្សីគាត់មិនឆ្លើយតប ពីព្រោះគាត់ឆ្លើយបានច្បាស់លាស់ហើយ។

[១០:១៦:០៩]

បើមកពីការភាសា -- បកប្រែ គឺសូមលោកបញ្ជាក់អំពីការបកប្រែហ្នឹងមិនច្បាស់នៅកណ្តាលទីដើម្បីកុំអាលឲ្យសាក្សីហ្នឹងឆ្លើយចប់ ដើម្បីយើងចាត់ចែងសម្របសម្រួលជាមួយនឹងខាងបកប្រែភាសាដើម្បីឲ្យបកឲ្យច្បាស់។

**លោក អាកទូរ វែកគែន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំឲ្យលេខកូដអស់ហើយអម្បាញ់មិញនេះ។ ឥឡូវខ្ញុំសូមបន្តទៅចំណុចមួយទៀត។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោកសាក្សី លោកទើបតែនិយាយថា ប៉ុល ពត មិនបានមកស្តុកតោលទេ -- ភ្លាមនោះទេ។ ពីព្រោះថា សុន សេន ជាអ្នកនៅទីនោះហើយ។ ក៏ប៉ុន្តែនៅទីនេះដដែលនេះ កាលពីសប្តាហ៍មុន នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ បន្ទាប់ពីម៉ោង ប្រហែលជាម៉ោង៩:៥៧:១៧ វិនាទី គេបានចោទសំណួរលោកដូចតទៅនេះ។ ខ្ញុំសូមដកស្រង់៖ “សុន សេន -- តើសុន សេន មានមន្ទីរ ឬក៏មូលដ្ឋាននៅឧដុង្គដែរឬទេ? ចម្លើយ បាទជាការពិត គាត់មានមន្ទីរមួយមិននៅឆ្ងាយពីឧដុង្គប៉ុន្មានទេ។ សំណួរ តើ

លោកដឹងថា មន្ទីររបស់សុន សេន នៅទីណាទេ? ចម្លើយ គឺនៅវ៉ាស្នាច់ នៅក្បែរខដុង្គ”។ សូមបញ្ចប់ការដកស្រង់។

[១០:១៧:៤០]

វាហាក់ដូចជាថាវ៉ាស្នាច់នេះនៅជិតខដុង្គនេះ វាមិនដូចទៅនឹងស្តុកគោលទេ អ៊ីចឹងតើ -- នេះវាមានភាពចម្រូងចម្រាសរវាងចម្លើយរបស់លោកកាលពីសប្តាហ៍មុន ហើយនិងអ្វីដែលលោកនិយាយឥឡូវនេះ ពាក់ព័ន្ធទៅនឹងមន្ទីររបស់លោក សុន សេន នេះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

ខ្ញុំគ្រាន់តែចង់កត់សម្គាល់ថា មេធាវីនោះមិនបានបញ្ជាក់ពេលវេលាដែលបាននិយាយអម្បាញ់នេះទេ។ ពេលវេលាដែលនិយាយនៅពេលនោះ ក្នុងផ្នែកដែលគាត់លើកឡើងនោះ គឺពី ១៩:៣៥ គឺចាប់ពី ១៩:៣៥ ដូច្នេះហើយខ្ញុំចង់ឲ្យមេធាវីបញ្ជាក់ម៉ោងកំណត់ឲ្យបានច្បាស់ផង នៅពេលដែលសួរអំពី សុន សេន នោះ គឺរយៈពេលពីឆ្នាំ៧៣ ដល់៧៥ ឬក៏រយៈពេលប៉ុនណាដែរ?

**លោក អាកទួរ វែកគែន៖**

លោកប្រធាន សំណួរខ្ញុំបើកចំហ ហើយទុកឲ្យសាក្សីហ្នឹងមានលទ្ធភាពពន្យល់ចម្លើយតាមចិត្តចង់។ ខ្ញុំគិតថា ការអន្តរាគមន៍របស់សហព្រះរាជអាជ្ញានោះមានបំណងតែមួយគាត់ គឺថាចង់ជួយសាក្សីឲ្យស្រួលឆ្លើយ ហើយដែលអ្វីដែលខ្ញុំមិនយល់ទាល់តែសោះ។ ហើយនេះខ្ញុំមិនចាប់អារម្មណ៍ទេ ក៏ប៉ុន្តែសំណួរ -- ប៉ុន្តែយ៉ាងណាសំណួររបស់ខ្ញុំហ្នឹង គឺថាបើកផ្លូវចំហរឲ្យសាក្សីគាត់អាចមានលទ្ធភាពពន្យល់បានតាមចិត្តគាត់។

[១០:១៩:២៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

ខ្ញុំនិយាយដោយសង្ខេប។ សូមអធ្យាស្រ័យមេធាវី យើងមិនមែនថាចង់ឲ្យសាក្សីយល់ខុសនោះទេ។ គឺលោកជាអ្នកលើកខុសទៅលើសក្ខីកម្ម។ លោកបានរៀបរាប់នៅក្នុងប្រតិចារឹកនោះ បើសិនជា

រៀបរាប់ទៅចំចំណុចនោះ គឺខ្ញុំមិនចាំបាច់លើកឡើងជំទាស់នោះឡើយ។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា និងសំអាងហេតុត្រឹមត្រូវ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរសួរដោយមេធាវីការពារក្ដីអម្បាញ់មិញនេះទេ!

[១០:២០:០០]

មេធាវីបើចង់តាំងសំណួរនេះ គឺរៀបចំសំណួរឲ្យបានត្រឹមត្រូវ ហើយចៀសវាងនូវការដកស្រង់យកមកតាំងសំណួរនូវចំណុចដែលពាក់ព័ន្ធគ្នា ហើយបំបាត់មួយកំណាត់ ហើយយកតែមួយកំណាត់មកធ្វើ ដូចជាករណីសួរអំពីចម្ងាយលើកមុនអ៊ីចឹង។ យាមឆ្ងាយប៉ុន្មានអ៊ីចឹង? យកដកស្រង់តែចំណុចឆ្ងាយទេ។ សូមលោករៀបរយឲ្យបានត្រឹមត្រូវ ដើម្បីជាប្រយោជន៍ក្នុងការស្វែងរកការពិត។ ហើយប្រសិនបើអាចធ្វើបាន លោកគប្បីធ្វើសំណួរខ្លីៗទៅបានហើយ កម្រិតយល់ដឹងប្រហែលជាអាចចាប់មិនបានទេ បើសិនជាលោកបែបសំណួរវែង ឬក៏ឲ្យចង់ធ្វើអត្ថាធិប្បាយបែបវែងនោះ។

**លោក អាកទូរ វែកគែន៖**

បាទជាបឋម ខ្ញុំមិនគិតថា ខ្ញុំនិយាយតែចម្ងាយអតិបរិមាទេ ខ្ញុំក៏និយាយថាចម្ងាយជិតដែរ គឺថាខ្ញុំនិយាយថា ពី១៦ ទៅ៦០ម៉ែត្រ។ ហើយចំណុចទី២ទាក់ទងទៅនឹងការកត់សម្គាល់របស់សហព្រះរាជអាជ្ញា ជាការពិតណាស់ដែលបញ្ហាដែលទាក់ទងថ្ងៃទី២៦ កក្កដា នោះ គឺថាទាក់ទងទៅនឹងតំបន់នេះដដែល ឬក៏ជុំវិញតំបន់នេះ គឺថានៅកំពង់ឆ្នាំង ឧដុង្គ តើលោកអាចជម្រាបបានទេថា មេដឹកនាំផ្សេងៗទៀតមានមន្ទីរឬក៏មូលដ្ឋានចន្លោះពីឆ្នាំ៧៣ ដល់៧៤ ហើយនិងដើមឆ្នាំ៧៥? លោកប្រធាន ខ្ញុំមិនដឹងពីស្មារតីតុលាការយ៉ាងម៉េចទេ គឺថាតើអាពាក្យដែលថា ដើមឆ្នាំ៧៥នោះមានន័យយ៉ាងម៉េច? ហើយបើចប់ត្រឹមណា? តើលោកប្រធានយល់ពាក្យថា ដើមឆ្នាំ៧៥ ហ្នឹងយ៉ាងម៉េច? ឬក៏វាអាចចំពោះថាខ្ញុំថា -- ចំពោះខ្ញុំ វា១ពាក្យនេះវាទូលាយ។ អ៊ីចឹងហើយបានខ្ញុំចោទសួរគាត់ថា ចម្លើយដែលគាត់ឆ្លើយនៅសប្ដាហ៍មុននោះ ទាក់ទងនឹងកន្លែង សុន សេន មានមន្ទីររបស់គាត់ គឺថាដើមឆ្នាំ១៩៧៥នោះ តើវាខុសពីកន្លែងដែលចម្លើយរបស់គាត់ហ្នឹងឬក៏អត់? ហើយគ្រាន់តែខ្ញុំចង់ដឹងថាវាមានភាពចម្រូងចម្រាសយ៉ាងម៉េច? អ៊ីចឹងហើយបានខ្ញុំសួរគាត់ហ្នឹង។

[១០:២២:៣៨]

**ប្រធានអង្គជំនុំ៖**

យើងឲ្យលោករៀបចំសំណួរ គ្រាន់ឲ្យសម្រួលសំណួរឲ្យងាយស្តាប់យល់។ បើស្តាប់សំណួរលោកយល់ ហើយនិងទំនងជាអាចឆ្លើយបាន។ បើសំណួរហ្នឹងវាពិបាកយល់ ប្រហែលជាឆ្លើយវាមិនបាន។ ធ្វើឲ្យអ្នកដែលឆ្លើយហ្នឹងអាចភ័ន្តច្រឡំ។ អ៊ីចឹងតម្លៃដែលវាមកបានមកហ្នឹង វាមិនមានប្រយោជន៍ក្នុងការស្វែងរកការពិត វាខាតពេលវេលាឥតប្រយោជន៍ក្នុងការដេញដោលនេះ។ យើងឲ្យលោកតាំងសំណួរឡើងវិញ ហើយឲ្យបានជាក់ច្បាស់ដើម្បីងាយយល់។ ទីពីរ ប្រសិនបើលោកផ្អែកលើឯកសារដែលជាប្រតិចារឹកមានរួចហើយ សូមលោកបង្ហាញអត្តសញ្ញាណឯកសារ និងដាក់បង្ហាញឯកសារនោះនៅលើអេក្រង់កុំព្យូទ័រ អេក្រង់ទូរទស្សន៍ដើម្បីឲ្យភាគីពាក់ព័ន្ធ អង្គជំនុំជម្រះនិងសាធារណជនបានឃើញផង ដើម្បីឲ្យបានដឹងច្បាស់ពីពាក្យពេចន៍ដែលប្រើប្រាស់ក្នុងការតាំងសំណួរនេះ។

[១០:២៣:៥៣]

**លោក អាកឡូវ វែកគែន៖**

បាទ ឥឡូវខ្ញុំព្យាយាម។

**សួរដោយលោក អាកឡូវ វែកគែន៖**

**ស៖** លោកសាក្សី តើ សុន សេន នៅវ៉ាស្នាច់ដល់ពេលណាលោកសាក្សី? តើជាវ៉ាស្នាច់នេះជាកន្លែងដែល សុន សេន ធ្វើការនោះ?

**លោក វ៉ាចាម តុន៖**

**ឆ៖** ត្រង់ចំណុចនេះ គឺសវនាការប៉ុន្មានថ្ងៃនេះ បានន័យថាលោកអត់យល់ទេ គឺថាភាសាខ្មែរគេហៅចល័តនោះ។ ពាក្យថាចល័តហ្នឹង គឺថាវ៉ាស្នាច់ឲ្យគេនៅ។ ស្តុកតោលគេនៅ។ បាត់កូនក៏គេនៅ។ ហើយបើល្អិតច្រើន យ៉ាងច្រើនទៀត ព្រោះកន្លែងសមរភូមិ វាចល័តច្រើនណាស់មួយថ្ងៃ មិនអាចរាប់អស់ទេ។ ប៉ុល ពត នោះក៏យ៉ាងដូច្នេះដែរ ក៏ចល័តដែរ។ ជិតសមរភូមិ នរណាទៅនៅត្រាំត្រែងហ្នឹងមួយកន្លែងៗហ្នឹងវាចល័ត។

[១០:២៥:០៣]

ហ្នឹងភាសាខ្មែរយើង ពាក្យដែល “ចល័ត” ហ្នឹងវាច្រើនកន្លែងណាស់ៗ។ ហើយចុចៗអំមិញហ្នឹងគឺថា យើងយកតែគោលដៅៗអ៊ីចឹងទេ យើងមិនបានលម្អិតគ្រប់ជ្រុងគ្រប់ជ្រោយអស់រលីងហ្នឹងទេអត់ទេ ពាក្យ “ចល័ត” នោះ អ៊ីចឹង។

**ស៖** ដូច្នេះ សុន សេន មិនមានទីបញ្ជាការជាក់លាក់ណាមួយទេ នៅក្នុងការវាយប្រហារយកទីក្រុងភ្នំពេញ តើអ៊ីចឹងមែនទេ អ្វីដែលលោកនិយាយនេះ?

**ឆ៖** សំណួរលោកសួរនោះ បើខ្ញុំផ្ទាល់យល់ណា៎ បើថា សុន សេន អត់មានទីបញ្ជាការច្បាស់លាស់នោះ អត់មានបានរំដោះភ្នំពេញទេ។ អាហ្នឹងខ្ញុំបកស្រាយទៅអ៊ីចឹងវិញ។ វាមានទីបញ្ជាការរបស់វាច្បាស់លាស់ហើយ វាចល័តបានហើយ បានវារស់រានមានជីវិត បានបញ្ជាសមរភូមិនឹងបានវាឈ្នះអ៊ីចឹង។

[១០:២៦:៣៧]

**ស៖** បាទ ឥឡូវយើងត្រឡប់មកនិយាយអំពីកិច្ចប្រជុំដើមខែមេសា ដែលលោកថា ក្នុងកិច្ចប្រជុំនោះមានការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅពេលដែលដណ្ដើមទីក្រុងភ្នំពេញបាននៅ -- អ្នកដែលចូលរួមកិច្ចប្រជុំហ្នឹង តើក្រោយមកមានបរិភោគអាហារជាមួយគ្នាដែរឬទេ?

**ឆ៖** ចំណុចនេះ ខ្ញុំសូមថា ខ្ញុំឈប់ឆ្លើយហើយ។ វាច្រើនបែបច្រើនយ៉ាងណាស់ បានហើយប៉ុណ្ណឹង។

**ស៖** លោកបាននិយាយថា នៅមន្ទីរនោះលោកមានតួនាទីខាងភស្តុភារ ខាងចង្ក្រានបាយ។ អ៊ីចឹងខ្ញុំគិតថា ប្រហែលជាលោកអាចឆ្លើយតបនឹងសំណួរនេះបាន ដែលថា ពេលគេប្រជុំចប់នោះតើគេបរិភោគអាហារជាមួយគ្នាដែរឬអត់?

[១០:២៨:០៣]

**ឆ៖** ប្រជុំចប់ហើយ ហូបបាយចប់ហើយបែកគ្នា។

**ស៖** នៅចំពោះមុខតុលាការនេះ លោកបានឆ្លើយថា កិច្ចប្រជុំនេះគឺថា ដើមខែមេសា ឆ្នាំ១៩៧៥ នេះ នៅ -- និយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយបានប្រព្រឹត្តទៅ ខ្ញុំដកស្រង់៖ "នៅក្នុងព្រៃ ហើយនៅក្នុងក្រោមដំបូលដែលអត់មានជញ្ជាំង" ហើយគឺថា -- ជាពង្រាងប្រតិចារិកថ្ងៃទី២៦ កក្កដា ឆ្នាំ២០១២ ម៉ោង១០:០០:១១វិនាទី បន្ទាប់មកទៀត ជាភាសាបារាំងមានចម្លើយដែលខ្ញុំសូមបំភ្លឺពីលោក ពីព្រោះថាពេលនោះ គេសួរថា៖ "លោកឈរនៅកន្លែងណាធៀបទៅនឹងកន្លែងប្រជុំ?" លោក ឆ្លើយថា បកប្រែជាភាសាបារាំងទេ ថា "ចន្លោះពីខ្ញុំ និងកន្លែងប្រជុំនោះ មានកូនដំបូកមួយ"។ តើលោក អាចបំភ្លឺបានទេ ព្រោះថាប្រើពាក្យថា "កូនដំបូក, កូនភ្នំ" នេះ តើលោកបំភ្លឺចំណុចហ្នឹងបន្តិចបានទេ?

[១០:២៩:៤៥]

**ឆ៖** កូនដំបូកហ្នឹង ខ្ញុំមិនដឹងថា ខ្មែរយើងបកប្រែទៅបារាំងហ្នឹងវាអាម៉េច ខ្ញុំមិនដឹងទេ កូនដំបូកៗហ្នឹងហើយ។ មិនដឹងបកប្រែអាម៉េចទៀត ខ្ញុំមិនដឹងថា ម៉េចទៀតខ្មែរ។

**ស៖** បាទ លោកនិយាយអ្វីតាមចិត្តលោកចង់ទៅ លោកសាក្សី។ តើដំបូកហ្នឹងមានកម្ពស់ប៉ុន្មានដែរលោកសាក្សី?

**ឆ៖** ភាសាខ្មែរ គេថា គ្រាន់តែគុម្ពោតបន្តិចទៅ គេហៅដំបូកដែរ វាកូនដំបូក វាមានមេដំបូក។ កន្លែងហ្នឹង វាកូនដំបូកទេ។ វាកម្ពស់ហ្នឹង ប៉ុន្មានប្រហែលជាមួយម៉ែត្រជាងហ្នឹង។

[១០:៣១:០០]

**ស៖** លោកពួននៅក្រោយដំបូកហ្នឹង ពេលដែលគេកំពុងប្រជុំនោះ ឬយ៉ាងម៉េច?

**ឆ៖** ទេបើចំណុចនេះ បើអស់លោកមិនយល់ប្រហែលឈប់ត្រឹមហ្នឹងទៅ ខ្ញុំក៏មិនឆ្លើយអីទៀតដែរ។ ដឹងឆ្លើយអាម៉េចទៀត។ ដំបូកលិច ដំបូកកើតម៉េចទេ អត់យល់ទេខ្ញុំ។ បើភាសាខ្មែរ អាហ្នឹងដូចវាគ្មានអីអស្ចារ្យទេ ដំបូកហ្នឹង ដោយលោកបារាំងលោកមិនយល់ អាភាសាខ្មែរនេះ មិនដឹងខ្ញុំបកប្រែទៅបារាំងអាម៉េច ខ្ញុំមិនយល់ទេ។

**ប្រធានអង្គជំនុំ៖**

បាទឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយលោកសាក្សីសម្រួលអារម្មណ៍បន្តិចទៅ នេះជានីតិវិធីនៃការសួរដេញដោលតាមផ្លូវតុលាការ។ អាចមានបញ្ហាប្រឈមខ្លះហើយ លើបញ្ហាសតិអារម្មណ៍ ពីព្រោះគេហៅនីតិវិធីដេញដោល ឬក៏ឈ្លោចសួរចម្លើយ នេះគឺគេអនុវត្តនៅក្នុងផ្លូវតុលាការ។ អាចមានបញ្ហាប្រឈម លោកអាចឆ្លើយបាន លោកឆ្លើយ លោកឆ្លើយមិនបាន លោកមិនឆ្លើយទៅ ហើយឧទាហរណ៍ថា កម្ពស់ដំបូកប៉ុន្មាន លោកអាចឆ្លើយថា អាហ្នឹងលោកមិនដែរ ព្រោះមិនបានវាស់ផង មិនដឹងកម្ពស់ប៉ុន្មាន ព្រោះពាក្យថា “កម្ពស់” ទាល់តែច្បាស់លាស់។ អ៊ីចឹងហើយបានយើងប្រាប់លោកតាំងលោកតាំងពីដើម សូមឲ្យលោករៀបចំនូវការស្តាប់សំណួរឲ្យបាន លោកអាចឆ្លើយតបខ្លីៗឲ្យចំនឹងសំណួរ លើកលែងតែសំណួរនុ៎ងវាវែងឲ្យអត្ថាធិប្បាយ យើងធ្វើអត្ថាធិប្បាយ។ បើសិនជាឲ្យសួរបញ្ហាអី និយាយងាយពាក្យសាមញ្ញ ពាក្យខ្មែរគេហៅថា សួរអំពីបញ្ហាអី ឆ្លើយតបអំពីបញ្ហាហ្នឹង។ អ៊ីចឹង ធ្វើឲ្យអារម្មណ៍យើងហ្នឹង វាអាចធូរស្រាល

ពេលវេលាក៏បានឆាប់ដែរ។ អ៊ីចឹងបានជៀសវាងធ្វើអត្ថាធិប្បាយ ដែលហួសពីគោលបំណងនៃការតាំងសំណួរ។

[១០:៣៣:១១]

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលកន្លែងសម្រាកក្នុងអំឡុងពេលឈប់សម្រាកដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៤ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះសូមប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី រ៉ែចាម តុន ជាបន្ត។

ហើយលោកសាក្សី សូមលោករៀបចំនូវ ពង្រឹងនូវអារម្មណ៍របស់លោកឲ្យនឹងនរ ហើយឆ្លើយតបទៅនឹងសំណួរដែលសួរ។ លោកស្តាប់សំណួរឲ្យបាន ហើយបើស្តាប់មិនបានទេ មិនយល់សំណួរទេ សូមលោកសុំឲ្យអ្នកតាំងសំណួរហ្នឹង សួរលោកម្តងទៀត ដើម្បីឲ្យច្បាស់ សូមឆ្លើយ។ ហើយពេលវេលាមិនយូរទេ មិនអាចលើសពីមួយម៉ោង គឺយ៉ាងយូរ អតិបរមា គឺម៉ោងដប់ពីរ ដំណើរការសវនាការនេះ ក្នុងការសួរដេញដោលលោកហ្នឹងនឹងចប់ហើយ។

ហើយអង្គជំនុំជម្រះអរគុណណាស់ ដែលថាលោកបានប្រឹងប្រែងខិតខំ ផ្តល់សក្ខីកម្មក្នុងអំឡុងពេលប៉ុន្មានថ្ងៃកន្លងមកនេះ។ ឃើញថាស្ថានការណ៍វា សំណួរចំពោះលោកហ្នឹង វាច្រើនសំណួរពេក វាច្រើនអាចមានការប៉ះពាល់នូវផ្នែកផ្លូវចិត្តខ្លះហើយ។ ប៉ុន្តែអង្គជំនុំជម្រះសង្ឃឹមថា លោកពង្រឹងនូវ

ស្មារតីនិងអារម្មណ៍របស់លោក ដើម្បីឲ្យល្អៗឡើងវិញ ដើម្បីឆ្លើយតបនាពេលចុងក្រោយនៃការផ្តល់សក្ខីកម្មរបស់លោកនេះឲ្យបានល្អ ដូចអ្វីដែលលោកបានធ្វើពីដើមដំបូង។

សូមអញ្ជើញ!

[១០:៥៣:៥៥]

**លោក អាកទួរ វែកកែន៖**

សូមអរគុណច្រើនណាស់លោកប្រធាន។ ប៉ុន្តែជាព័ត៌មាន ខ្ញុំគិតថា ដោយសារតែខ្ញុំនិយាយយឺតៗនោះ គឺខ្ញុំគិតថា ខ្ញុំនឹងបញ្ចប់រហូតដល់ពេលថ្ងៃត្រង់តែម្តង។ សូមទោស លោកប្រធាន គឺខ្ញុំត្រូវតែធ្វើម៉េច ប្រហែលជាអាចចូលទៅដល់រសៀលទៀត។ សូមទោស អម្បាញ់មិញនេះ ពីព្រោះថាដោយសារតែមានភាពយឺតយ៉ាវនៅក្នុងសួរសំណួរនោះ។ បើសិនជាត្រឹមតែព្រឹកនេះ ខ្ញុំមិនអាចសួរចប់ទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកសួរទៅដល់រសៀលទេ។ ត្រឹមអាហារថ្ងៃត្រង់ប៉ុណ្ណោះ ព្រោះលោកមានតាំងសំណួរច្រំដែលច្រើនណាស់នៅព្រឹកនេះ។

**លោក អាកទួរ វែកកែន៖**

លោកប្រធាន យើងមានរយៈពេលពីរថ្ងៃកន្លះសម្រាប់មេធាវីការពារក្តីទាំងអស់ ហើយប្រសិនបើយើងដកពេល ពេលដែលមានការសួររបស់លោកចៅក្រម ឡាវែន៍ ហើយមានការកាត់ចុះឡើងៗនោះ ខ្ញុំគណនាមើលទៅ គឺថាខ្ញុំអាចសួរសំណួរដល់សាក្សីនេះ រហូតដល់ពេលរសៀលទៀត។ លោកប្រធាន ខ្ញុំពិតជាត្រូវការពេលរសៀល។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតតែថ្ងៃ តែត្រឹមថ្ងៃម៉ោងដប់ពីរទេ។ លោកប្រឹងប្រែងតាំងសំណួរទៅ ចំណាយពេលវេលាអត់ប្រយោជន៍។

[១០:៥៥:៣៩]

**លោក អាកទួរ វែកកែន៖**

លោកប្រធាន នេះជាការរំលោភទៅលើសិទ្ធិរបស់មេធាវីការពារក្តីហើយ លោកប្រធាន លោកមិនអាចធ្វើដូច្នេះបានទេ។ លោកប្រធានកំពុងតែដាក់ទណ្ឌកម្មចំពោះមេធាវីហើយ។ លោកសាក្សីនេះ

គាត់ផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន ជាច្រើនណាស់។ ដូច្នេះ ខ្ញុំត្រូវការពេលវេលាបន្ថែម ដើម្បីនិយាយ ហើយពួកយើងគោរពទៅតាមពេលវេលាដែលបានចែងចែកដោយអង្គជំនុំជម្រះរួចហើយ គឺយើងប្រើរយៈពេល -- គឺខាង នួន ជា ក៏គាត់បានគោរពតាមពេលវេលារបស់គាត់ ហើយមានសល់ពេលមួយថ្ងៃសម្រាប់មេធាវីការពារក្តីលោក កាណាវាស នោះ។ ហើយអ៊ីចឹង ខ្ញុំគិតថា ខ្ញុំក៏ត្រូវការពេលដូចអ្នកផ្សេងដែរ គឺថាយើងបានកំណត់ជាមុនរួចមកហើយ។ អង្គជំនុំជម្រះបានកំណត់ ប្រហែលជាលោកប្រធានមិនចាំពីអ្វីដែលយើងបានមានការផ្លាស់ប្តូរយោបល់គ្នារវាងមេធាវីការពារក្តី ហើយនិងអ្នកមន្ត្រីច្បាប់។ ខ្ញុំសូម--

[១០:៥៦:៣៦]

**ប្រធានអង្គជំនុំ៖**

យើងចាំច្បាស់ណាស់ យើងសម្រេចគ្រប់គ្រងកិច្ចដំណើរការសវនាការឲ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាន តាមលទ្ធភាពដែលយើងប្រឹងប្រែងធ្វើ។ លោកបន្តការតាំងសំណួរចាំបាច់ទៅ។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំសូមទទូច គឺថាជារឿងសំខាន់ណាស់--

**ប្រធានអង្គជំនុំ៖**

លោកបន្តការតាំងសំណួរចំពោះសាក្សីទៅ! ចាំយើងពិនិត្យមើល ថាតើសារៈសំខាន់យ៉ាងដូចម្តេចខ្លះ នៅពេលដែលលោកតាំងសំណួរនេះ? វាចាំបាច់យ៉ាងម៉េចខ្លះ? ហើយលោកត្រូវការពេលវេលាប៉ុន្មាន នាពេលម៉ោងចុងក្រោយ?

[១០:៥៧:៣៤]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកសាក្សី តើមានចម្ងាយប៉ុន្មានពីកន្លែងប្រជុំ ហើយនិងដំបូក ដែលលោកបាននិយាយមុនពេលឈប់សម្រាកអម្បាញ់មិញនេះ?

**លោក វ៉ាចាម គុន៖**

**ឆ៖** អត់បានវាស់ទេ អត់ដឹងទេ។

**ស៖** តើលោកនៅជិតដំបូកនោះ ពេញម៉ាពេលប្រជុំតែម្តង ឬក៏យ៉ាងណា?

**ឆ៖** នៅពេញម៉ាពេលប្រជុំហ្នឹង។

**សរ** តើដំបូកនោះ មានទំហំធំ ដែលអាចឲ្យលោកលាក់ខ្លួននៅខាងក្រោយនោះបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:៥៨:៤៦]

**លោក ខេល លីសាក់៖**

ខ្ញុំសូមជំទាស់ សំណួរនេះ គឺថាសំណួរនេះ គឺថាច្រើនដង ហើយថាហេតុអីបានជាសាក្សីបានលាក់ខ្លួននៅខាងក្រោយ។ គាត់បានឆ្លើយ។ ហើយមេធាវីសួរ ហើយសូមកុំអនុញ្ញាតឲ្យមេធាវីការពារសួរសំណួរដដែលៗនេះ គឺមិនស្របទេ លោកប្រធាន។

**លោក អាកទូរ វែកគែន៖**

លោកប្រធាន មិនត្រូវទេ ខ្ញុំមិនដែលបានសួរសំណួរបែបនេះទេ។ ការជំទាស់នេះ មិនត្រឹមត្រូវទេ គឺថាគ្រាន់តែធ្វើឲ្យខ្ញុំខាតពេលតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុរបស់នៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ត្រឹមត្រូវ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។ សាក្សីមិនដែលបានឆ្លើយថា ខ្លួនបានពួននៅក្បែរដំបូកនោះទេ។

[១០:៥៩:៤៦]

**សួរដោយលោក អាកទូរ វែកគែន៖**

**សរ** លោកសាក្សីនៅក្នុងកំណត់ហេតុទីពីររបស់លោក ថ្ងៃ២១ ខែកញ្ញា ឆ្នាំ២០០៨។ លោកមិនបាននិយាយអំពីដំបូកដែលថាលោកនៅយាមជិតហ្នឹងក្នុងពេលប្រជុំដូចដែលលោកបានឆ្លើយនេះទេ ក៏ប៉ុន្តែផ្ទុយទៅវិញនោះ លោកនិយាយអំពីជញ្ជាំងមួយដែលធ្វើពីស្លឹក។ ខ្ញុំនឹងប្រើប្រតិចារឹកនៃខ្សែអាត់ ពីព្រោះថានៅក្នុងខ្សែអាត់នោះមានបង្ហាញអំពីពាក្យរបស់លោកច្បាស់លាស់គឺនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៨។ កិច្ចសម្ភាសន៍លើកទីពីរ។ គឺឯកសារលេខ D107/3.1។ ERN ជាភាសាបារាំង 00825629, ERN ជាភាសាខ្មែរ 00754368, ERN ជាភាសាអង់គ្លេស 00826385។ លោកបានសម្ភាស យើងនឹងបង្ហាញឯកសារនេះនៅលើអេក្រង់។

**លោក អាកឡូវ វែកគែន៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់ជាភាសាខ្មែរ ដើម្បីឲ្យលោកប្រធានអាចពិគ្រោះបានផង ហើយខ្ញុំអាចមានជាក្រដាសជូនទៅសាក្សីផងដែរ ប្រសិនបើគាត់ចង់អាន។

[១១:០១:២៧]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីយកទៅជូនសាក្សីពិនិត្យ!

**លោក អាកឡូវ វែកគែន៖**

សូមអរគុណលោកប្រធាន។

**លោក អាកឡូវ វែកគែន៖**

**ស៖** នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៨ លោកបានឆ្លើយថា ខ្ញុំសូមដកស្រង់ "កិច្ចប្រជុំរៀបចំឡើងនៅក្នុងផ្ទះឈើដែលមានដំបូលប្រក់ស្លឹក មានទំហំប្រហែលបួនគុណនឹងប្រាំម៉ែត្រ ជារោងធម្មតាជញ្ជាំងស្លឹក។ ខ្ញុំបានឈរជាប់នឹងជញ្ជាំង ហើយខ្ញុំអាចមើលឃើញ និងស្តាប់អ្វីៗបានទាំងអស់"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះសំណួរខ្ញុំសាមញ្ញទេ លោកសាក្សី។ តើចម្លើយមួយណាដែលជាចម្លើយត្រឹមត្រូវនោះ? ចម្លើយដែលលោកបានឆ្លើយនៅឆ្នាំ២០០៨ ដែលលោកបានឆ្លើយថា លោកអាចស្តាប់ឮអំពីសម្តីដែលគេបាននិយាយក្នុងប្រជុំ ពីព្រោះថាលោកនៅឈរជាប់នឹងជញ្ជាំង កន្លែងដែលប្រជុំនោះ។ ហើយនិងចម្លើយដែលឆ្លើយនៅទីនេះ ដែលលោកបានពន្យល់ថាលោកនៅជិតដំបូកទៅវិញនោះ។ អ៊ីចឹងតើចម្លើយមួយណាដែលត្រឹមត្រូវនោះ?

[១១:០៣:០៦]

**លោក វ៉ាចាម គុន៖**

**ឆ៖** យកចម្លើយជាប់ជញ្ជាំងហ្នឹងទៅ។

**ស៖** ដូច្នេះ មានន័យថាចម្លើយដែលបង្ហាញនេះលើអេក្រង់នេះ គឺជាចម្លើយដែលលោកបានពន្យល់ថាលោកបានស្តាប់ឮខ្លឹមសារនៃកិច្ចប្រជុំ ពីព្រោះថាលោកឈរជាប់នឹងជញ្ជាំងស្លឹក។ តើលោកចង់មានន័យអ៊ីចឹងទេ? លោកយកចម្លើយនេះមែនទេ?

**ឆ៖** យកចម្លើយហ្នឹងហើយ។

**ស៖** ដូច្នេះ ឥឡូវនេះ ខ្ញុំចង់បង្ហាញជូននូវចម្លើយដែលលោកបានឆ្លើយទៅនឹងសំណួរ ឲ្យលោក

រៀបរាប់អំពីកន្លែង គឺក្នុងសវនាការនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ គឺនៅទំព័រទី២២ នៃសេចក្ដីព្រាងប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា គឺក្រោយម៉ោងដប់មួយ។ គឺសូមទោស ក្រោយម៉ោង១០:១១ ហើយ ERN គឺ 00828349 គឺឯកសារលេខ E1/97.1។

**លោក អាកទួរ វែកគែន៖**

ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានបង្ហាញឯកសារនេះ ពីព្រោះយើងមានជាភាសាខ្មែរ។

[១១:០៤:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកជូនសាក្សីពិនិត្យ!

**សួរដោយលោក អាកទួរ វែកគែន៖**

បាទលោកប្រធាន ឥឡូវនេះឯកសារនេះនៅលើអេក្រង់រួចទៅហើយ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកសាក្សី គឺមានបង្ហាញជូននៅលើអេក្រង់ហើយ។ កាលពីថ្ងៃទី២៦ ខែកក្កដា លោកបានឆ្លើយទៅនឹងសំណួរដែលគេសួរថា៖ "ដើម្បីឲ្យយល់បន្ថែមនោះ តើកន្លែងប្រជុំនោះជាកន្លែងមួយដែលមានអគារ មានជញ្ជាំងជុំវិញដែរឬទេ? តើគេប្រជុំហ្នឹងនៅត្តុំកន្លែងណាដែរ?" ហើយលោកបានឆ្លើយថា៖ "ដូចខ្ញុំបញ្ជាក់បន្តបន្ទាប់មកហើយ កន្លែងហ្នឹងអត់មានផ្ទះទេ អត់មានជញ្ជាំងទេ គឺនៅកណ្ដាលវាល គ្រាន់តែប្រក់ទៅលើឲ្យម្លប់អីអ៊ីចឹង ហើយល្អល្មេរ វាលស្រែជុំវិញនោះ"។ ហើយអម្បាញ់មិញនេះ លោកទើបតែបញ្ជាក់ថា ចម្លើយដែលត្រឹមត្រូវនោះ គឺចម្លើយឆ្លើយនៅ ទៅសហចៅក្រមស៊ើបអង្កេត នៅឆ្នាំ២០០៨ គឺលោកឆ្លើយថា៖ "លោកបានស្ដាប់ឮពីអ្វីដែលគេនិយាយនៅក្នុងកិច្ចប្រជុំពីព្រោះថាលោក១ឈរនៅជាប់នឹងជញ្ជាំងធ្វើពីស្លឹក។ បន្ទាប់មកទៀតនៅថ្ងៃទី២៦ ខែកក្កដា នៅក្នុងសវនាការដែលនៅពេលដែលគេឲ្យលោករៀបរាប់អំពីកន្លែងដដែលនេះ គេសួរលោកច្បាស់ណាស់ថា មានជញ្ជាំងឬក៏មានអីអត់? លោកឆ្លើយថា អត់មានជញ្ជាំង អត់មានអីទេ គឺនៅកណ្ដាលវាល។ ដូច្នេះ ឥឡូវនេះ ចម្លើយដែលត្រឹមត្រូវនោះមួយណាទៅលោកសាក្សី?

[១១:០៧:៤០]

**លោក វ៉ាចាម តុន៖**

**ឆ៖** ស្រេចតែលោកទៅ លោកចង់បានចំណុចណាស្រេចតែលោកយកខ្លួនឯងទៅអានោះ។

**ស៖** នេះជាចម្លើយហើយរបស់លោកសាក្សីមែនទេ ខ្ញុំមិនដឹងថាតើខ្ញុំត្រូវអត្ថាធិប្បាយអ្វីចំពោះចម្លើយនេះទេ។ ដូច្នេះខ្ញុំសូមបន្តទៅទៀត។ នៅក្នុងសវនាការនេះលោកបានឆ្លើយថា កិច្ចប្រជុំនោះបានប្រព្រឹត្តទៅយ៉ាងតិចណាស់ក៏បីម៉ោងកន្លះ ឬក៏បីទៅបួនម៉ោង។ តើលោកអាចបញ្ជាក់អំពីរយៈពេលពិតប្រាកដនៃកិច្ចប្រជុំនេះបានទេ ប៉ុន្មាន បីឬក៏បួនម៉ោង?

**ឆ៖** បញ្ជាក់ តែមួយព្រឹកហ្នឹង។

[១១:០៩:០៣]

**ស៖** ហើយនៅក្នុងពេលប្រជុំនោះគឺលោកអាចនៅជិត ហើយអាចស្តាប់ឮអ្វីៗទាំងអស់នៅក្នុងកិច្ចប្រជុំនោះ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** នៅក្នុងសវនាការនេះលោកបាននិយាយផងដែរ អំពីក្តារខៀនពណ៌ខ្មៅ ហើយលោកបាននិយាយថាមានការសរសេរនៅលើក្តារខៀនពណ៌ខ្មៅនោះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** អ្វីដែលគេសរសេរនៅលើក្តារខៀននោះ គឺជារូបគំនូរ ឬក៏គេសរសេរជាឃ្លាអីដើម្បីពន្យល់?

**ឆ៖** គូសវាសជាព្រួញទេ មិនមានអក្សរ មិនមានអីទេ គូសវាសជាព្រួញៗទៅចេញ។ មុខសញ្ញាណាចេញទៅណាៗ អ៊ីចឹងទៅ អ៊ីចឹង។

**ស៖** នៅពេលដែលលោកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការនេះ លោកបានផ្តល់បញ្ជីឈ្មោះបញ្ជាការ មេបញ្ជាការរងដែលបានចូលរួមនៅក្នុងកិច្ចប្រជុំ ពាក់ព័ន្ធទៅនឹងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ឧទាហរណ៍លោកបានប្រាប់ថាមានឈ្មោះ វន វ៉េត ហើយមានអនុប្រធានរបស់គាត់ គឺចេន អន ឬក៏ កុយ ធួន ហើយនិងអនុរបស់គាត់គឺ កែ ពក។ លោកបាននិយាយអំពី តាម៉ុក ហើយនិងសុន សេន ផងដែរ។ គឺនៅទំព័រ១៣ នៃសេចក្តីព្រាងប្រតិចារឹកថ្ងៃទី២៦ ខែកក្កដា ក្រោយម៉ោង ៩:៤០នាទី។ សំណួររបស់ខ្ញុំ គឺដើមខែមេសា ឆ្នាំ៧៥ លោកបានឆ្លើយនៅក្នុងសវនាការនេះថា ការវាយប្រហារនោះ គឺថាមានយ៉ាងខ្លាំងដើម្បីយកទីក្រុងភ្នំពេញនេះ។ តើលោកអាចបញ្ជាក់បានទេ ថានៅពេលដែលមានការប្រមូលផ្តុំមេបញ្ជាការ មេបញ្ជាការរង មកកន្លែងជុំគ្នា កន្លែងតែមួយបែបនេះ? តើវាអាចចោទ

ជាបញ្ហាដែរឬទេ? ពីព្រោះថា ត្រូវហៅពួកគាត់ចេញមកពីសមរភូមិ ហើយមកប្រជុំមួយកន្លែងអ៊ីចឹង ពេលដែលកំពុងតែប្រយុទ្ធគ្នាខ្លាំងអ៊ីចឹង។ តើបើតាមន័យសន្តិសុខហ្នឹង តើអាចមានចោទជាបញ្ហាអីកើតឡើងទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សំណួរនេះនឹងនាំឲ្យសាក្សីធ្វើការសន្និដ្ឋាន។ សូមអរគុណលោកប្រធាន។

[១១:១២:៤៦]

**លោក អាកទួរ វែកកែន៖**

លោកប្រធាន ខ្ញុំមិនគិតថា សំណួរនេះនាំឲ្យមានការសន្និដ្ឋានទេ ពីព្រោះថា សាក្សីនេះគាត់ស្ថិតនៅក្នុងក្រុមកងការពារ។ ដូច្នេះ គាត់អាចដឹងអំពីការលំបាក គឺថានៅពេលដែលយើងកោះហៅមេបញ្ជាការ មេបញ្ជាការរង ដែលកំពុងវាយប្រយុទ្ធនៅសមរភូមិយ៉ាងខ្លាំងនោះ វាធ្វើឲ្យមានបង្កជាបញ្ហាហើយស្ថានភាពបែបនេះនុះ។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយនឹងសំណួរដែលនាំឲ្យលោកបញ្ចេញនូវមតិយោបល់ផ្ទាល់ខ្លួនរបស់លោកលើបញ្ហាអ្វីមួយទេ។ សាក្សីគ្មានករណីយកិច្ចធ្វើសេចក្ដីសន្និដ្ឋាន អំពីហេតុការណ៍ ព្រឹត្តិហេតុណាមួយដែលកើតមានឡើងនោះទេ។

[១១:១៣:៤៥]

**លោក អាកទួរ វែកកែន៖**

ខ្ញុំចង់សុំឲ្យមាន -- ខ្ញុំមិនចង់ឲ្យសាក្សីធ្វើការស្មាន ឬក៏សន្និដ្ឋានទេ ពីព្រោះខ្ញុំគ្រាន់តែចង់ឲ្យគាត់បញ្ជាក់ច្បាស់ ពីព្រោះគាត់ថា គាត់ទទួលបន្ទុកខាងសន្តិសុខ។ ដូច្នេះខ្ញុំ--

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរដែលសួរ ដែលមានអត្ថន័យឲ្យលោកផ្ដល់មតិយោបល់ជាសេចក្ដីសន្និដ្ឋានទេ ពីព្រោះសាក្សីគ្មានភារកិច្ចបញ្ចេញមតិយោបល់ជាសេចក្ដីសន្និដ្ឋានទេ។

**លោក អាកទូរ វែកកែន៖**

បាទ លោកប្រធាន ខ្ញុំឯកភាពចំពោះចំណុចនេះ។

**សួរដោយលោក អាកទូរ វែកកែន៖**

**ស៖** លោកសាក្សី សំណួរបន្តទៅទៀត។ យើងបាននិយាយរួចមកហើយ អំពីសៀវភៅរបស់លោក ហ្វីលីព ស្សូត ដែលគាត់បានជួបលោកប្អូនដង។ ខ្ញុំចង់សួរលោកថា នៅក្នុងពេលកិច្ចសម្ភាសន៍របស់លោក ជាមួយនឹង ហ្វីលីព ស្សូត នោះ តើគាត់មានសួរលោកអំពីបញ្ហានៃការប្រជុំដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត និងសវនាការនេះដែរឬទេ?

**ឆ៖** បើលោកឃើញកិច្ចសម្ភាសន៍គាត់ហ្នឹង ឃើញយ៉ាងម៉េច គឺវាអ៊ីចឹងហើយ។

**ស៖** ដូច្នេះ អ៊ីចឹងមានន័យថា បាទមែនទេ គឺថាលោកបាននិយាយជាមួយលោក ហ្វីលីព ស្សូត អំពីកិច្ចប្រជុំនៅមន្ទីរប-៥ នៅដើមខែមេសា ឆ្នាំ៧៥ គឺ "បាទ" មែនទេ?

[១១:១៥:៥២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា! សាក្សីកុំអាលទាន់ឆ្លើយ!

**លោក ខេល លីសាក់៖**

លោកប្រធាន សំណួរនេះគឺសំណួរនាំមុខទៅដល់សាក្សី។ ប្រសិនបើមេធាវីចង់មានអត្ថបទណាមួយចង់ឲ្យមើលនោះ គឺអាចធ្វើទៅបាន។ គឺយើងមិនត្រូវធ្វើយ៉ាងណាយល់ខុសទៅអ្វីដែលសាក្សីឆ្លើយនោះទេ។ ដូច្នេះការសួរសំណួរបែបនេះ គឺសំណួរនាំមុខ។

**លោក អាកទូរ វែកកែន៖**

ខ្ញុំគិតថា មិនមែនជាសំណួរនាំមុខទេ ខ្ញុំគ្រាន់តែសួរថា តើគាត់មានបានចាំទេ ថាគាត់បានពិភាក្សាអំពីកិច្ចប្រជុំនៅដើមខែមេសា ឆ្នាំ៧៥ នេះ ជាមួយលោក ហ្វីលីព ស្សូត នេះ។ តើគាត់មាននឹកឃើញទេ ថាគាត់បាននិយាយអំពីកិច្ចប្រជុំនេះជាមួយ ហ្វីលីព ស្សូត។ ដូច្នេះ គាត់អាចឆ្លើយថា ចាំ ឬក៏មិនចាំ។ ដូច្នេះមិនមានការនាំមុខអីទេលោកប្រធាន។

[១១:១៦:៥១]

**ប្រធានអង្គជំនុំ៖**

គាត់ឆ្លើយរួចហើយអំមិញ ថាលោកឃើញម៉េច យកតាមហ្នឹងទៅ។ ឆ្លើយរួចហើយ លោក

ស្តាប់មិនបាន ស្តាប់មិនយល់ អត់មានការបកប្រែ? មានការបកប្រែទេ? មេធាវីខ្មែរហ្នឹង គាត់ឆ្លើយនៅ?

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំស្តាប់ជាភាសាខ្មែរ ខ្ញុំអត់ស្តាប់ជាភាសាបារាំងទេ។ ដូច្នេះបើបកប្រែ ខ្ញុំម៉េច -- ខ្ញុំអត់អាចដឹងបាន។

**ប្រធានអង្គជំនុំ៖**

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**លោក គង់ សំអុន៖**

បាទ គាត់ឆ្លើយបែបដូចលោកប្រធានមានប្រសាសន៍អំមិញ ប៉ុន្តែវាអត់ចំនឹងសំណួរមែនទែន វារបៀបៗជាៗ គេហៅ វោហារសាស្ត្រ បាទ។

[១១:១៧:៤៧]

**ប្រធានអង្គជំនុំ៖**

ចម្លើយគាត់ឆ្លើយប៉ុណ្ណឹង។

**លោក អាកទូរ វែកគែន៖**

លោកប្រធាន បើអ៊ីចឹងខ្ញុំនឹងបន្តទៀតដោយមិនដឹងអំពីចម្លើយរបស់សាក្សី។ ខ្ញុំមិនដឹងថាគាត់ឆ្លើយយ៉ាងណាទេ--

**ប្រធានអង្គជំនុំ៖**

សូមអ្នកបកប្រែរៀបចំនូវការបកប្រែ លើកកម្ពស់គុណភាពឲ្យបានល្អ ហើយនិងបកប្រែយឺតៗឲ្យច្បាស់លាស់។ ឥឡូវនេះកិច្ចដំណើរការពិភាក្សាដេញដោលកំពុងប្រឈមខ្លាំង ហើយសាក្សីឆ្លើយរួចហើយ ហើយអ្នកដែលចង់បានចម្លើយហ្នឹងស្តាប់អត់ទាន់បានផង សួរសាថ្មីម្តងទៀតច្រំដែល សួរម្តងទៀតឆ្លើយខុសពីមុន នាំឲ្យជជីកសួរហ្នឹង គឺដដែលៗហ្នឹងអត់ទៅមុខទេ ហើយគាត់នឹងសុំពេលវេលាទៀត។

[១១:១៨:៥៣]

អញ្ជើញបន្ត សូមលោកមេធាវីរៀបចំសំណួរឲ្យបានងាយៗ ជាក់ច្បាស់ ខ្លី ដើម្បីឲ្យសាក្សីទទួលយល់អំពីគោលបំណងនៃការសួររបស់លោក ហើយនិងលោកអាចឆ្លើយតបបាន។ ពីព្រោះលោកដាក់បង្ហាញឯកសារ ទាញឯកសារមក ឯកសារហ្នឹងមិនមាននៅអេក្រង់ទេ ហើយប្រសិនបើមានឯកសារ

នោះជាភាសាបរទេសទៀត ដែលគាត់មិនបានឃើញ មិនបានដឹងទេ។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** ខ្ញុំចង់សួរទៅកាន់សាក្សី នៅពេលដែលលោកសម្ភាសជាមួយលោក ហ្វីលីព ស្សូត តើលោកមានបាននិយាយអំពីកិច្ចប្រជុំនៅដើមមេសា ៧៥ នៅមន្ទីរប-៥ អំពីការជម្លៀសប្រជាជនចេញទីក្រុងភ្នំពេញដែរឬទេ? គ្រាន់តែឆ្លើយទៅថា "បាននិយាយ" ឬក៏ "មិនបាន"?

**លោក វ៉ាចាម តុន៖**

**ឆ៖** ខ្ញុំបាននិយាយ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចង់ឲ្យលោកដឹងថា នៅក្នុងសៀវភៅរបស់គាត់ គាត់មិនបានយកសក្ខីកម្មរបស់លោកមកដាក់ទេ គាត់បានប្រាប់ថា នៅក្នុងកិច្ចប្រជុំដែលគេមានសម្រេចអំពីការជម្លៀសប្រជាជនទីក្រុងភ្នំពេញនេះ គឺថានៅឆ្នាំ៧៤ ទៅវិញទេ។ ខ្ញុំសូមផ្តល់នូវឯកសារយោង គឺលេខ E3/9 ERN ជាភាសាបារាំង 00639453, ERN ជាភាសាអង់គ្លេស 00306199។ សូមបញ្ជាក់ថា ឯកសារនេះមិនមានបកប្រែជាភាសាខ្មែរទេ។

[១១:២១:១៣]

លោកសាក្សីលោកបានជួបលោក ហ្វីលីព ស្សូត ប្អូនដង ហើយលោកបានពិភាក្សាជាមួយគាត់ច្បាស់ណាស់ អ៊ីចឹងតើលោកអាចមានគំនិតទេថា ហេតុអ្វីបានជាគាត់មិនយកសក្ខីកម្មរបស់លោកទៅសរសេរនៅក្នុងសៀវភៅគាត់ ហើយគាត់សរសេរចេញទៅផ្សេងទៅវិញនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! ចាំស្តាប់សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាជាមុនសិន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សំណួរសួរទៅកាន់សាក្សីគឺឲ្យសន្និដ្ឋាន និងផ្តល់ជាយោបល់។ មេធាវីគាត់បានបញ្ជាក់ហើយថា គាត់មិនមានពេលវេលាគ្រប់គ្រាន់ក៏ប៉ុន្តែនៅពេលនេះ គាត់បានស្នើសុំឲ្យសាក្សីនេះផ្តល់យោបល់ និងផ្តល់ជាគំនិតលើបញ្ហា ហ្វីលីព ស្សូត។ ដូច្នេះខ្ញុំសូមជំទាស់។

**លោក អាកឡូរ វែកគែន៖**

លោកប្រធាន គឺថា ការធ្វើនេះគឺថាគាត់ជំទាស់ គាត់រារាំងខ្ទាស់ខ្ញុំមិនឲ្យទៅមុខលឿនហើយ

ព្រោះខ្ញុំសួរនេះគឺចេញពីអ្វីដែលគាត់បានសម្ភាសជាមួយ ហ្វីលីព ស្សូត ទេ។ ខ្ញុំចង់ឲ្យគាត់ប្រាប់ថា ហេតុអីបានជាលោក ហ្វីលីព ស្សូត មិនយកសក្ខីកម្មគាត់ទៅសរសេរនៅក្នុងសៀវភៅទៅវិញនោះ? ប្រសិនបើគាត់មិនចាំទេ ថាគាត់មិនបានពិភាក្សាអីជាមួយ ហ្វីលីព ស្សូត ទេ មិនអីទេ យើងអាចបន្តទៅទៀតបាន យើងអាចរំលងចោលបាន។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់ របស់តំណាងសហព្រះរាជអាជ្ញាមានមូលហេតុត្រឹមត្រូវ។ សេចក្ដីជំទាស់មានប្រសិទ្ធភាព សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីអម្បាញ់មិញនេះទេ។

[១១:២២:៥៩]

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** ឥឡូវខ្ញុំសូមបន្តទៅមុខទៀត។ លោកសាក្សី ឥឡូវនេះ ខ្ញុំចង់និយាយអំពីកិច្ចប្រជុំដែលប្រព្រឹត្តទៅនៅស្ថានីយរថភ្លើងទីក្រុងភ្នំពេញ គឺនិងនៅអតីតក្រសួងពាណិជ្ជកម្ម ក្រោយពីការដួលរលំទីក្រុងភ្នំពេញ។ លោកបានឆ្លើយថា “នៅក្រោយពេលទីក្រុងភ្នំពេញដួលរលំ អ៊ំៗមួយចំនួនគឺថា ជួបជុំគ្នានៅស្ថានីយរថភ្លើង ហើយពួកគាត់នៅទីនោះប្រហែលជាសរុបទៅមួយសប្ដាហ៍ បន្ទាប់មកពួកគាត់ទៅនៅខាងអតីតក្រសួងពាណិជ្ជកម្មហ្នឹងអស់ពីរសប្ដាហ៍”។ រួចលោកឆ្លើយថា “នៅក្នុងកន្លែងទាំងពីរនេះ គឺស្ថានីយរថភ្លើងហើយនិងអតីតក្រសួងពាណិជ្ជកម្ម អ៊ំៗបានជួបនឹងយោធាជាច្រើន”។ គឺនៅទំព័រ៦៣ នៃសេចក្ដីព្រាងប្រតិចារឹក ចុះថ្ងៃទី២៦ ខែកក្កដា នៅប្រហែលជាម៉ោង ១៤:១៣។

[១១:២៤:០៣]

សំណួររបស់ខ្ញុំ នៅក្នុងស្ថានីយរថភ្លើងមានការប្រជុំ ដែលលោកបាននិយាយនៅក្នុងសវនាការនេះតើការប្រជុំហ្នឹងនៅក្នុងបន្ទប់រង់ចាំនៅជាន់ផ្ទាល់ដី ជាន់ក្រោម ឬក៏នៅជាន់ខាងលើ ឬក៏នៅខាងក្រៅស្ថានីយរថភ្លើង? តើកិច្ចប្រជុំហ្នឹងប្រព្រឹត្តទៅនៅឯណាទៅ?

**លោក វ៉ាចាម តុន៖**

**ឆ៖** ខ្ញុំបញ្ជាក់ហើយថា ប្រជុំនៅរ៉ាវទេះភ្លើង វាមាន -- កន្លែងរ៉ាវទេះភ្លើងវាមានកន្លែងស្ថានីយហ្នឹង អាផ្ទះខ្ពស់ហ្នឹងវាមានតែមួយហ្នឹង តែមួយប្រជុំត្រង់ហ្នឹង នៅលើកន្លែងមួយហ្នឹងហើយ។

**ស៖** ហើយនៅក្នុងផ្ទះហ្នឹង តើគេប្រជុំហ្នឹងនៅកន្លែងណាក្នុងផ្ទះហ្នឹង?

**ឆ៖** ផ្ទះហ្នឹងវាមានបន្ទប់ៗវាតើ។

**ស៖** ហើយនៅក្នុងបន្ទប់មួយណា បន្ទប់ៗហ្នឹង ដែលថា លោកថាបន្ទប់ៗហ្នឹង ដែលមានការប្រជុំរវាងអ៊ំៗ ហើយនិងយោធាជាច្រើននុ៎ង បន្ទប់ហ្នឹងបន្ទប់ណា?

[១១:២៦:០៦]

**ឆ៖** បើខ្ញុំឆ្លើយថា ក្នុងបន្ទប់ហើយ លោកថាសួរថាបន្ទប់ណា? ខ្ញុំមិនដឹងឆ្លើយថា ម៉េចទៀតអ៊ីចឹង។ នៅក្នុងបន្ទប់ហ្នឹងហើយ។

**ស៖** អ៊ីចឹងគឺថា លោកមិនដឹងលម្អិតមែនទេ ថានៅបន្ទប់ណាៗនោះ?

**ឆ៖** អាហ្នឹងស្រេចតែលោកទៅ លោកថាមិនល្អិត ក៏ស្រេចតែលោកទៅ។

**ស៖** ចុះលោកផ្ទាល់ដែលលោកយាមនៅក្នុងអគារ ឬក៏ខាងក្រៅអគារហ្នឹង?

**ឆ៖** កន្លែងនេះ ខ្ញុំបញ្ជាក់ថា ខ្ញុំយាមខាងក្រៅ ខាងក្រោមទេ។ ខ្ញុំឃើញគាត់ចេញចូល មេៗហ្នឹងចេញចូលធ្វើការខាងលើជាមួយគាត់។ ខ្ញុំថាអ៊ីចឹងតើ។

**ស៖** ដូច្នេះគឺមានន័យថា លោកមិនបានចូលរួមនៅក្នុងកិច្ចប្រជុំនេះទេ មែនទេ? លោកគ្រាន់តែយាមនៅខាងក្រៅទេមែនទេ?

**ឆ៖** បាទ។

**ស៖** ឥឡូវនេះ សូមនិយាយអំពីអតីតក្រសួងពាណិជ្ជកម្មវិញម្តង។ សំណួរដដែល នៅអតីតក្រសួងនេះ តើកិច្ចប្រជុំរវាងអ៊ំៗ ហើយនិងយោធា ជាច្រើននោះ ប្រព្រឹត្តទៅនៅក្នុង ឬក៏ខាងក្រៅអគារ?

**ឆ៖** ក្នុងអគារ វាមានបន្ទប់ធំមួយនៅហ្នឹង។

**ស៖** ហើយចុះលោក លោកយាមនៅខាងក្នុង ឬក៏ខាងក្រៅអគារ?

**ឆ៖** កន្លែងហ្នឹង ខ្ញុំមិនបានយាមទេ។ មានគេអ្នកផ្សេង គេយាម។

**ស៖** តើលោកមានបានចូលរួមនៅក្នុងកិច្ចប្រជុំដែលបានប្រព្រឹត្តទៅនៅក្នុងអតីតក្រសួងពាណិជ្ជកម្មនេះដែរឬទេ ក្នុងរយៈពេលពីរសប្តាហ៍ហ្នឹង?

**ឆ៖** អត់ទេ។ ខ្ញុំអត់បានចូលប្រជុំទេ។

[១១:៣០:០៤]

**ស៖** ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត។ ក្នុងសវនាការនេះ លោកបាននិយាយថា នៅពេលណាមួយនោះ ក្រោយពីវាយយកទីក្រុងភ្នំពេញបាន មេដឹកនាំនោះបានរើទៅ ពី ក-៣ ទៅ ក-១

គឺលោកបានឆ្លើយបែបនេះនៅក្នុងសវនាការនេះ។ គេបានសួរលោកថា "តើលោកចាំទេ ថានៅពេលណាដែលមេដឹកនាំទៅនៅ ក-១នោះ?"។ លោកឆ្លើយថា "បើតាមខ្ញុំចាំ គឺមានកន្លែងជាច្រើន មាន ក-៣ ហើយក្រោយមកពួកគាត់បានរើទៅនៅ ក-១ នៅចុងឆ្នាំ៧៥"។ សូមបញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំ គឺចង់ដឹងថា នៅពេលដែលលោកឆ្លើយថា មេដឹកនាំរើពី ក-៣ ទៅ ក-១ នៅចុងឆ្នាំ៧៥នោះ តើនៅពេលរើនោះ តើលោកមានឃើញលោក ខៀវ សំផន ទេ នៅពេលដែលរើពី ក-៣ ទៅ ក-១ នោះ?

**ផ៖** គាត់ទៅនៅជុំគ្នាទៅ។

**ស៖** តើការរើសទៅហ្នឹង រើរបៀបម៉េចដែរ គឺជាការរើមន្ទីរដែលចេញពី ក-៣ ទៅ ក-១ ឬក៏គ្រាន់តែជាការរើផ្ទះទេ ពី ក-៣ ទៅ ក-១? គ្រាន់តែរើផ្ទះទេ ឬក៏យ៉ាងម៉េច?

**ផ៖** មិនមែនរើផ្ទះទេ គឺម្តងគាត់ធ្វើការនៅ ក-៣។ ម្តងគាត់នៅ ក-១។ ចល័តចុះ ចល័តឡើងកន្លែងជាច្រើនទៀតនៅភ្នំពេញហ្នឹង មិនមែនមានប៉ុណ្ណឹងទេ។

[១១:៣២:២៣]

**ស** បាទ ដូច្នេះសក្ខីកម្មរបស់លោកនោះ គឺលោកចង់និយាយថា នៅពេលណាមួយ បន្ទាប់ពី ក-៣ នោះ ខៀវ សំផន មានមន្ទីរគាត់នៅ ក-១។ អ៊ីចឹងមែនទេ?

**ផ៖** អំមិញ ខ្ញុំប្រាប់ថា គាត់ទៅនៅជុំគ្នា គាត់នៅ ក-៣ ហ្នឹងក៏ជុំគ្នាដែរ។ គាត់ទៅនៅនុំង ក៏ជុំគ្នាដែរ។ គាត់ទៅនៅនុំងក៏ជុំគ្នាដែរ។ កន្លែងៗ គេចល័តតើ មិនមែនទៅរើផ្ទះ រើសម្បែងឯណា អត់ទេ។

**ស៖** បាទ ខ្ញុំមានអារម្មណ៍ថា លោកទើបតែនឹងប្តូរ ផ្លាស់ប្តូរកាលប្រវត្តិហើយនេះ។ ហើយនិងកន្លែងផ្លាស់ប្តូរ ពីព្រោះថានៅក្នុងការបកប្រែជាភាសាបារាំងហ្នឹង គឺថាមិនមែនជាការដូរទីកន្លែងពី ក-៣ ទៅ ក-១ ទេ ប៉ុន្តែទៅជា ក-១ ទៅ ក-៣ វិញ។ ហ្នឹងអ្វីលោក -- ជាអ្វីដែលលោកទើបតែនិយាយអំមិញហ្នឹង ឬក៏យ៉ាងម៉េច?

**ផ៖** អាហ្នឹងស្រេចតែលោកយល់ខ្លួនឯងអាម៉េច យល់អ៊ីចឹងទៅ។ បើខ្ញុំប្រាប់ថាកន្លែងចល័តហើយ លោកអត់យល់ហើយ។ អាហ្នឹង គឺថាលោកយល់ខ្លួនឯងអាម៉េច យល់អ៊ីចឹងទៅ!

[១១:៣៤:០៥]

**លោក អាកឡូវ វែកគែន៖**

លោកប្រធាន ខ្ញុំសូមឲ្យលោកប្រធានជួយអន្តរាគមន៍ ពីព្រោះថា ខ្ញុំមិនមានសិទ្ធិអំណាចអ្វីឲ្យសាក្សីឆ្លើយមកនឹងសំណួរខ្ញុំទេ។ ខ្ញុំសូមឲ្យលោកប្រធានជួយរំឭកគាត់ ព្រោះថាសុំឲ្យគាត់ឆ្លើយឲ្យ

ច្បាស់លាស់បន្តិចទៅនឹងសំណួរដែលគេចោទទៅគាត់នោះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយសាក្សី ដូចគ្នា សាក្សីគឺសុំរៀបចំនិងឆ្លើយតបទៅនឹងសំណួរ សំណួរដែលសួរ។

គ្រប់សំណួរដែលសួរ យើងបានប្រាប់តាំងពីដើមមក គឺថាកាតព្វកិច្ចរបស់សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលភាគីសួរ គ្រប់សំណួរទាំងអស់ តាមលទ្ធភាពនិងសមត្ថភាពដែលលោកខ្លួនបានដឹង បានឮ បានឃើញ ចងចាំ មានបទពិសោធន៍ឆ្លងកាត់ ឬក៏បានសង្កេត ឬកត់សម្គាល់ឃើញនៅក្នុងអំឡុងពេលដែលក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលពាក់ព័ន្ធទៅនឹងព្រឹត្តិហេតុ ឬហេតុការណ៍ដែលមាននៅក្នុងសំណួរ។

ហើយសាជាថ្មីម្តងទៀត សូមលោកមេធាវីក៏សម្រួលសំណួរឲ្យបានងាយៗដែរ អាចពី ក-៣ ទៅ ក-១។ ក-១ ទៅ ក-៣ ហ្នឹងអាចវាកើតមកពីបកប្រែ ឬក៏ជាការតាំងសំណួរដើមដំបូង វាយ៉ាងម៉េចបានជាអាចមានចម្លើយអ៊ីចេះ។ ទីពីរ ក៏សូមស្វែងយល់ដែរ អំពីពាក្យ "ចល័ត" នេះ។ ព្រោះដូចជាញឹកច្រើនដងហើយ ពីពាក្យ "ចល័ត" នេះ គឺថាការស្វែងយល់ហ្នឹង គឺជាការលំបាកមួយ។ ពាក្យ "ចល័ត" ដែលគេប្រើនៅក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យ។ វាពាក់ព័ន្ធជាមួយនឹងការសម្ងាត់ នៃអង្គការ គឺគេតែងតែធ្វើអ្វីជាសម្ងាត់និងចល័តជានិច្ច។ បញ្ហានេះ គឺកើតមានហើយនៅក្នុងសំណុំរឿង គឺមានអ្នកច្រើនរួចហើយ។

[១១:៣៦:១៤]

លោកតាំងសំណួរបន្ត លោកចាំថា សំណួរកាលណាសួររួច បើមានហេតុការណ៍អីកើតឡើងភ្លេចអស់ហើយ។ ម្យ៉ាងរឿងហេតុវាយូរ ម្យ៉ាងបកប្រែ ម្យ៉ាងវ័យគាត់ក៏ចំណាស់ហើយ ហុកសិបជាងហើយ។ លោកមានបំណងសួរអី លោកតាំងសំណួរ ដើម្បីលោកអាចមានឱកាសនៅក្នុងការអង្គជំនុំជម្រះពិចារណាអំពីផ្តល់ពេលវេលាឲ្យលោក ដែលលោកមានបំណងស្នើសុំ។ លោកមានបំណងស្នើសុំពេល ប៉ុន្តែការតាំងសំណួរ គឺអាចមានបញ្ហាមួយចំនួន។

**សួរដោយលោក អាកឡូវ វ៉ែកគែន៖**

**ស៖** លោកសាក្សី នៅពេលណានោះ បន្ទាប់ពីភ្នំពេញត្រូវបានផ្តួលរំលំ តើ ខៀវ សំផន មានមន្ទីរមួយ នៅក្នុងបរិវេណមន្ទីរ ក-១ នោះ។ តើមានទេ? គាត់មានទេ លោក ខៀវ សំផន?

**លោក វ៉ាចាម តុន៖**

**ឆ៖** ខ្ញុំក្តាប់អត់បានទេ ប៉ុន្តែខ្ញុំទៅឃើញហ្នឹងនៅជុំគ្នាទេ។ មន្ទីរដោយឡែក ដូចអត់មានទេ។

**ស៖** បាទ ឥឡូវខ្ញុំសូមបន្តទៅសំណួរមួយទៀត លោកសាក្សី។ នៅចំពោះមុខតុលាការនេះ លោកបានឆ្លើយថា ចាប់ពីខែឧសភា ឆ្នាំ១៩៧៥ គឺថាបន្ទាប់ពីវើបានភ្នំពេញហើយ លោកបានឈប់ធ្វើការជាកងការពារ ហើយលោកក៏បានលើកឡើងផងដែរ គឺថានៅពេលដំបូង ថាលោកទទួលបន្ទុកនៅជាមួយ អៀង សារី នោះ គ្រាន់ទទួលភ្ញៀវ គឺនៅទំព័រទី១២ នៃពង្រាងប្រតិចារិក។ សំណួរខ្ញុំដូចតទៅនេះ តើតួនាទីជានីរសាររបស់គាត់ -- របស់លោកដែលនៅក្នុងព្រៃនោះ វាក្លាយទៅជាយ៉ាងណា? ហើយលោកឈប់ធ្វើការជានីរសារហ្នឹង និងកងការពារនៅក្នុងពេលតែមួយហ្នឹង ឬក៏យ៉ាងម៉េច?

[១១:៣៨:៤៨]

**ឆ៖** សំណួរនេះ អត់យល់ទេ។ សូមតាំងម្តងទៀត។

**ស៖** តើចាប់ពីពេលណាដែលលោកបានឈប់ធ្វើការជានីរសារ?

**ឆ៖** ចំណុចនេះគឺថា ជាភាសាខ្មែរយើង គឺថាការទាក់ទងវាមានរហូត។ វានាំទៅនាំមក។ ដល់អ៊ីចឹង គឺថាលោកសួរថា ឈប់ពេលណា? គឺថាអត់មានពេលឈប់ទេ គឺថាក្នុងរយៈបីឆ្នាំ មានការទំនាក់ទំនងគ្នារហូតហ្នឹង។ គ្រាន់តែជិត គ្រាន់តែឆ្ងាយអ៊ីចឹង។ មុនឆ្ងាយ អានេះជិត អ៊ីចឹង។

**ស៖** សូមអរគុណ។ បើសិនជាខ្ញុំយល់មិនខុសទេ គឺនៅក្នុងចន្លោះពេលឆ្នាំ១៩៧៥ ដល់៧៩ នោះ លោកបំពេញបេសកកម្មសំខាន់ហ្នឹង គឺថា ដូចជាទទួលភ្ញៀវបរទេស ឬក៏ផ្គត់ផ្គង់អាហារដល់មន្ទីរ ប-១ ហើយនិងការគ្រប់គ្រងសតិអារម្មណ៍បុគ្គលិក១.០០០នាក់ ដែលលោកទទួលបន្ទុក ហើយនិងការទៅសិក្សានៅប្រទេសចិនទាក់ទងទេសចរណ៍ ដែលលោកបាននិយាយម្សិលមិញនេះ ហើយនិងបន្ថែមលើសហ្នឹងទៀត គឺថាលោកធ្វើការជាអ្នកបម្រើដូចជាអ្នកនាំសំបុត្រទៅឲ្យគេជាដើម។ តើនេះឬអ្វីដែលលោកចង់និយាយនោះ?

**ឆ៖** ខ្ញុំយល់សំណួរលោកអំមិញថា ពីរឿងដែលខ្ញុំនីរសារហ្នឹង បានខ្ញុំឆ្លើយថា រឿងនីរសារនេះ អត់មានឈប់ទេ គឺនៅធ្វើរហូតអ៊ីចឹង។ ព្រោះវាមានសារនាំទៅនាំមក។ វាមានការទំនាក់ទំនងទៅ អ្នកទំនាក់ទំនងមក។ អាហ្នឹងវាមានអ៊ីចឹង ការងារហ្នឹងក៏គេធ្វើដែរ។ ការងាររដ្ឋបាលក៏គេធ្វើដែរ។ ការងារទទួលភ្ញៀវក៏គេធ្វើដែរ។ ការងារស្អីដែលជុំវិញដែលថាក្នុងរង្វង់ខាងលើដែលប្រគល់ឲ្យហ្នឹងធ្វើទាំងអស់។

[១១:៤២:០៤]

**ស៖** នៅចំពោះមុខតុលាការនេះ តើក្នុងសវនាការប៉ុន្មានថ្ងៃនេះ លោកបានឆ្លើយថាលិខិតដែលបានឆ្លើយឆ្លងជាមួយ ខៀវ សំផន នឹងលោកនោះ គឺថាទាក់ទងទៅនឹងការទទួលភ្ញៀវ។ ខ្ញុំយោងទៅឯកសារ -- ទៅសវនាការថ្ងៃទី២៧ កក្កដា នៅទំព័រ៨៨ ជាភាសាបារាំង គឺជាបណ្ដោះអាសន្នទេ ហើយនៅម៉ោង ១៥ និង៣៤ សឺហ្គុង គឺទំព័រ៧៣, ថ្ងៃដដែលគឺថាម៉ោង ១៥:៤៩:៤១ ហើយនិងចម្លើយរបស់លោកនៅថ្ងៃទី៣០ នៅម៉ោង០៩:១២:៤៨។ តើលោកបញ្ជាក់បានទេថា នៅចន្លោះ៧៥ ដល់៧៩នោះ គឺថាលោកបានបញ្ជូនឯកសារទៅ -- សំបុត្រទៅលោក ខៀវ សំផន នោះ មានតែមួយគត់ គឺថាទាក់ទងទៅនឹងការទទួលភ្ញៀវបរទេសនៅប្រទេសកម្ពុជា។ លោកអាចបញ្ជាក់បានដែរឬទេ?

[១១:៤៣:២៨]

**ឆ៖** ចំពោះអ៊ំ ខៀវ សំផន ដូចថ្ងៃមុនខ្ញុំបានបញ្ជាក់ហើយថា គាត់ទើបកាន់ៗនាទីហ្នឹង គឺក្រោយពីបាត់ ឌឿន ទៅបានគាត់ឡើង។ ឡើងវាចុង៧៨ទៅហើយ អ៊ីចឹង។ ហ្នឹង ដូច្នេះ វាមិនមានអីច្រើនទេដែលថាមានទាក់ទងជាមួយគាត់ហ្នឹង។ ខ្ញុំចង់និយាយថា ការទាក់ទងហ្នឹងរវាងមន្ទីរ៨៧០ និងប-១។ រវាងខ្ញុំទៅគាត់នោះវាមានម្ដងម្កាលអីអ៊ីចឹងដែរ។ ការងារចាំបាច់អីវាមានការទាក់ទងគ្នាអ៊ីចឹង។

**ស៖** អរគុណ។ ហើយទាក់ទងទៅនឹងខ្លឹមសារ ហើយនិងកម្មវត្ថុនៃការទំនាក់ទំនងរវាងលោកជាមួយលោក ខៀវ សំផន នោះគឺទាក់ទងតែនឹងការទទួលភ្ញៀវបរទេសទេ ឬក៏យ៉ាងម៉េច?

[១១:៤៤:៣៤]

**ឆ៖** ខ្លឹមសារហ្នឹងគឺទាក់ទងនឹងការទទួលភ្ញៀវហ្នឹង ការនាំភ្ញៀវទៅតាមខេត្តហ្នឹងបាទ។

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ៧៥ ដល់ ៧៩ នោះតើលោកបានធ្វើការ ឬក៏សហការដោយផ្ទាល់ជាមួយលោក ខៀវ សំផន ពាក់ព័ន្ធនឹងបញ្ជាចាប់ខ្លួនមនុស្ស ឬក៏ការកម្ទេចមនុស្សដែរឬទេ?

**ឆ៖** អត់មានទេចំណុចនេះ អត់មានទេ។

**ស៖** នៅពេលដែលលោកនិយាយថា អៀង សារី បាននិយាយប្រាប់លោកអំពីការដែល ខៀវ សំផន បានបន្តតំណែងពី ឌឿន។ តើគាត់ចង់និយាយប្រាប់លោកថា ទាក់ទងទៅនឹងការទទួលភ្ញៀវ គឺ ខៀវ សំផន ជាអ្នកទទួលបន្ទុក ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:៤៦:១៤]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមជំទាស់ប្រយោគនេះជាសំណួរនាំមុខ ហើយនិងជាការដកស្រង់សម្ដីខុសរបស់ឆ្លើយសាក្សីពីខាងដើម បាទ។

**លោក អាកឡូវ វ៉េកគែន៖**

លោកសហព្រះរាជអាជ្ញា លោកអាចពន្យល់បានទេថា ខ្ញុំបំភ្លៃពាក្យពេចន៍របស់សាក្សីនេះកន្លែងណា? សូមបញ្ជាក់បន្តិចមើល៍?

**លោក ឌេល លីសាក់៖**

បើថា រយៈពេលរបស់លោកត្រូវប្រើ គឺថាសាក្សីបានធ្វើសក្ខីកម្មអំពីទំនាក់ទំនងរវាងលោក អៀង សារី ដែលលោកថា មន្ទីររបស់៨៧០ ហ្នឹង គឺថាទាក់ទងទៅនឹងករណីនេះ គឺថា ហើយលោកបានបន្ថែមព័ត៌មាននេះទៅឲ្យសាក្សី ហើយធ្វើឲ្យសំណួរនោះជាសំណួរនាំមុខ ហើយអាចនឹងធ្វើឲ្យចម្លើយខាងដើមរបស់សាក្សីនេះមានការភ័ន្តច្រឡំ។

[១១:៤៧:១៤]

**លោក អាកឡូវ វ៉េកគែន៖**

ខ្ញុំមិនបាននិយាយអ៊ីចឹងទេលោកប្រធានអំមិញ។ ឥឡូវបើថានេះ ខ្ញុំចោទសំណួរម្ដងទៀត រៀបពាក្យពេចន៍ថ្មីឡើងទៀត។ ខ្ញុំអាចធ្វើបានទេលោកប្រធាន?

**សួរដោយលោក អាកឡូវ វ៉េកគែន៖**

**ស៖** លោកសាក្សីចុងឆ្នាំ១៩៧៨ អៀង សារី បានប្រាប់លោកថា ចាប់ពីពេលនេះទៅគឺ ខៀវ សំផន ជាអ្នកទទួលបន្ទុក ទទួលមុខងារជំនួស ឌឿន។ តើគាត់បានបញ្ជាក់អំពីថា តួនាទីដែលគាត់និយាយនេះវាពាក់ព័ន្ធនឹងតួនាទីរបស់ ឌឿន ទាំងអស់ ឬក៏គាត់បានត្រឹមតែបញ្ជាក់ថា ដែលថាតួនាទីជំនួសនេះត្រឹមតែថាទទួលភ្ញៀវបរទេសនោះទេ?

**លោក រ៉ចាម តុន៖**

**ឆ៖** ចំណុចនេះ គឺថាពាក្យដែលទទួលបន្តពី ឌឿន តាមខ្ញុំយល់គាត់ទទួលខុសត្រូវទាំងអស់ហ្នឹងហើយ។ ប៉ុន្តែចំពោះថាខ្ញុំ ទាក់ទងទៅគាត់ ទាក់ទងដែលថា ត្រូវទៅទាក់ទងគាត់ហ្នឹង គឺទាក់ទងពីរឿងភ្ញៀវទេ អ៊ីចឹង។

[១១:៤៨:៥៧]

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណ ថាគាត់ឆ្លើយនឹងសំណួរខ្ញុំហើយលោកប្រធាន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** តើលោកស្គាល់ បងយ៉ែម ដែរឬទេ? ហើយបើលោកស្គាល់ហ្នឹង លោក យ៉ែម ហ្នឹងមានមុខងារអីដែរ?

[១១:៤៩:៤៤]

**លោក វ៉ាចាម តុន៖**

**ឆ៖** បងយ៉ែម នេះខ្ញុំស្គាល់ ព្រោះខ្ញុំស្គាល់ហ្នឹង ពី៦៧ ហ្នឹងគាត់ទៅបង្រៀនហ្នឹង គាត់ទៅរៀនហ្នឹងដែរ៦៧, ៦៧ហ្នឹង គាត់ទៅរតនគិរីដែរ។ ហើយក្រោយមកនេះ គាត់មកនៅលេខានៅក្រចេះ។ ដល់ក្រោយមកទៀត រំដោះនេះ គាត់មកក្រសួងការបរទេស ហើយក្រោយ គាត់ទៅធ្វើទូតនៅកូរ៉េ កូរ៉េខាងជើងនោះ។ ដល់ក្រោយពីគាត់មកពីហ្នឹងមក ឥឡូវគាត់ស្លាប់បាត់ទៅហើយ។

**ស៖** បាទសូមអរគុណ។ បាទ ខ្ញុំសូមចោទសំណួរសុំការបំភ្លឺមួយ លោកបានឆ្លើយថា នៅថ្ងៃទី ២៦ កក្កដា គឺថាក្នុងពង្រាងប្រិចារឹកមុនម៉ោង ១៥:៥២:១៣។ គេសួរលោកថា តើអ្នកណាជាប្រធានមន្ទីរ៨៧០។ លោកថាពីដំបូងគឺ បងប៉ង់ ជាអ្នកធ្វើប្រធាន ហើយបន្ទាប់បាត់ ប៉ង់ ទៅ ឌឿន មកជំនួស។ ខ្ញុំចង់សួរលោកថាតើ ប៉ង់ បាត់ខ្លួននៅពេលណា បើតាមលោកដឹង?

**ឆ៖** ខ្ញុំមិនចាំច្បាស់ទេ ប៉ុន្តែក្នុងៗឆ្នាំ៧៨ហ្នឹងឯង។ រវាងខែ៥ ខែ៦ មិនដឹងទេ គឺចន្លោះហ្នឹងក៏មិន ចាំមិនច្បាស់ទេ អ៊ីចឹង។

[១១:៥២:១៧]

**ស៖** ហើយ ឌឿន នោះបាត់ខ្លួនពេលណាដែរ? លោកចាំកាលបរិច្ឆេទដែរឬទេ?

**ឆ៖** បាត់ខ្លួនហ្នឹងក្នុងឆ្នាំ៧៨ ដែរ។

**ស៖** នៅចំពោះមុខតុលាការនេះនោះ ខ្ញុំសូមប្តូរប្រធានបទ។ គេបានសួរលោកថា លោកមានដែលដឹងសុន្ទរកថារបស់ ខៀវ សំផន ទាន់ទងទៅនឹងមហាក្សត់ទាំងប្រាំពីរនាក់ដែរឬទេ? គឺថាបន លន់ នល់។ ហើយខ្ញុំចង់សួរលោកថា តើលោកដឹងកាលនៅសម័យនោះនុះ អំពីចម្លើយរបស់ -- សេចក្តីប្រកាសរបស់ សីហនុ នៅថ្ងៃទី២៧ មីនា។ នៅក្នុងសេចក្តីប្រកាសនេះ គាត់និយាយកាត់ទោសប្រហារជីវិត ឡុង បូរ៉េត ហើយដោយប្រើពាក្យពេចន៍ដ៏សាហាវ ហើយនិងមហាក្សត់ទាំងប្រាំពីរនាក់

របស់បនក្សត់ លន់ នល់ ហើយសុំ -- ហើយនិងទាមទារឲ្យកាត់ទោសអ្នកក្បត់ ១៦នាក់ទៀត។ តើលោកដឹងពីសុន្ទរកថានេះរបស់ព្រះអង្គ នរោត្តម សីហនុ ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ។

[១១:៥៣:៥៩]

**ស៖** ម្សិលមិញ លោកបានឆ្លើយថា លោកទទួលបន្ទុកខាងការជម្លៀសព្រះអង្គម្ចាស់ ព្រះអង្គចេញពីភ្នំពេញនៅឆ្នាំ១៩៧៩ នៅពេលដែលវៀតណាមចូលមកវាយប្រហារ។ តើ ខៀវ សំផន នៅពេលនោះនៅជាមួយព្រះអង្គ ហើយនិងមហេសីព្រះអង្គដែរឬទេ ពេលដែលជម្លៀសចេញពីទីក្រុងភ្នំពេញឆ្នាំ៧៩នេះ?

**ឆ៖** ជម្លៀសចេញចុង ជិត៧៨ មិនមែន៧៩ ទេ។ ហើយអត់ពេលដែលយើងជម្លៀសហ្នឹងអត់ឃើញ អ៊ំ ខៀវ សំផន នៅនុ៎ងទេ អត់ឃើញទេ។

**លោក អាកទូរ វែកគែន៖**

លោកប្រធាន ខ្ញុំគិតថា លោកប្រធានប្រហែលជាសប្បាយចិត្តនឹងខ្ញុំហើយ ពីព្រោះអីខ្ញុំឈប់ -- ចប់ សួរចប់ហើយលោកប្រធាន។

*(សម្រាករយៈពេលខ្លី)*

[១១:៥៥:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ លោក រ៉ចាម តុន ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះ បានចប់សព្វគ្រប់ហើយ។ ហើយអង្គជំនុំជម្រះមិនត្រូវការស្តាប់សក្ខីកម្មរបស់លោកជាបន្តទៀតទេ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬគោលដៅដែលលោកចង់ទៅបានហើយ។ អង្គជំនុំជម្រះថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេលប្រាំថ្ងៃកន្លងមកនេះ ដោយបានខិតខំអត់ធ្មត់ និងប្រឹងប្រែងអស់ពីសមត្ថភាពផ្តល់សក្ខីកម្ម។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទាននៅក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ ហើយសូមលោកជួបតែសំណាងល្អ និងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១១:៥៦:៣១]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូន

សាក្សីរូបនេះវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅដែលគាត់ចង់ទៅ។

កិច្ចដំណើរការសវនាការសម្រាប់ព្រឹកនេះ ឃើញថាសមល្មមនឹងសម្រាកហើយ។ ហើយអង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងរសៀលម៉ោងមួយសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយនៅរសៀលនេះអង្គជំនុំជម្រះសូមជម្រាបភាគី និងសាធារណជនជ្រាបផងដែរ ថាកិច្ចដំណើរការសវនាការនឹងបន្តស្តាប់សក្ខីកម្មសាក្សី TCW-694 ដែលនឹងចាប់ផ្តើមសំណួរបឋមដោយអង្គជំនុំជម្រះ ហើយនិងបន្ទាប់មក គឺអង្គជំនុំជម្រះនឹងផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីតាំងសំណួរចំពោះសាក្សីដែលបានបម្រុងទុកនេះ។

សូមអញ្ជើញលោកមេធាវី!

[១១:៥៧:៣៦]

**លោក អេនគ្រូ អ៊ីនូហ្សី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមដោយសង្ខេប គឺកូនក្តីរបស់ខ្ញុំ គឺឈឺខ្នង ហើយនិងឈឺក្បាល ហើយនិងបាត់បង់ការផ្តង់អារម្មណ៍ជាទូទៅ ហើយខ្ញុំសូមអនុញ្ញាតទៅតាមដាននូវខាងក្រោម នៅល្ងាចនេះ ហើយខ្ញុំនឹងដាក់ជូនតុលាការនូវលិខិតបោះបង់សិទ្ធិតាមនីតិវិធី។ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់នូវសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សូមទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ហើយដោយមេធាវីរបស់គាត់សន្យាថានឹងផ្តល់មកឲ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។

[១១:៥៨:២៥]

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវានាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

មេធាវីលោក នួន ជា ត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះភ្ជាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការ

ដោយផ្ទាល់របស់លោក នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលនេះ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែក ខៀវ សំផន ឲ្យខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥៩ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅរសៀលនេះ អង្គជំនុំជម្រះនឹងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សី TCW-694។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីTCW-694 និងមេធាវីប្រឹក្សាសាក្សីមកកាន់បន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៣៤:២១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តីលោកសាក្សី! ជាបឋមនេះ យើងសួរអំពីសាវតារខ្លះៗអំពីសាក្សី។ តើលោកឈ្មោះអ្វីដែរសាក្សី?

**លោក សួង ស៊ីគឿង៖**

**ឆ៖** ខ្ញុំបាទឈ្មោះ សួង ស៊ីគឿន ហៅ គង់ ឬ ធន បាទ។

[១៣:៣៤:៥៤]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយលោកសាក្សីបង្អង់បន្តិច ពេលដែលខ្ញុំសួរលោកទៅ លោកបង្អង់បន្តិចចាំមើលក្បាលមីក្រូ ឬក៏ភ្លើងក្រហមនៅពីមុខលោកហ្នឹង ចាំភ្លើងក្រហម មានភ្លើងក្រហមសឹមលោកឆ្លើយ ទើបមានន័យថា ក្បាលមីក្រូចាប់ធ្វើប្រតិបត្តិការ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកអាចប្រាប់អង្គជំនុំជម្រះ អំពីថ្ងៃខែឆ្នាំកំណើតរបស់លោកបានដែរឬទេ? តើលោកកើតថ្ងៃខែឆ្នាំណា?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំបាទកើតនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៣៦ បាទ។

**ស៖** បាទ អរគុណ។ ហើយតើលោកមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណា?

**ឆ៖** ចេះតែភ្លេច។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

**ស៖** បាទ អរគុណ។ ហើយសព្វថ្ងៃហ្នឹងលោកប្រកបមុខរបរអ្វីដែរ?

**ឆ៖** ខ្ញុំចូលនិវត្តន៍ហើយ បាទ។

[១៣:៣៥:៥៩]

**ស៖** បាទ អរគុណ។ ហើយតើឪពុកបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ សួង កាក់។ គាត់ស្លាប់ហើយបាទ។

**ស៖** បាទ អរគុណ។ ចុះម្តាយបង្កើតរបស់លោក?

**ឆ៖** ម្តាយខ្ញុំបាទឈ្មោះ នូ រឹម។ គាត់ក៏ស្លាប់ដែរ។

**ស៖** បាទ អរគុណ។ ហើយចុះប្រពន្ធរបស់លោក គាត់ឈ្មោះអ្វីដែរ?

**ឆ៖** ប្រពន្ធរបស់ខ្ញុំសព្វថ្ងៃ ឈ្មោះ តាំង ហ៊ុយអេង។

**ស៖** តើលោកមានកូនប៉ុន្មាននាក់?

**ឆ៖** កូនខ្ញុំប្រពន្ធក្រោយមានម្នាក់ បាទ។

**ស៖** ចុះកូនជាមួយប្រពន្ធមុន មានកូនទេ?

**ឆ៖** ប្រពន្ធមុន ខ្ញុំមានកូន៤នាក់។ ស្លាប់ម្នាក់ នៅសល់៣នាក់ បាទ។

[១៣:៣៧:០៦]

**ស៖** បាទ អរគុណ។ លោក សួង សុគឿង តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីម្សិលមិញ ថាតាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូបទេ គឺលោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន និងបុគ្គលទាំងឡាយ ដែលត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២នេះ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** បាទ អរគុណ។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីដែល គឺបានធ្វើរបាយការណ៍ថាលោកបានធ្វើសម្បថរួចហើយ កាលពីថ្ងៃទី១ ខែសីហា នៅចំពោះមុខអ្នកតាដំបងដែក។ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែនហើយ បាទ។

**ស៖** បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

លោក សួង ស៊ីគឿន នៅក្នុងនាមលោកជាសាក្សី យើងសុំប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់លោកមួយចំនួនដូចខាងក្រោមនេះ៖

ក្នុងនាមលោកជាសាក្សី ក្នុងកិច្ចដំណើរការនីតិវិធីសវនាការ នៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធនៅក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬក៏អំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងត្រូវប្រឈម និងទទួលរងនូវការចោទប្រកាន់។ ហើយដើម្បីអនុវត្តសិទ្ធិនេះ អង្គជំនុំជម្រះបានផ្តល់មេធាវីប្រឹក្សាសាក្សីមួយរូបគឺលោក សេង រិទ្ធី តាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដើម្បីជួយលោកនៅក្នុងអនុវត្តសិទ្ធិនេះ នៅក្នុងកិច្ចដំណើរសវនាការនេះ។ តើលោកយល់ទេអំពីសិទ្ធិនេះ?

**លោក ស្នួង ស៊ីគឿន៖**

បាទ ខ្ញុំបាទយល់អំពីសិទ្ធិរបស់ខ្ញុំ។

[១៣:៣៩:១៤]

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ គឺទន្ទឹមនឹងសិទ្ធិនេះក៏លោក ក្នុងនាមជាសាក្សី លោកមានករណីយកិច្ចត្រូវផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ ដោយលោកត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬអង្គជំនុំជម្រះសួរចំពោះលោក។ លើកលែងតែក្នុងករណីចម្លើយទៅនឹងសំណួរ ឬការអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានរៀបរាប់ខាងលើអម្បាញ់មិញនេះ គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយលោកត្រូវឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

[១៣:៤០:០៤]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ស្នួង ស៊ីគឿន តើលោកដែលធ្លាប់បានផ្តល់សក្ខីកម្មជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតទេ កន្លងមក?

**លោក ស្នួង ស៊ីគឿន៖**

**ឆ៖** កន្លងមក ពីរដងនៅឆ្នាំ២០០៧ ហើយនិងឆ្នាំ២០០៩ ខ្ញុំបានធ្វើសក្ខីកម្មនៅមុខចៅក្រមស៊ើបអង្កេត បាទ។

**ស៖** លោកធ្លាប់ធ្វើ -- សម្ភាសជាមួយនឹងនៅចៅក្រមស៊ើបអង្កេតប៉ុន្មានដង? ពីរដង?

**ឆ៖** បាទ ពីរដង បាទ។

**ស៖** ហើយលោកចាំទេ ការធ្វើសម្ភាសហ្នឹង ប្រព្រឹត្តនៅទីកន្លែងណាដែរ?

**ឆ៖** បាទ នៅកន្លែងនេះ បាទៗ។

**ស៖** នៅក្នុងបរិវេណនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺនៅទីនេះ។ ពិតមែនទេ?

**ឆ៖** បាទ ពិតមែន។

**សៈ** ហើយនៅពេលចូលមកចំពោះមុខ -- នៅមុនពេលចូលចំពោះមុខអង្គជំនុំជម្រះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលស្ដាប់ចម្លើយរបស់លោក ដែលបានធ្វើជាមួយអ្នកស៊ើបអង្កេតកន្លងមកដែរឬទេ ដើម្បីរំឭកការចងចាំ?

[១៣:៤១:៤៣]

**ឆៈ** បាទ ខ្ញុំបានអានកំណត់ហេតុនេះ ឡើងវិញ បាទ។

**សៈ** បាទ អរគុណ។ ហើយបើតាមសមត្ថភាពដែលលោកដឹង លោកចង់ចាំ តើលោកអាចបញ្ជាក់បានដែរឬទេ ថាកំណត់ហេតុស្ដាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំនេះ ពិតជាត្រឹមត្រូវ និងស៊ីសង្វាក់គ្នា ឬក៏ស្របគ្នា ទៅនឹងចម្លើយរបស់លោកដែលបានធ្វើសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតកាលពីមុននោះ ដែរឬទេ?

**ឆៈ** បាទ ស្របគ្នា។

**ប្រធានអង្គជំនុំៈ**

បាទ អរគុណ។ បាទ អង្គជំនុំជម្រះសូមជម្រាបជូនតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការសវនាការ ពិភាក្សាដេញដោលស្ដាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីតាំងសំណួរដេញដោលចំពោះសាក្សីនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

សូមៗបង្អង់បន្តិច! សូមៗសម្រាកបន្តិចសិន!

តាមព័ត៌មានដែលអ្នកមន្ត្រីរដ្ឋបាលតុលាការប្រាប់ខ្ញុំថា លោកមានបញ្ហាសុខភាព ដោយបត់ជើងញឹកញាប់។ អ៊ីចឹង ដើម្បីសម្រួលដល់បញ្ហានេះ នៅក្នុងកិច្ចដំណើរការ។ អង្គជំនុំជម្រះសូមអនុញ្ញាតឲ្យលោកអាចលើកដៃ ដើម្បីស្នើសុំ ជាសញ្ញាស្នើសុំទៅបន្ទប់ទឹក។ ហើយគប្បីលោកអនុវត្តនូវការស្នើសុំនេះនៅពេលដែលណាគម្លាតគ្នា។ ឧទាហរណ៍លោកឆ្លើយចប់នូវសំណួរ គឺលោកអាចស្នើសុំបាន ឬក៏មានពេលវេលាណាដែលឃ្លាតគ្នាបន្តិច ដើម្បីលើកដៃជាសញ្ញាទៅ ដើម្បីយើងនឹងអនុញ្ញាតឲ្យ។ ពីព្រោះកិច្ចដំណើរការពិភាក្សានេះ ប្រើប្រាស់ដោយក្បាលមីក្រូ ហើយមីក្រូនេះមិនលោកបញ្ឆោទេ គឺគេបញ្ជាពីកន្លែងផ្សេងមក។

[១៣:៤៣:៥៤]

អ៊ីចឹង ក្រែងលោលោកមានការអៀនខ្មាស ហើយយឺតយ៉ាវទៅ ហើយមិនបានស្នើសុំ គឺអាចមាន

បញ្ហាផ្នែកខាងសុខភាពរបស់លោកប៉ះពាល់។ ហើយភាគី និងសាធារណជន សូមជម្រាបពីបញ្ហានេះ។ ហើយបើសិនជាដើម្បីសម្រួលឲ្យច្បាស់លាស់ហ្នឹង គឺយើងបានរៀបចំនូវក្រដាសម្យ៉ាង គឺក្រដាសពណ៌លឿងនេះ ដើម្បីឲ្យជាងាយក្នុងការមើលឃើញ លោកអាចលើអ៊ីចឹង គឺមានន័យថា ជាសញ្ញាមួយ ថាលោកស្នើសុំសម្រាក ឬក៏អាចផ្អាកបន្តិចទៅបន្ទប់ទឹក ដើម្បីសម្រួលកិច្ចដំណើរការនេះ ឲ្យទៅប្រព្រឹត្តទៅដោយរលូន។ ចៀសវាងមានបញ្ហាកើតឡើងនៅក្នុងអំឡុងពេលសួរដេញដោលរបស់លោក ព្រោះឃើញថា លោកមានវ័យចំណាស់ ហើយអាចមានបញ្ហាដូច្នេះ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៣:៤៤:៤៩]

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ សូមគោរពលោក លោកស្រី មានវត្តមាននៅទីនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** សូមជម្រាបសួរលោក សួង ស៊ីគឿន! ខ្ញុំឈ្មោះ ច័ន្ទ តារាស្មី ជាសហព្រះរាជអាជ្ញារងជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅទីនេះ។ នៅពេលនេះ ខ្ញុំសូមជម្រាបសួរលោកទាក់ទិននឹងសំណួរមួយចំនួនដែលខ្ញុំមានបំណងសួរលោក ហើយនិងសហការីរបស់ខ្ញុំនឹងបន្តសួរបន្ទាប់ពីខ្ញុំ។

សំណួរជាបន្ទាប់នេះ ខ្ញុំសូមសួរលោកទាក់ទិនទៅនឹងឈ្មោះរបស់លោក។ តើលោកមានឈ្មោះធ្លាប់ហៅក្រៅហ្នឹងឈ្មោះ គង់ ឬ ធន ដែលលោកបញ្ជាក់ជូនលោកប្រធានអម្បាញ់មិញនេះ តើឈ្មោះនេះលោកបានប្រើនៅក្នុងពេលណាបាទ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ឈ្មោះ គង់ ខ្ញុំបានប្រើ ខ្ញុំបានចូលរួមក្នុងបក្សកុម្មុយនីស្តកម្ពុជានៅម៉ាឡៃ។ គេស្គាល់ឈ្មោះនេះនៅម៉ាឡៃ នៅប៉ៃលិន។ រីឯឈ្មោះ ធន គឺខ្ញុំជាឈ្មោះបដិវត្តន៍របស់ខ្ញុំ ដែលគេបានស្គាល់ឈ្មោះនេះនៅកោះកុងបាទ។

**ស៖** អរគុណបាទ។ ក្រៅពីឈ្មោះ គង់ ឬ ធន តើលោកមានឈ្មោះប្រើក្នុងបដិវត្តន៍ផ្សេងក្រៅពីនេះដែរឬទេបាទ?

**ឆ៖** បាទ មិនមានទេ។

**ស៖** បាទ ហេតុអ្វីបានជាលោកប្រើប្រាស់ឈ្មោះ គង់ ឬ ធន នៅក្នុងបដិវត្តន៍នោះបាទ? តើការប្រើហ្នឹងមានបំណងអ្វីបាទ?

**ឆ៖** គង់ និង ធន មានន័យដូចគ្នា។ គង់វង្ស ឈ្មោះនេះខ្ញុំអាចនឹងជម្រាបអង្គប្រជុំថាជាបងស្រីអៀង ធីរិទ្ធ គាត់បានដាក់ឈ្មោះខ្ញុំ គង់ហ្នឹង គឺគាត់ថា គង់វង្ស ហើយដោយសារក្នុងប្រវត្តិ ជាក្នុងដំណើរការជីវិតតស៊ូរបស់ខ្ញុំ ដោយសារគង់វង្សនេះហើយបានខ្ញុំរស់រានមានជីវិតដល់សព្វថ្ងៃហ្នឹង ក្នុងកាលៈទេសៈដ៏ពិសេសដែលខ្ញុំបានរៀបរាប់ក្នុងគម្រោងសៀវភៅរបស់ខ្ញុំ។

[១៣:៤៧:២២]

**ស៖** បាទ អរគុណ។ ជាទូទៅ យើងឃើញនៅក្នុងឯកសារមានឈ្មោះផ្សេងៗហៅជាច្រើនសម្រាប់កម្មាភិបាល ឬក៏បក្ខជនរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏របស់កម្មាភិបាលខ្មែរក្រហម។ តើលោកអាចពន្យល់បានទេថា ហេតុអ្វីបានជាមានការប្រើឈ្មោះផ្សេងនៅក្នុងពេលធ្វើបដិវត្តន៍នោះបាទ?

**ឆ៖** បញ្ហានេះស្រួលយល់ទេបាទ គឺក្នុងការតស៊ូបដិវត្តន៍ដ៏សែនស្មុគស្មាញ គឺតែង -- កម្មាភិបាលតែងតែចល័តពីតំបន់មួយទៅតំបន់មួយ ដូច្នេះទៅតំបន់ណាមួយ ត្រូវប្រើយកឈ្មោះមួយ ទៅតំបន់ផ្សេងទៀតគឺយកឈ្មោះមួយផ្សេងទៀតក្នុងទិសដៅ គឺគេចអំពីការរាតត្បាតរបស់ខ្មាំងបាទ។ គឺតាមគោលការណ៍របស់ចលនាបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជា រក្សាការសម្ងាត់ មានន័យថា ទទួលជ័យជម្នះបាន ៥០ភាគរយ បាទ។

**ស៖** បាទ សូមអរគុណលោក សួង ស៊ីគឿង។ ជាបន្តទៅនេះ ខ្ញុំសូមឆ្លងទៅប្រធានបទមួយទៀត គឺទាក់ទងទៅនឹងប្រវត្តិរបស់លោកមុនខែមេសា ឆ្នាំ១៩៧៥។ បាទ ជាដំបូងខ្ញុំសូមសួរលោកទាក់ទងទិននឹងប្រវត្តិការសិក្សារបស់លោក។ សូមលោកមេត្តាបញ្ជាក់ថា តើលោកធ្លាប់សិក្សានៅសាលាណាខ្លះបាទ?

[១៣:៤៩:០៥]

**ឆ៖** ខ្ញុំធ្លាប់សិក្សានៅសាលាបឋមសិក្សាបឋមភូមិនៅភូមិជ្រោយអំពិល ឃុំចំបក់ ស្រុកឆ្លូងបច្ចុប្បន្នស្រុកព្រែកប្រសប់ ខេត្តក្រចេះ រួចទៅខ្ញុំទៅបន្តការសិក្សានៅសាលាបឋមភូមិទុតិយភូមិនៅឆ្លូងបន្ទាប់មក ខ្ញុំបន្តការសិក្សានៅអនុវិទ្យាល័យព្រះសីហនុនៅកំពង់ចាម។ បន្ទាប់មក នៅសាលាកម្ពុជបុត្រនៅភ្នំពេញ ហើយបន្តមកទៀតនៅវិទ្យាល័យព្រះស៊ីសុវត្ថិនៅភ្នំពេញនោះ។ ហើយទៅប្រទេសបារាំង ខ្ញុំ

បាននៅឆ្នាំ១៩៥៧ ខ្ញុំបានទទួលអាហារូបករណ៍ខាងពីរដ្ឋាភិបាលបារាំង ទៅរៀនខាងអាកាសចរណ៍ស៊ីវិល។ ក្នុងពេលនោះខ្ញុំក៏ផ្លៀតទៅប្រឡងគេហៅថា Bac ទីII គឺយើងថា សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅ Bac លើកទី II គឺថាបាក់ឌុប នៅប៉ារីស ខ្ញុំក៏ជាប់បាក់ឌុបនៅប៉ារីសទៅ ហើយខ្ញុំក៏ចូលទៅរៀននៅសាកលវិទ្យានៅប៉ារីស -- សាកលវិទ្យាល័យហ្សកប៊ននៅប៉ារីស។ នៅហ្សកប៊ន ខ្ញុំបានជាប់សញ្ញាបរិញ្ញាបត្រខាងអក្សរ រួចក៏បានជាប់សញ្ញាបត្រខាងអនុបណ្ឌិតខាងអក្សរសាស្ត្របាទ។ ហើយ ៣០ឆ្នាំក្រោយមក ខ្ញុំក៏បន្តរៀបចំធ្វើជាបេក្ខជនអនុ -- បេក្ខជនបណ្ឌិតខាងចិត្តសាស្ត្រនយោបាយនៅសាកលវិទ្យាល័យប៉ារីស១០ ណង់ទែរ។ ក៏ប៉ុន្តែដល់ឆ្នាំ២០០៤ ខ្ញុំត្រូវរះបេះដូង ខ្ញុំក៏បោះបង់ចោលការសិក្សារបស់ខ្ញុំបាទ។ សូមចប់ប្រវត្តិរៀនសូត្ររបស់ខ្ញុំ។

[១៣:៥១:២៩]

**សៈ** បាទ សូមអរគុណលោក។ ខ្ញុំសូមសួរថា បន្តទៀត តើក្នុងអំឡុងពេលនៃការសិក្សារបស់លោកនៅប្រទេសបារាំង ឬក៏នៅក្នុងប្រទេសកម្ពុជាទាំងពីរ នៅក្នុងប្រទេសខ្មែរ និងនៅប្រទេសបារាំង។ តើលោកបានធ្លាប់ចូលរួមក្នុងសកម្មភាពនយោបាយណាមួយដែរឬទេ? បើធ្លាប់តើលោកចូលក្នុងគណបក្សណាមួយបាទ?

**ផៈ** កាលខ្ញុំនៅរៀននៅសាលាបឋមសិក្សាបឋមភូមិនៅស្រុកឆ្លូង ចាងហ្វាងសាលាហ្នឹង ហើយត្រូវជាគ្រូរបស់ខ្ញុំ ហើយខ្ញុំនៅស្នាក់ផ្ទះរបស់គាត់ហ្នឹង គឺថាលោកគ្រូ កង សារិន គឺជាប្រធានគណបក្សប្រជាធិបតេយ្យក្បាលដំរីនៅស្រុកឆ្លូង។ ដូច្នេះខ្ញុំក៏ចូល ពេលដែលខ្ញុំនៅតូចហ្នឹង អាយុ១៣, ១៤ឆ្នាំ ខ្ញុំក៏ចូលក្នុងក្រុម គឺថាយុវជនឃោសនាឲ្យគណបក្សប្រជាធិបតេយ្យ។ បន្ទាប់មកក៏ខ្ញុំចូលក្នុងចលនាប្រជាចលនារបស់ សឺង ង៉ុកថាញ់។ នៅពេលនោះខ្ញុំក៏គេចរត់ពីការចាប់ចងរបស់រដ្ឋាភិបាលនៅពេលនោះ។ ខ្ញុំចូលព្រៃនៅកំពង់ស្ពឺជាមួយព្រះអង្គម្ចាស់ចន្ទរង្សី បាទ។ បន្ទាប់ពីកិច្ចព្រមព្រៀងហ្សឺណែវ ខ្ញុំក៏បាន ពេលនោះ ពេលដែលខ្ញុំរត់ចេញនោះ ខ្ញុំត្រូវទទួលទោសឲ្យជាប់គុកធ្វើការធ្ងន់២០ឆ្នាំ ដោយរដ្ឋាភិបាលពេលនោះ។ ប៉ុន្តែកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ១៩៥៤ ក៏ការទោសហ្នឹង ខ្ញុំត្រូវបានលុបលាង ខ្ញុំក៏ចូលរៀនវិញនៅថ្នាក់ទី៣ ទំនើប ដែលត្រូវជាថ្នាក់ទី៩ សព្វថ្ងៃនេះ នៅវិទ្យាល័យ -- នៅអនុវិទ្យាល័យឯកជននៅកម្ពុជបុត្របាទ។ ពេលនោះគឺថា លោក ហ៊ូ យន់ ជាប្រធានអនុវិទ្យាល័យនេះ ហើយគ្រូរបស់ខ្ញុំ គឺលោក ម៉ី ម៉ាន់។ ខ្ញុំរៀននៅនោះ ខ្ញុំក៏ប្រឡងជាប់ឌីប្លូមទៅ គឺសញ្ញាបត្រមធ្យមសិក្សាបឋមភូមិហ្នឹង ខ្ញុំក៏ចូលទៅរៀននៅវិទ្យាស៊ីសុវត្ថិនៅភ្នំពេញបាទ។

[១៣:៥៤:១៩]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា រៀបចំសំណួរបន្ត គប្បីគិតឲ្យបានច្បាស់លាស់នូវការតាំងសំណួរ បែងចែកឲ្យច្បាស់លាស់រវាងសាក្សី។ គាត់ក្នុងនាមជាសាក្សី ហើយនិងគាត់ក្នុងនាមជនជាប់ចោទនៅចំពោះមុខនេះ។ នៅចំពោះមុខនេះ គាត់មិនមែនជាជនជាប់ចោទទេ គាត់ជាសាក្សី។ ដូច្នេះសំណួរគប្បីជ្រើសរើសនូវសំណួរណាដែលពាក់ព័ន្ធទៅនឹងអង្គហេតុ ជិតដិតទៅនឹងអង្គហេតុ ដែលបង្ហាញ ចង្អុលបង្ហាញនៅក្នុងដីកាដំណោះស្រាយ។ បើពុំដូច្នោះទេ គឺបញ្ហាទាំងអស់វាចេញក្រៅអង្គហេតុឆ្ងាយពេក។ ជិតកន្លះម៉ោងហើយដែលអត់ទាន់បានចូលពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលចោទប្រកាន់ចំពោះជនជាប់ចោទនៅឡើយទេ។

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន។ ខ្ញុំសូមបន្តទៅសំណួរមួយទៀត។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក សួង ស៊ីគឿន តើលោកអាចបញ្ជាក់បានទេថា តើលោកធ្លាប់បានជួបជាមួយនឹងលោក អៀង សារី ដែរឬទេ នៅក្នុងព្រឹត្តិការណ៍មុនខែមេសា ឆ្នាំ១៩៧៥?

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ ខ្ញុំបានជួបលោក អៀង សារី ពេលដែលគាត់ៗត្រឡប់មកពីប្រទេសបារាំងវិញ នៅដើមឆ្នាំ តាមខ្ញុំចាំនៅដើមឆ្នាំ១៩៥៧។ ពេលនោះ ខ្ញុំចង់ចូលតស៊ូជាសម្ងាត់ក្នុងក្របខ័ណ្ឌបក្សកុម្មុយនីស្តកម្ពុជា ដែលជាចលនាមិនទាន់កើតទេ ប៉ុន្តែជាចលនាសម្ងាត់។ គឺខ្ញុំស៊ុំពីរដង ពេលដែលខ្ញុំស្នាក់នៅទីចាត់ការសមាគមសិស្សចាស់អនុវិទ្យាល័យ និងវិទ្យាល័យព្រះស៊ីសុវត្ថិនៅផ្លូវប៉ាស្ទ័រ។ ហើយពេលនោះ គឺលោក អៀង សារី បានមកជួបខ្ញុំនៅកន្លែងនោះ ដើម្បីយល់ព្រមឲ្យខ្ញុំចូលជាអង្គការសម្ងាត់នៅពេលនោះបាទ។

[១៣:៥៦:៣៩]

**ស៖** បាទ អរគុណ។ នៅប្រទេសបារាំង តើលោកធ្លាប់បានដឹងឮអំពីវង់ ម៉ាក្ស-ឡេនីន ដែរឬទេបាទ? ក្រុមវង់ ម៉ាក្ស-ឡេនីន តើលោកបានដឹងឮដែរឬទេ ឬក៏លោកបានធ្លាប់ចូលរួមសកម្មភាពហ្នឹងដែរឬទេ?

**ផ៖** ពេលដែលខ្ញុំទៅបន្តសិក្សានៅប្រទេសបារាំង នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៥៧ គឺលោក អៀង សារី បានផ្ញើសារសំបុត្រខ្ញុំមួយច្បាប់ទៅជូនលោក ខៀវ សំផន នៅប៉ារីស។ ខ្ញុំចាំច្បាស់ថាពេលនុ៎ងលោក ខៀវ សំផន គាត់សម្រាកនៅពេទ្យបុរី សកលវិទ្យាល័យអន្តរជាតិនៅប៉ារីស *ស៊ីតេ អ៊ុយនីវើស៊ីទែរ អាំងទែរណាស្យូណាល់ ដឺ ប៉ារីស*។

[១៣:៥៧:៣៨]

បាទ ខ្ញុំមិនបានដឹងខ្លឹមសារនៃសំបុត្រនេះទេ ក៏ប៉ុន្តែក្រោយពីលោក ខៀវ សំផន បានទទួលសំបុត្រនេះ ក៏គាត់ទទួលខ្ញុំចូលជាសមាជិកនៃរង់បក្ស -- នៃរង់ ម៉ាក្ស-ឡេនីន នៅទីក្រុងប៉ារីស។

**ស៖** បាទ សូមអរគុណ។ តើរង់ ម៉ាក្ស-ឡេនីន នេះបង្កើតឡើងក្នុងបំណងអ្វីបាទ? ហើយបង្កើតឡើងដោយអ្នកណា?

**ផ៖** ឯកសារក្រោយៗក៏បញ្ជាក់ដែរ គឺអ្នកបង្កើតហ្នឹងគឺមានលោក អៀង សារី, លោក ទូ សាមុត និងលោក គេង វ៉ាន់សាក់ បាទ បីនាក់។

**ស៖** បាទ សូមអរគុណ។ តើគោលបំណងសំខាន់នៃការបង្កើតរង់ ម៉ាក្ស-ឡេនីន ហ្នឹងគឺដើម្បីអ្វី?

[១៣:៥៨:៤២]

**ផ៖** ខ្ញុំមិនបានដឹងជាក់ច្បាស់នៃគោលដៅនៃការបង្កើត រង់ ម៉ាក្ស ឡេនីន នេះទេ ប៉ុន្តែជាក់ស្តែងគឺខ្ញុំដឹងថា ទិសដៅបឋមបំផុតគឺរៀនសូត្រពីទ្រឹស្តី ម៉ាក្ស-ឡេនីន។ ហើយទីពីរទៀត គឺជាចលនាមួយដែលទម្រង់រូបរាងកាយជាបក្ស ម៉ាក្ស-ឡេនីន មួយដូចជាចាត់តាំង វិន័យ ការរស់នៅអីគឺយើងត្រៀមខ្លួនឲ្យលក្ខណៈសម្បត្តិទៅជាជនកុម្មុយនិស្ត តាមខ្ញុំដឹងបាទ។

**ស៖** បាទ អរគុណ។ តើក្នុងហេតុផលអ្វីបានជាលោកសម្រេចចិត្តចូលទៅក្នុងរង់ ម៉ាក្ស-ឡេនីន ហ្នឹង?

**ផ៖** ខ្ញុំកើតនៅក្នុងគ្រួសារកសិករក្រ មធ្យម ខ្ញុំនឹកឃើញពីម្តាយរបស់ខ្ញុំដែលគាត់រកតែសំពត់ស្លៀកត្រឹមត្រូវទៅវត្តក៏មិនបាន ហើយការរស់នៅ១២ខែ បង្កបង្កើនផលស្រែចម្ការហ្នឹងមិនបានដល់ចប់ចុងចប់ដើមទេ ខ្ចីបុលគេច្រើន។ ខ្ញុំមានការឈឺចាប់នៃជីវភាពរបស់គ្រួសារខ្ញុំ របស់កសិករ។ ភ្លើងកំហឹងនេះ នៅដុតនៅក្នុងខ្លួនខ្ញុំដដែលតាំងពីកុមារភាពមក។ ដូច្នេះហើយពេលនោះប្រទេសយើងនៅក្រោមអាណានិគមរបស់បារាំង ប្រទេសយើងនៅក្រោមរបបមួយ ដែលនៅចំពោះមុខអាណានិគមនិយម គឺជា

របបមួយដែល -- ខ្ញុំមិនមែនថា ជាអាយ៉ងអីទេ ក៏ប៉ុន្តែរបបមួយដែលបម្រើអាណានិគមនិយមតាមកម្រិតនេះ។ ដូច្នោះ ការឈឺចាប់នេះនាំឲ្យខ្ញុំគិតគូរអំពី រកអ្វីដើម្បីរួមចំណែក ដើម្បីរំដោះជាតិរបស់ខ្ញុំចេញពីនឹមអាណានិគមនិយម។ ហេតុដូច្នេះហើយបានជាខ្ញុំចូលបក្ស គណបក្សប្រជាធិបតេយ្យ ដែលមានព្រះអង្គ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ជាប្រធាននៅពេលនោះ។

[១៤:០១:៣០]

ក៏ប៉ុន្តែបក្ស គណបក្សប្រជាធិបតេយ្យ មិនបានបំពេញនូវសេចក្តីស្រេកឃ្លានរបស់ខ្ញុំ អំពីយុត្តិធម៌សង្គមទេ។ ដូច្នោះ មានតែលទ្ធិកុម្មុយនីស្តទេ លទ្ធិម៉ាក្ស-ឡេនីនទេ ដែលខ្ញុំយល់ថា អាចរំដោះប្រទេសជាតិខ្ញុំពី -- ជាមួយគ្នាពីនឹមអាណានិគមបារាំង និងពីរបបជិះជាន់នៅពេលនោះ។ ការគិតគូរនេះ ខ្ញុំសូមជម្រាបអង្គប្រជុំថា ជាការគិតគូរពីយុវវ័យ មិនមែនជាការគិតគូរ១០០ភាគរយរបស់ខ្ញុំ នៅពេលបច្ចុប្បន្ននេះទេបាទ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា សាជាថ្មីម្តងទៀត សូមរំឭកថា ការតាំងសំណួរគប្បីឲ្យមានការពាក់ព័ន្ធទៅនឹងអង្គហេតុ ដែល -- ទាំងឡាយដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ ព័ត៌មានដែលផ្តល់ឡើងដោយសាក្សី អម្បាញ់មិញនេះគឺ មិនមានប្រយោជន៍អ្វី ដើម្បីឲ្យអង្គជំនុំជម្រះយកទៅពិនិត្យពិចារណាសេចក្តីនោះទេ។ អ៊ីចឹងគឺសំណួរច្រើនហើយ។ ហើយសំណួរនេះ យើងបានកត់សម្គាល់ឃើញនៅក្នុងសំណួរដែលសួរឡើងដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ ទីនេះ ស្វែងរកការពិត ពាក់ព័ន្ធទៅនឹងអង្គហេតុទាំងឡាយដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ ដែលមាននៅក្នុងដីកាដំណោះស្រាយ។ យើងបានជម្រាបហើយអំមិញ ថាគួរត្រូវបានបែងចែកច្បាស់លាស់រវាងការតាំងសំណួរចំពោះសាក្សី ក្នុងនាមគាត់ជាសាក្សី ជាមួយនឹងក្នុងនាមគាត់ជាជនជាប់ចោទ ក្រែងលោមានការភ័ន្តច្រឡំ។

[១៤:០៣:៣២]

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន។ ខ្ញុំសូមឆ្លងទៅប្រធានបទមួយទៀត គឺទាក់ទងនឹងរណសិរ្សរួបរួមជាតិកម្ពុជា។ ប៉ុន្តែអ្វីដែលខ្ញុំបានលើកអំមិញ សួរអំមិញ គឺគ្រាន់តែជាការចង់ភ្ជាប់រវាងប្រវត្តិសាស្ត្រ នៃអ្វីដែលគាត់បានចូលនៅក្នុងសកម្មភាពជាក់ស្តែង ជាមួយនឹងអង្គហេតុដែលខ្ញុំ និងសហការីខ្ញុំនឹងសួរ។

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតសួរទៅប្រធានបទថ្មីមួយទៀត ទាក់ទងទៅនឹងរណសិរ្សរួបរួមជាតិកម្ពុជា។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក សួង ស៊ីគឿន នេះគឺជាសំណួរដែលខ្ញុំចាប់ផ្ដើមសួរលោក ឆ្លងចូលប្រធានបទរណសិរ្សរួបរួមជាតិកម្ពុជាបាទ។ សូមលោកមេត្តាបញ្ជាក់ បើសិនលោកអាចបញ្ជាក់បាន ទាក់ទងនឹងបញ្ហារណសិរ្សរួបរួមជាតិកម្ពុជា ដែលមានធ្វើសកម្មភាពនៅប្រទេសចិន។ តើលោកធ្លាប់បានចូលរួមក្នុងរណសិរ្សរួបរួមជាតិកម្ពុជានៅប្រទេសចិនដែរឬទេ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទខ្ញុំបានចូលរួមក្នុងការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា នៅប្រទេសចិន ហើយខ្ញុំបានត្រូវអង្គប្រជុំហ្នឹង ជ្រើសតាំងជាលេខា នៃគណៈកម្មការកណ្ដាល នៃរណសិរ្សទៀតផង។

[១៤:០៥:៤៦]

**ស៖** បាទ អរគុណ។ តើការចូលនោះក្នុងបំណងអ្វីដែរបាទ? ហើយហេតុអ្វីបានជារណសិរ្សរួបរួមជាតិកម្ពុជាហ្នឹងមានសកម្មភាពនៅប្រទេសចិន?

**ឆ៖** រណសិរ្សរួបរួមជាតិកម្ពុជានេះ កើតឡើងក្រោយពីលោកសេនាប្រមុខ លន់ នល់ ហ្នឹងធ្វើរដ្ឋប្រហារផ្ដួលរំលំសម្ដេចព្រះ នរោត្ដម សីហនុ ដែលជាប្រមុខរដ្ឋស្របច្បាប់នៃប្រទេសកម្ពុជាពេលនោះ ដើម្បីរំដោះប្រទេសកម្ពុជាពីនឹម -- ពីសេនាប្រមុខ -- ពីសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ លន់ នល់ ដែលមានចក្រពត្តិអាមេរិកជាអ្នកគាំទ្រ។ ពាក្យសម្ដីដែលខ្ញុំនិយាយ គឺនិយាយហេតុផលពេលនោះ មិនមែនពេលបច្ចុប្បន្ននេះទេ លោកប្រធាន ខ្ញុំចង់រំឭកប៉ុណ្ណឹងបាទ។

**ស៖** អរគុណ។ តើលោកចាប់ផ្ដើមចូលក្នុងរណសិរ្សនោះនៅពេលណាបាទ?

**ឆ៖** ពេលដែលបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ក្រោយពីសេចក្ដីប្រកាសរបស់សម្ដេចព្រះ នរោត្ដម សីហនុ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ គឺពេលនោះខ្ញុំនៅប្រទេសបារាំង ក្នុងឋានៈជាប្រធានសហភាពនិស្សិតខ្មែរនៅអឺរ៉ុប។ អង្គការរបស់ខ្ញុំឯកភាពគ្នា និងគាំទ្ររណសិរ្សរួបរួមជាតិកម្ពុជា ហើយបានបញ្ជូនខ្ញុំធ្វើជាតំណាងដើម្បីសម្ដែងការគាំទ្ររបស់សហភាពនិស្សិតខ្មែរ ចំពោះរណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្ដេចព្រះ នរោត្ដម សីហនុ ជាប្រធាន។ ពេលនោះព្រះអង្គ លោកគង់នៅប៉េកាំងបាទ។

[១៤:០៦:៥៦]

**ស៖** តើការចូលទៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជានោះ លោកចូលដោយស្ម័គ្រចិត្តផ្ទាល់ខ្លួន ឬក៏មានការជំរុញពីខាងណាបាទ?

**ឆ៖** គឺចូលដោយស្ម័គ្រ ព្រោះសហភាពនិស្សិតខ្មែរជាសមាគមនិស្សិត។ ពួកនិស្សិតចម្រើនខ្មែរ ហើយធ្វើការ -- ធ្វើសេចក្តីសម្រេចអ្វីនីមួយៗ គឺដោយស្ម័គ្រចិត្តក្នុងឋានៈយើងជាអ្នកគិតគូរ ជាយុវជនស្នេហាជាតិ គិតគូរដល់ប្រទេសជាតិយើងបាទ។

**ស៖** បាទ អរគុណ។ តើលោក អៀង សារី គាត់ធ្លាប់បានបើកកិច្ចប្រជុំ វគ្គអប់រំណាមួយដែរ ឬទេ សម្រាប់រណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងប៉េងកាំងនោះបាទ?

**ឆ៖** តាមខ្ញុំដឹងលោក អៀង សារី គាត់នៅប៉េកាំង នៅពេលនោះមិនមែនក្នុងឋានៈជាអ្នកនាំ អ្នកដឹកនាំរណសិរ្សរួបរួមជាតិកម្ពុជាទេ។ គាត់នៅប៉េកាំងពេលនោះ ក្នុងឋានៈជាតំណាង អ្ហឺ! ភាគីផ្ទៃ -- ភាគីក្នុងប្រទេសនៃរណសិរ្សរួបរួមជាតិកម្ពុជា។ គាត់តំណាងរបស់ចលនាតស៊ូនៅក្នុងប្រទេសបាទ។

[១៤:០៨:៣៥]

**ស៖** បាទ សូមអរគុណ។ តើនៅពេលណា និងក្នុងកាលៈទេសៈណា ដែលលោកបានក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** ខ្ញុំបានក្លាយជាសមាជិកពេញសិទ្ធិ នៃបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៧១។

**ស៖** អរគុណបាទ។ តើនៅពេលនោះ មានរៀបចំពិធីបញ្ចូលរូបលោកចូលទៅក្នុងសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? បើសិនជាមាន តើអ្នកណាគេជាអធិបតីនៅក្នុងពិធីបញ្ចូលនោះ?

**ឆ៖** ពេលនោះ គឺនៅផ្ទះ នៅផ្ទះលោក អៀង សារី នៅប៉េកាំង ហើយអ្នកដែលធានារបស់ខ្ញុំ ធានាខ្ញុំជាបក្ខជនហ្នឹង គឺមានដូច មានពីរនាក់ ខ្ញុំដូចភ្លេច ដូចមិនចាំ ប៉ុនដូចមានលោក គាត ឈន់ និង លោក ជួន ប្រសិទ្ធិ ហើយអ្នកដែលធ្វើជាប្រធានអង្គប្រជុំហ្នឹងគឺ លោក អៀង សារី បាទ។

**ស៖** អរគុណ។ តើមុននឹងបញ្ចូលលោកទៅក្នុងសមាជិកបក្សកុម្មុយនីស្តកម្ពុជា តើលោកបានធ្វើសកម្មភាពយ៉ាងដូចម្តេចខ្លះ? ឬក៏បង្ហាញគោលជំហរយ៉ាងដូចម្តេច ដើម្បីឲ្យបក្សកុម្មុយនីស្តកម្ពុជាហ្នឹង សម្រេចចិត្តបញ្ចូលលោកទៅក្នុងបក្សកុម្មុយនីស្តកម្ពុជាបាទ?

[១៤:១០:៣៧]

**ឆ៖** ដើម្បីឆ្លើយនឹងសំណួរហ្នឹង គឺខ្ញុំត្រូវមើលថយក្រោយបន្តិច ពីព្រោះនេះ ជាចលនាតស៊ូ ជា

ចលនានយោបាយនៅប្រទេសកម្ពុជានៅពេលនោះ។ គឺការតស៊ូរវាងផ្នែកចម្រើននៅក្នុងបក្សប្រជាធិបតេយ្យនិងពួកដែលចាស់ៗ។ ខ្ញុំនិយាយនេះ គឺថាមិនមែនខ្ញុំខ្វះគួរសម ប៉ុន្តែដើម្បីស្រួលស្តាប់ ពួកនិន្នាការចាស់ៗ។ គឺថា គឺកាលដែលខ្វែងគំនិតគ្នា លើការសហការជាមួយនឹងចលនាតស៊ូវៀតណាម វៀតមិញ។ គឺពួកសមាជិកគណបក្សប្រជាធិបតេយ្យដែលជានិយម សឺន ង៉ុក ថាន់ គឺដាច់ខាតមិនធ្វើសហការជាមួយចលនាវៀតមិញទេ។ គឺទុកចលនាវៀតមិញជាសត្រូវដូចជាអាណានិគមបារាំងដែរ ប៉ុន្តែពួកចម្រើនដែលខ្លួនខ្ញុំភ្ជាប់ខ្លួនជាមួយនេះ គឺយល់ថា សត្រូវរួមរបស់ប្រជាជនយើង ប្រជាជនកម្ពុជា ប្រជាជនវៀតណាម និងប្រជាជនឡាវ គឺអាណានិគមនិយមបារាំង។ យើងមានសត្រូវតែមួយ ដូច្នោះយើងត្រូវសហការគ្នា ក្នុងគោលជំហរស្មើភាព ភាតរភាព ដើម្បីប្រឆាំងតទល់នឹងអាណានិគមនិយមបារាំង។ ដូច្នោះ ចលនានេះ វាក្រោយទៅបែកជាពីរ។ គឺថា មួយផ្នែកទៅជាចលនា -- ទៅជាៗប្រជាចលនាដែលមាន សឺន ង៉ុក ថាន់ ហើយដែលក្រោយមកក៏រួមជាមួយនឹងលោកសេនាប្រមុខ លន់ នល់ ដែលមាននិន្នាការនិយមសហរដ្ឋអាមេរិក។ ហើយចលនាមួយទៀត គឺចលនាតស៊ូដែលប្រមូលផ្តុំនៃពួកបញ្ញាជនទើបមកស្រុកបារាំង ដូចជាលោក កេង វ៉ាន់សាក់, លោក ស៊ិន កែមកូ ជាដើម លោក ជួន មុំ ជាដើមបាទ។

[១៤:១៣:១២]

**សៈ** បាទ អរគុណ។ នៅក្នុងគោលមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជាមានកំណត់អំពីសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំចង់ឲ្យជួយបញ្ជាក់ ថាតើសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា និងសមាជិកបក្សពិតប្រាកដ តើធ្វើដូចម្តេចដើម្បីកំណត់ពីភាពខុសគ្នារវាងសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយនិងសមាជិកបក្សពិតប្រាកដនោះបាទ? តើគេកត់សម្គាល់ត្រង់ចំណុចណាខ្លះ?

**ឆៈ** លោកប្រធាន សូមអត់ទោស ខ្ញុំដូចក្តាប់សំណួរហ្នឹងមិនសូវបានទេបាទ។

**សៈ** សូមអនុញ្ញាតជម្រាបសួរម្តងទៀតលោកប្រធាន។ សូមលោកបញ្ជាក់អំពីភាពខុសគ្នារវាងសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា និងសមាជិកបក្សកុម្មុយនីស្តកម្ពុជា។ ថាតើមាគ៌ា ឬក៏លក្ខន្តិកៈ ឬក៏គោលមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង កំណត់ថានរណាខ្លះជាសត្រូវ ដែលចាត់ទុកជាសត្រូវហ្នឹង? ហើយសត្រូវហ្នឹង គេកត់សម្គាល់ដោយសកម្មភាព ឬក៏កាយវិការ យ៉ាងដូចម្តេចខ្លះ? ហើយសមាជិកបក្សហ្នឹង លោកបានបញ្ជាក់អំមិញហើយ ថាលក្ខណៈដើម្បីចូលសមាជិកបក្សហ្នឹង គឺមានចំណុចល្អៗជាច្រើន។ អ៊ីចឹង ខ្ញុំចង់ឲ្យលោកបញ្ជាក់អំពីសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង តើគេកត់សម្គាល់

មើលឃើញដោយចំណុចណាខ្លះបាទ?

[១៤:១៤:៤១]

**ឆ៖** ខ្ញុំថា សត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា គឺពេលនោះ វាជាចក្រពត្តិអាមេរិក ហើយនិងបរិវារវាផ្ទៃក្នុង។ អាហ្នឹងសត្រូវទីមួយ។ បន្ទាប់មកគឺថាពួកម្ចាស់ដីកុំប្រាដ័រ ដែលនិយមគាំទ្រសហរដ្ឋអាមេរិក។ ព្រោះក្នុងម្ចាស់ដីពួកកុំប្រាឌ័រហ្នឹង ក៏មានកុំប្រាឌ័រអ្នកស្នេហាជាតិ។ បក្សកុម្មុយនីស្តកម្ពុជាមិនបានចាត់ទុកអ្នកទាំងនោះជាជនក្បត់ជាតិទេ ជាសត្រូវរបស់ខ្លួនទេ ចាត់ទុកជាសម្ព័ន្ធមិត្តៗរបស់ៗគេបាទ។

**ស៖** បាទ សូមអរគុណ។ សំណួរមួយទៀត តើលោក អៀង សារី នៅពេលដែលគាត់ស្នាក់នៅក្រុងប៉េកាំង តើគាត់មានតួនាទីអ្វីខ្លះនៅទីនោះបាទ?

**ឆ៖** តួនាទីគឺ ក្នុងឋានៈគាត់ជាតំណាងផ្នែកក្នុងប្រទេសនៃចលនាតស៊ូពេលនោះគឺ ទីមួយ គាត់ដូចជាតំណាងចលនាតស៊ូប្រចាំប្រទេសចិនដែរ។ ដូចថា ទីពីរគឺការ -- សំខាន់បំផុតគឺថាគាត់នៅជាមួយអមជាមួយសម្តេចព្រះនរោត្តម សីហនុ ដើម្បីរួមកម្លាំងទាំងខាងក្នុងប្រទេសទាំងក្រៅប្រទេស បន្តការតស៊ូដើម្បីរំដោះប្រទេសចេញពីនឹមរបស់សាធារណរដ្ឋកម្ពុជា ដែលមានសហរដ្ឋអាមេរិកគាំទ្របាទ។

[១៤:១៦:៥០]

**ស៖** បាទ សូមអរគុណ។ សំណួរមួយទៀត តើលោកអាចបញ្ជាក់បានទេថា មានតំណាងគណៈមជ្ឈិមបក្សកុម្មុយនីស្តនៅឯបរទេសដែរឬទេ នៅព្រឹត្តិការណ៍មុនខែមេសា ឆ្នាំ១៩៧៥ នោះបាទ?

**ឆ៖** ខ្ញុំដឹង តាមខ្ញុំដឹងគឺថាមានតំណាងបក្សកុម្មុយនីស្តកម្ពុជានៅបរទេសគឺថា បរទេសពេលនុ៎ងគឺថា មាននៅវៀតណាមខាងជើង ពេលនោះជាសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ហើយនិងនៅប្រទេសចិន គឺលោក អៀង សារី នេះឯងបាទ។

**ស៖** បាទ តើតំណាងគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជានៅវៀតណាមខាងជើង និងនៅចិននោះ តើអ្នកណាគេធ្វើជាប្រធាននៅទីនោះបាទ?

**ឆ៖** ខ្ញុំៗដឹងតែប៉ុណ្ណឹង ខ្ញុំដឹងលោក អៀង សារី គឺថាគាត់ជាតំណាងរបស់បក្សកុម្មុយនីស្តកម្ពុជានៅវៀតណាមខាងជើង ហើយនៅស្រុកចិន។ ត្រង់អ្នកឯងទៀត ខ្ញុំអត់បានដឹងទេបាទ។

**ស៖** បាទ សូមអរគុណ។ តើលោក អៀង សារី បានវិលត្រឡប់ទៅទីក្រុងប៉េកាំងនៅពេលណាបាទ? នៅដំណាក់កាលចុងក្រោយ នៅពេលដែលគាត់វិលត្រឡប់មកវិញ ហើយគាត់វិលមកស្រុកខ្មែរ

វិញ អ៊ីចឹងគឺពេលដែលគាត់ធ្វើដំណើរទៅប្រទេសចិនលើកចុងក្រោយបំផុត តើនៅពេលណា មុននឹងគាត់វិលត្រឡប់មកប្រទេសកម្ពុជាវិញ តើលោកចាំបានទេបាទ?

[១៤:១៨:៤០]

**ឆ៖** លោកប្រធាន សូមអត់ទោស សូមព្រះរាជអាជ្ញាបញ្ជាក់ ព្រោះធ្វើដំណើរចេញចូលស្រុកចិន គាត់ធ្វើដំណើរច្រើន ខ្ញុំភ្លាប់សំណួរនេះមិនបានទេបាទ។ មិនច្បាស់បាទ។

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណ។ សូមអត់ទោសលោកប្រធាន ខ្ញុំសូមបន្តទៅសំណួរផ្សេងមួយទៀតបាទ ដោយសារតែសំណួរនេះ ខ្ញុំគិតថាគាត់ អាចគាត់មិនចាំបាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ទាក់ទិននឹងបញ្ហាមួយទៀត គឺសំណួរខ្ញុំសូមចូលទៅក្នុងអត្ថបទមួយដែលទាក់ទិននឹងទីភ្នាក់ងារសារព័ត៌មានខ្មែរ -- ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ហៅកាត់ថា អា.កា.អ៊ី បាទ។ តើនៅក្នុងសារព័ត៌មាននេះលោកមានបានធ្លាប់ចូលរួមក្នុងសកម្មភាពសារព័ត៌មាននេះដែរឬទេ?

**ឆ៖** នៅពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៤ មុនដែលខ្ញុំធ្វើដំណើរចូលមកក្នុងប្រទេសវិញ។ ខ្ញុំជាតំណាងសារព័ត៌មាននេះប្រចាំប្រទេសចិនបាទ។

**ស៖** តើនៅពេលនោះ អ្នកណាគេជាប្រធានការិយាល័យព័ត៌មាននៅក្នុងទីភ្នាក់ងារសារព័ត៌មាននោះ? អ្នកណាជាគេជាប្រធានបាទ?

[១៤:១៩:៥៩]

**ឆ៖** សូមជម្រាបឲ្យត្រង់ទៅ ខ្ញុំមិនដឹងអ្នកណាជាប្រធានទេ។ ខ្ញុំគ្រាន់តែដឹងថា សារព័ត៌មាននេះ គឺដំណឹងអីគឺថាដែលខ្ញុំបានទទួលហ្នឹង គឺផ្ញើមកហាណូយតាមរយៈស្ថានទូតវៀតណាមខាងជើងប្រចាំប៉េកាំង។

**ស៖** បាទ អរគុណ។ ចុះចំពោះការិយាល័យព័ត៌មាននៃរណសិរ្សរួបរួមជាតិកម្ពុជា តើលោកអាចចងចាំបានទេថា អ្នកណាជាប្រធានការិយាល័យព័ត៌មាននៃរណសិរ្សរួបរួមជាតិកម្ពុជានោះ?

**ឆ៖** ប្រធានការិយាល័យព័ត៌មានរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំប្រទេសចិនហ្នឹង គឺខ្ញុំបាទនេះឯងបាទ។

**ស៖** អរគុណ។ តើការិយាល័យរណសិរ្សរួបរួមជាតិកម្ពុជាហ្នឹងមានមុខងារធ្វើអ្វីខ្លះបាទ?

**ឆ៖** គឺជាអង្គការមួយដែលផ្សព្វផ្សាយដំណឹងពីសមរភូមិខាងមុខ សមរភូមិខាងក្នុង ហើយនិងសកម្មភាពទូតដែលគាំទ្ររណសិរ្សរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាល រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលមានសម្តេចព្រះ សីហនុ ជាប្រធានបាទ។

[១៤:២១:២៧]

**ស៖** ចុះចំពោះទីភ្នាក់ងារសារព័ត៌មានកម្ពុជា ហៅកាត់ថា អា.កា.អ៊ី មានមុខងារអ្វីខ្លះដែរ នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជានោះ?

**ឆ៖** ទីភ្នាក់ងារសារព័ត៌មានកម្ពុជា អា.កា.អ៊ី ហ្នឹងមិនមានទាក់ទងអីជាមួយរណសិរ្សរួបរួមជាតិកម្ពុជាទេ ជាការចាត់តាំង អានេះជាផ្នែកមួយ ខ្ញុំដឹងមិនច្បាស់ទេ ប៉ុន្តែជា គឺថាមិនមែនជាអង្គការដែលចាត់តាំងដោយការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជាទេបាទ។

**ស៖** បាទ អរគុណ។ តើទីភ្នាក់ងារសារព័ត៌មានកម្ពុជា អា.កា.អ៊ី ហ្នឹងមានមុខងារអ្វីខ្លះដែរឬទេនៅក្នុងចលនាបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** មែនទែនទៅតួនាទី វាដូចប្រហែលជាព្រឹត្តិបត្រព័ត៌មានរបស់រណសិរ្សរួបរួមជាតិកម្ពុជាដូចគ្នា គឺថាផ្សព្វផ្សាយការតស៊ូរបស់ប្រជាជនកម្ពុជា និងកងទ័ពរំដោះជាតិកម្ពុជានៅសមរភូមិក្នុងប្រទេស ព្រមទាំងសកម្មភាពទូត ប្រមែប្រមូលការគាំទ្រពីសកលលោក ដើម្បីតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិក ហើយនិងបរិវាររបស់វា។

[១៤:២៣:១០]

**ស៖** បាទ សូមអរគុណ។ តាមបទពិសោធន៍ និងការដែលធ្លាប់ -- ដែលលោកធ្លាប់បានដឹងឮបានជួបប្រទះនៅក្នុងពេលដែលលោករស់នៅប្រទេសបារាំង ថាតើលោកបានឃើញប្រជាពលរដ្ឋខ្មែរប្រជាជនខ្មែរនៅឯបរទេសនោះ បានចូលរួមក្នុសកម្មភាពនៃចលនាបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ពេលនោះមិនទាន់មានបក្សកុម្មុយនីស្តកម្ពុជាទេ ពេលដែលខ្ញុំនៅប្រទេសបារាំងហ្នឹង មិនទាន់លេចឮដំណឹងថាមានបក្សកុម្មុយនីស្តកម្ពុជា។ ប៉ុន្តែមានអង្គការពីរដែលប្រមែប្រមូលជន អាណិកជនខ្មែរនៅបរទេសនៅអឺរ៉ុប។ ជាពិសេស គឺវង់ម៉ាក្ស-ឡេនីន ហើយអង្គការចំហហ្នឹង គឺសហភាពនិស្សិតខ្មែរ។ សូមបញ្ជាក់ថា សហភាពនិស្សិតខ្មែរនេះ គឺមានលោក ខៀវ សំផន ជាប្រធាន ហើយប្រមូលបានការគាំទ្រពីនិស្សិត និងបញ្ញាជនច្រើនលើសលប់នៅអឺរ៉ុប មិនគ្រាន់តែនៅប្រទេសបារាំង ទាំងទៅស្វីស នៅបែលហ្ស៊ិក ទាំងនៅសហភាពសូវៀតទៀតបាទ។

**ស៖** បាទ អរគុណ។ តើព្រឹត្តិបត្រដែលលោកបានមានប្រសាសន៍អម្បាញ់មិញ ព្រឹត្តិបត្រនេះបានបញ្ជូនទៅប្រទេសបារាំងដែរឬទេ? ហើយតើបញ្ជូនទៅហ្នឹង បញ្ជូនទៅជូនទៅអ្នកណាខ្លះ? ហើយក្នុងហេតុផលអីបាទ?

[១៤:២៥:០៨]

**ឆ៖** ច្បាស់ណាស់ហើយ ព្រោះបញ្ជូនទៅប្រទេសបារាំង ព្រោះពេលដែលក្រោយពីបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា នៅស្រុកបារាំងហ្នឹងក៏មានជាការិយាល័យបេសកជន អ៎! បេសកកម្មរបស់រណសិរ្សរួបរួមជាតិប្រចាំងប៉ារីស ពេលនោះខ្ញុំ តាមខ្ញុំចាំគឺមាន មុនដំបូងបំផុតមានលោក អ៊ិន សូកាន បន្ទាប់មកលោក ឱក សុគន្ធ ជាប្រធានបាទ។

**ស៖** អរគុណ។ នៅក្នុងអត្ថបទព្រឹត្តិបត្រនៃទីភ្នាក់ងារសារព័ត៌មានកម្ពុជា មុនពេលដែលធ្វើការចេញផ្សាយអត្ថបទទាំងអស់នោះ តើលោកអាចបញ្ជាក់បានទេថា អ្នកណាគេជាអ្នកត្រួតពិនិត្យលើរាល់ខ្លឹមសារនៃអត្ថបទទាំងអស់នោះ មុនពេលចេញផ្សាយអត្ថបទនោះជាផ្លូវការបាទ?

[១៤:២៦:១២]

**ឆ៖** គឺអត្ថបទនេះ គឺថាគឺក្រុមខ្ញុំជាអ្នករៀបរៀង ហើយអ្នកដែលត្រួតពិនិត្យហ្នឹងគឺជាការិយា-ល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា ហើយជាក់ស្តែងជា គឺលោក ជួន មុំ និង លោក ជួន ប្រសិទ្ធិ ដែលជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា។

**ស៖** អរគុណបាទ។ នៅក្នុងការិយាល័យព័ត៌មាននៃរណសិរ្សរួបរួមជាតិកម្ពុជា និងទីភ្នាក់ងារសារព័ត៌មានកម្ពុជា ហៅកាត់ថា អា.កា.អ៊ី តើនៅក្នុងអង្គការទាំងពីរនេះ អ្នកណាជាអ្នកសម្រេចទៅលើមាគ៌ានយោបាយនៅក្នុងការគ្រប់គ្រង និងបញ្ចេញផ្សាយព័ត៌មានបាទ?

**ឆ៖** មិនមានអ្នកណាសម្រេចទេ ព្រោះយើងគ្រាន់ផ្សាយជាព័ត៌មាន។ គឺខ្លួនខ្ញុំផ្ទាល់ ហើយនិងសហការីរបស់ខ្ញុំជ្រើសរើសដំណឹងពីខាងក្នុង ហើយនិងសកម្មភាពទូត សេចក្តីរាយការណ៍ពីស្ថានទូតនានានៅក្រៅប្រទេសហ្នឹង ហើយយើងចងក្រងធ្វើជាព្រឹត្តិបត្រព័ត៌មានចេញផ្សាយប្រចាំអាទិត្យនៅពេលដើមដំបូង ហើយបន្ទាប់មកចេញផ្សាយពីរដងក្នុងមួយអាទិត្យបាទ។

**ស៖** បាទ អរគុណ។ ខ្ញុំសូមសួរសំណួរមួយទៀតទាក់ទងនឹងសារព័ត៌មាននេះ ថាតើសម្តេចព្រះនរោត្តម សីហនុ និងក្រុមរបស់ព្រះអង្គធ្លាប់បានចូលរួមក្នុងកិច្ចការសារព័ត៌មាននោះដែរឬទេ?

[១៤:២៨:២២]

**ឆ៖** ពេលនោះព្រះអង្គជាប្រធាន ហើយជាប្រធានអ្វីៗដែលចេញពីព្រះអង្គយើងផ្សាយទាំងអស់។ យើងមិនមានអំណាច ឬមានសិទ្ធិ ឬមានចេតនានឹងបំបិទ ឬទប់ស្កាត់អ្វីៗដែលចេញពីព្រះអង្គឡើយ។ ឃើញទេ គឺថាជានយោបាយ ហើយជាមនោសញ្ចេតនា ក៏យើងមិនមានបំណងទៅនឹងអ្វីដែលចេញពីប្រធានប្រមុខនៃការតស៊ូនៃចលនាតស៊ូរបស់យើង យើងផ្សាយទាំងអស់ ហើយក៏ជាកិត្តិយសរបស់យើងដែរបាទ។

**ស៖** បាទ សូមអរគុណ។ តើក្រុមមេដឹកនាំណាខ្លះនៃគណបក្សកុម្មុយនីស្តកម្ពុជាដែលធ្លាប់បានចូលរួមក្នុងកិច្ចការសារព័ត៌មានកម្ពុជានោះបាទ?

**ឆ៖** តាមខ្ញុំដឹងដូចអត់មានទេបាទ។ ព្រោះលោក អៀង សារី ដូចគាត់អត់មានអីទាក់ទងជាមួយសារព័ត៌មានហ្នឹងទេបាទ។

**ស៖** អរគុណ។ តើអ្នកណាគេជាអ្នកទទួលខុសត្រូវខ្ពស់ជាងគេបំផុតចំពោះអត្ថបទសារព័ត៌មាននៃទីភ្នាក់ងារសារព័ត៌មានកម្ពុជានោះ?

[១៤:២៩:៤៨]

**ឆ៖** លោកប្រធាន សូមឲ្យសហព្រះរាជអាជ្ញាបញ្ជាក់បន្តិច ព្រោះទទួលខុសត្រូវខ្ពស់បំផុត បើចំពោះមុខច្បាប់គឺខ្ញុំបាទហ្នឹងហើយ ព្រោះជាចាងហ្វាងសារព័ត៌មាន ហើយបើខាងនយោបាយចំពោះមុខខាងនយោបាយគឺ ការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា ហើយជាក់ស្តែងគឺលោក ជួន មុំ ហើយនិង ឬលោក ជួន ប្រសិទ្ធិ បាទ។

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន។ គាត់បានឆ្លើយសំណួរខ្ញុំបាទ អ្វីដែលគាត់ឆ្លើយអម្បាញ់មិញបាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ខ្ញុំសូមអនុញ្ញាតបន្តទៅសំណួរមួយទៀត។ នៅក្នុងអំឡុងពេលនៃការស្នាក់នៅរបស់លោកនៅទីក្រុងប៉េកាំង តើលោកធ្លាប់កាន់មុខតំណែងអ្វីខ្លះបាទ?

[១៤:៣០:៣៩]

**ឆ៖** ខ្ញុំក្រៅពីប្រធានការិយាល័យសារព័ត៌មាននៃរណសិរ្សរួបរួមជាតិកម្ពុជា ខ្ញុំក៏ជាសមាជិកគណៈកម្មាធិការនៃរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំប្រទេសចិនដែរ ដែលមានឧត្តមសេនីយ៍ ដួង សំអុល គាត់ជាប្រធាន ហើយខ្ញុំ គឺខ្ញុំកាន់កិច្ចការសន្តិសុខបាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ថាអ្នកណាជាអ្នកកាន់អំណាចឃោធា នៅក្នុងបក្សកុម្មុយនីស្ត កម្ពុជានាសម័យកាលនោះបាទ?

**ឆ៖** ខ្ញុំមិនបានដឹងទេ បាទសូមទោស។

**ស៖** អរគុណ។ តើលោកធ្លាប់ធ្វើជាអ្នកបកប្រែភាសាឲ្យមេដឹកនាំណាខ្លះ នៅពេលដែលលោក ស្នាក់នៅទីក្រុងប៉េកាំង?

[១៤:៣១:៤០]

**ឆ៖** មិនមានទេ ព្រោះអ្វីៗគឺទាក់ទងតែជាមួយប្រទេសចិន ដូច្នោះចិនគេមាន -- ចិនមានអ្នក បកប្រែជាភាសាខ្មែរស្រាប់ហើយបាទ។

**ស៖** អរគុណ។ តើលោកធ្លាប់បានអមដំណើរក្នុងដំណើរទស្សនកិច្ចទៅបរទេសជាមួយនឹងមេ ដឹកនាំណាខ្លះបាទ?

**ឆ៖** ខ្ញុំធ្លាប់ធ្វើដំណើរទស្សនកិច្ចទៅប្រទេសអាហ្វ្រិក យូហ្គោស្លាវី រ៉ូម៉ានី អាល់បានី ហ្នឹង ជាមួយ -- អមដំណើររបស់សម្តេចព្រះ នរោត្តម សីហនុ ហើយពេលនោះខ្ញុំធ្វើដំណើរជាមួយលោក អៀង សារី បាទ។ ហើយបន្ទាប់មកនៅឆ្នាំ១៩៧៤ ខ្ញុំក៏បានរួមដំណើរធ្វើទស្សនកិច្ចនៅប្រទេសអាហ្វ្រិក អាល់បានី យូហ្គោស្លាវី ហ្នឹងជាមួយលោក ខៀវ សំផន ក្នុងឋានៈលោកជាអគ្គមេបញ្ជាការ -- ជា ឧបនាយករដ្ឋមន្ត្រី និងជាអគ្គមេបញ្ជាការកងទ័ពរំដោះជាតិកម្ពុជា បាទ។

[១៤:៣៣:០៨]

**ស៖** លោកបានបញ្ជាក់អម្បាញ់មិញថា លោកធ្លាប់កាន់មុខតំណែងផ្នែកសន្តិសុខនៅក្នុងរណសិរ្ស រួបរួមជាតិកម្ពុជា តើក្នុងមុខតំណែងនេះ លោកជាអ្នកទទួលខុសត្រូវផ្នែកសន្តិសុខហ្នឹង តើលោកធ្លាប់ ធ្វើកិច្ចការអ្វីខ្លះ?

**ឆ៖** ពេលនោះ គឺថាមិនមានអី កិច្ចការងារអីច្រើនទេ ព្រោះយើងនៅលើទឹកដីប្រទេសចិន ជា អធិបតេយ្យភាពរបស់ប្រទេសចិន ក៏ប៉ុន្តែក្នុងរង្វង់ខ្មែរ កិច្ចការមួយចំនួនគឺចិនគេមិនអាចលូកដៃចូលបាន ទេ ក៏ប៉ុន្តែរឿងនេះវាមានពាក់ព័ន្ធដល់សន្តិសុខរបស់ប្រទេសចិន។ ឧទាហរណ៍ជាក់ស្តែង គឺនៅឆ្នាំ ១៩៧១ ខ្ញុំនេះគឺ កែ ឈាង ហ្នឹងជាកូនរបស់ កែ មាស ដែលជាឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំប្រទេសចិន។ កែ ឈាង គាត់បាន -- ពេលនោះ គាត់ធ្វើជាកងការពាររបស់សម្តេចព្រះ នរោត្តម សីហនុ ទៅទស្សនកិច្ច រោងចក្រធ្វើអាវុធមួយនៅខេត្តស៊ិនយ៉ាំង ប្រទេសចិនខាងជើង។

[១៤:៣៤:៣៥]

ហើយ កែ ឈាង ហ្នឹងបានផ្តល់ព័ត៌មានអំពីទីតាំងរោងចក្រធ្វើអាវុធហ្នឹង ដល់ស្ថានទូតអ៊ីតាលីនៅប្រទេសចិន។ ចិន គេមានភស្តុតាងជាក់ស្តែង ហើយធម្មតាបើគ្មានរណសិរ្សរួបរួមជាតិកម្ពុជានៅកន្លែងនោះទេ គឺថាគេចាប់ផ្ទាល់តែម្តងអត់មានបញ្ហាអី ព្រោះគេមានភស្តុតាង។ ដូច្នោះ គេឱ្យខ្មែរយើងគឺថា ដោះស្រាយបញ្ហាហ្នឹង។ ក្នុងឋានៈជាគណៈកម្មាធិការរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំប្រទេសចិន យើងក៏សម្រេចចាប់ កែ ឈាង ហ្នឹង ឃុំដើម្បីសួរចម្លើយ។ ប៉ុន្តែក្រោយមកគឺថា ក៏ខាងលើខាងអ្នកដឹកនាំខាងលើប្រទេសហ្នឹង ក៏សម្រេចលែង កែ ឈាង ហ្នឹងទៅវិញទៅបាទ។ ហើយម៉្យាងទៀត ចំពោះករណីមួយទៀត គឺនៅឆ្នាំ១៩៧២ ពេលនោះព្រះមហាក្សត្រយានី ជាព្រះបាទក្សត្រី កុសមៈ ហ្នឹង ព្រះអង្គទ្រង់ឈឺ គឺនាំទៅព្យាបាលនៅគ័ងចូវ។ គ័ងចូវ នៅទីក្រុងនៅខាងត្បូងប្រទេសចិនហ្នឹង។ ពេលនោះ កែ -- ពេលនោះ នុត ឈឿម គាត់អមដំណើរទៅគាត់បានយកព័ត៌មានសម្ងាត់ពីប្រទេសចិនហ្នឹងប្រគល់ ឱ្យអាជ្ញាធរអង់គ្លេសនៅហុងកុង។ ពេលនោះហុងកុងមិនទាន់វិលត្រឡប់មកប្រទេសចិនវិញទេ។

ដូច្នោះជាការប៉ះពាល់ដល់សន្តិសុខផ្ទៃក្នុងរបស់ប្រទេសចិន។ ចិនក៏គេចង់ឱ្យយើងដោះស្រាយបញ្ហានេះ ខ្មែរយើងក៏សម្រេចចាប់ នុត ឈឿម ហ្នឹង មកឃុំឃាំងសួរចម្លើយ។ ក្រោយមកដូចករណី កែ ឈាង ដែរ នុត ឈឿម នោះក៏ត្រូវបានដោះលែងវិញទៅដោយសុវត្ថិភាពបាទ។

[១៤:៣៦:៤៤]

**សៈ** បាទ អរគុណ។ ទាក់ទងនឹងការចាប់ខ្លួនបុគ្គល តើ -- ខ្ញុំចង់សួរថា កម្មាភិបាល ឬក៏សមាជិកបក្សកុម្មុនីស្តកម្ពុជា តើលោកធ្លាប់បានសម្រេចចិត្ត ឬក៏ចេញបទបញ្ជា ឬក៏លោកមានសិទ្ធិនៅក្នុងការចេញបទបញ្ជា ឱ្យចាប់ខ្លួនសមាជិកណានៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដែរឬទេបាទ?

**ផៈ** លោកប្រធានខ្ញុំចង់ -- សូមលោកព្រះរាជអាជ្ញាបញ្ជាក់ថា អំពីបរិច្ឆេទបាទ។

**សៈ** អរគុណ។ គឺបរិច្ឆេទនៅព្រឹត្តិការណ៍មុនខែមេសា ឆ្នាំ១៩៧៥។ តើ -- ខ្ញុំចង់ដឹងថា ក្នុងនាមលោកជាអ្នកទទួលខុសត្រូវ ផ្នែកសន្តិសុខនេះ តើលោកមានសិទ្ធិអំណាចក្នុងការសម្រេចចេញជាបទបញ្ជា ដើម្បីឱ្យចាប់ខ្លួនបុគ្គលណា ឬក៏ចាប់សមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ផៈ** ខ្ញុំសូមបញ្ជាក់ថា ខ្ញុំដើរតួនាទីជាទទួលខុសត្រូវសន្តិសុខហ្នឹង ក្នុងក្របខ័ណ្ឌរណសិរ្សរួបរួមជាតិកម្ពុជា។ ដូច្នេះ ខ្ញុំមិនមានសិទ្ធិអីទៅចាប់ចងនៅក្នុងបក្សក្នុងបរិវេណបក្សកុម្មុយនីស្តកម្ពុជាទេបាទ។

[១៤:៣៨:១៩]

**ស៖** អរគុណ។ តើនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជានោះៗ លោកមានសិទ្ធិក្នុងការសម្រេចដើម្បីឱ្យចាប់ខ្លួនបុគ្គលណាមួយ ដែលជាសមាជិករបស់រណសិរ្សរួបរួមជាតិកម្ពុជាដែរឬទេ?

**ឆ៖** ក្នុងឋានៈជាអ្នកទទួលខុសត្រូវសន្តិសុខ ខ្ញុំមិនមានសិទ្ធិទេ គឺថា រណសិរ្សរួបរួមជាតិកម្ពុជានៅប៉េកាំងមានប្រធានរបស់គេ ហើយពីលើប្រធានរណសិរ្សនៅប្រទេសចិនហ្នឹង ក៏មានប្រធានទូទាំងប្រទេស ដែលជាព្រះបាទ នរោត្តម សីហនុ។ ដូច្នេះ ខ្ញុំមិនមានសិទ្ធិអីទៅសម្រេចកិច្ចការនេះទេបាទ។

[១៤:៣៨:៥៩]

**ស៖** អរគុណបាទ។ ខ្ញុំសូមសួរបន្តទៀត ថាតើអ្នកណាជាអ្នកជំរុញ ឬក៏លើកទឹកចិត្តឱ្យលោកទទួលខុសត្រូវកាន់កាប់ការងារ ទទួលខុសត្រូវនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជាបាទ?

**ឆ៖** តាមមើលទៅលោកឧត្តមសេនីយ៍ ដួង សំអុល ហ្នឹង គាត់ហើយនិងខ្ញុំហ្នឹង ក៏គាត់ចាស់មែន ប៉ុន្តែដូចថា គាត់រាប់អានខ្ញុំ ហើយខ្ញុំក៏គោរពស្រលាញ់ គាត់ប្រគល់ឱ្យខ្ញុំអីចឹង ខ្ញុំតែគេប្រគល់អីចឹងហើយខ្ញុំមិនសូវចេះថាទេ ទេបាទ។ ដូច្នោះ ខ្ញុំទទួលយកទៅបាទ ហើយឃើញថា មិនមានកិច្ចការអីធំដុំទេនៅស្រុកចិននោះ គឺសន្តិសុខនោះបាទ។ បើនៅប្រហែលជានៅកន្លែងទៀត ខ្ញុំមិនទេ ព្រោះខ្ញុំមិនមែនជាអ្នកកាប់ចាក់អីប៉ុន្មានទេបាទ។

**ស៖** អរគុណលោក សួង ស៊ីគឿន។ ខ្ញុំសូមបន្តទៅប្រធានបទមួយទៀត។ ទាក់ទងទៅនឹងយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា--

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយសាក្សី មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាកដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់។ ហើយនិងឱ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្តសួរទៅលោកសាក្សី។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក សួង ស៊ីគឿន ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត គឺទាក់ទិននឹងយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជាចន្លោះខែមីនា ឆ្នាំ១៩៧០ គឺនៅសម័យកាលរដ្ឋប្រហារ និងការអំពាវនាវរបស់សម្តេចន រោត្តម សីហនុ និងខែមេសា ឆ្នាំ១៩៧៥។ សំណួរជាបន្តនេះ គឺសូមសួរថា តើនៅទីក្រុងប៉េកាំង នៅពេលដែលលោក អៀង សារី ស្នាក់នៅទីក្រុងប៉េកាំង តើលោក អៀង សារី បានធ្វើទំនាក់ទំនងជាមួយនឹងកម្មាភិបាលរបស់បក្ស ឬក៏អ្នកចលនាតស៊ូនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា តាមមធ្យោបាយបែបណាខ្លះ?

[១៥:០២:២២]

**លោក សួង ស៊ីគឿន៖**

**ឆ៖** គឺនៅទីក្រុងប៉េកាំង លោក អៀង សារី បានចាត់តាំងសាខារបស់បក្សកុម្មុយនីស្តកម្ពុជានៅទីនោះមួយ ហើយគាត់ក៏បាន ដូចថាក្នុងឋានៈជាបេសកជនពិសេសនៃរណសិរ្សរួបរួមជាតិកម្ពុជានៅក្នុងប្រទេស គាត់ក៏បានបើកវគ្គអប់រំសមាជិកការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជាហើយនិងសមាជិកធម្មតារបស់រណសិរ្សរួបរួមជាតិកម្ពុជានៅប៉េកាំងនេះដែរ។

**ស៖** បាទ សូមអរគុណ។ តើលោកធ្លាប់ដឹងឮអំពីសម្ព័ន្ធភាពជាមួយនឹងសម្តេច សីហនុ នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជាដែរឬទេ?

[១៥:០៣:៣៨]

**ឆ៖** គឺសម្ព័ន្ធភាពរវាងសម្តេចព្រះ នរោត្តម សីហនុ ហើយនិងតំណាងរណសិរ្សរួបរួមជាតិ

កម្ពុជានៅទីក្រុងប៉េកាំង។ ជាកិច្ចស៊ីជម្រៅ ខ្ញុំមិនបានដឹងអីច្បាស់លាស់ទេ ព្រោះកិច្ចហ្នឹងវាហួសពីវង្វង់នៃភារកិច្ចរបស់ខ្ញុំបាទ។ ខ្ញុំមិនបានដឹងច្បាស់ទេ ប៉ុន្តែគ្រាន់ថាលោក អៀង សារី គាត់តំណាង ហើយគាត់ការគោលជំហររបស់ផ្នែកក្នុងប្រទេសនៃរណសិរ្សរួបរួមជាតិកម្ពុជា។ ជាពិសេសក្នុងពេលសម្រេចថា តើចូលរួមក្នុងកិច្ចប្រជុំក្នុងសន្និសីទអន្តរជាតិស្តីពីសន្តិភាពនៅវៀតណាម-កម្ពុជា នៅឆ្នាំ១៩៧៣។ អាហ្នឹងជាផ្លូវបត់មួយសំខាន់នៃការតស៊ូរបស់ប្រជាជនកម្ពុជា និងប្រជាជវៀតណាមបាទ។ ក្នុងពេលហ្នឹងជំហររបស់បក្សកុម្មុយនីស្តកម្ពុជាដែលលោក អៀង សារី គាត់តំណាងហ្នឹង គឺច្បាស់លាស់ណាស់ គឺមិនមានការចរចាជាមួយនឹងរបបរបស់សេនាប្រមុខ លន់ នល់ គឺថាបន្តការតស៊ូរហូតដល់ទីចុងបញ្ចប់បាទ។ ខុសពីជំហររបស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនៅពេលនោះបាទ។

**ស៖** អរគុណបាទ។ សូមលោកមេត្តាជួយបញ្ជាក់អំពីការទំនាក់ទំនងរបស់សម្តេចព្រះ នរោត្តម សីហនុ ជាមួយនឹងអ្នកចលនាតស៊ូនៅផ្ទៃក្នុងប្រទេសកម្ពុជានៅពេលនោះបាទ។ តើប្រើមធ្យោបាយណាខ្លះបាទ?

[១៥:០៥:៥៨]

**ឆ៖** គឺនៅពេលនោះ ការភ្ជាប់សកម្មភាពរវាងសម្តេច នរោត្តម សីហនុ ហើយនិងផ្នែកតស៊ូនៅក្នុងប្រទេសគឺជាដំណើរទស្សនកិច្ចមួយខែរបស់សម្តេចនៅខែមីនា ឆ្នាំ១៩៧៣ ចូលមកក្នុងប្រទេសបាទ។ ពេលនោះគឺជា ផ្លូវបត់ប្រវត្តិសាស្ត្រមួយបង្ហាញប្រជាជនកម្ពុជាទាំងមូល ហើយសាកលលោកឲ្យដឹងថារវាងសម្តេច នរោត្តម សីហនុ ហើយនិងចលនាតស៊ូនៅក្នុងប្រទេស គឺឯកភាពគ្នានឹងបន្តការតស៊ូរហូតដល់រំដោះប្រទេសជាតិបាទ។

**ស៖** បាទ សូមអរគុណ។ សូមលោកមេត្តាជួយបញ្ជាក់បន្ថែមទៀតទាក់ទងនឹងការទំនាក់ទំនងរបស់លោក អៀង សារី ជាមួយនឹងចលនាតស៊ូនៅខាងក្នុងប្រទេសកម្ពុជានាសម័យកាលនោះ តើគាត់ប្រើមធ្យោបាយយ៉ាងដូចម្តេច? ហើយភាគច្រើនទាក់ទងជាមួយនឹងបុគ្គលណាខ្លះបាទ?

**ឆ៖** ពេលនោះគឺសកម្មភាពលោក អៀង សារី ចំពោះយើងខ្ញុំដែលជាសមាជិកសាខារបស់បក្សកុម្មុយនីស្តកម្ពុជានៅប្រទេសចិន ជាសកម្មភាពសម្ងាត់។ ហើយកិច្ចការរបស់លោក អៀង សារី ជាពិសេសការទាក់ទងរបស់ -- រវាងគាត់ជាមួយនឹងផ្នែកខាងក្នុងប្រទេសក៏ខ្ញុំមិនបានដឹងដែរបាទ។

[១៥:០៨:០៣]

**ស៖** បាទ អរគុណ។ តើគណបក្សៗកុម្មុយនីស្តកម្ពុជាក្នុងសម័យកាលដែលខ្ញុំបានបញ្ជាក់នូវ

កាលបរិច្ឆេទខាងលើអម្បាញ់មិញនេះ បានចាត់ទុកសម្ដេច ព្រះនរោត្តម សីហនុ ក្នុងន័យយ៉ាងដូចម្ដេចចំពោះបក្សកុម្មុយនីស្តកម្ពុជាបាទ?

**ឆ៖** និយាយឲ្យត្រង់ទៅ ខ្ញុំក៏អត់បានដឹងដែរ។

**ស៖** អរគុណ។ សំណួរមួយទៀតសុំសួរថា តើលោកធ្លាប់បានដឹងឮអំពីពាក្យថា "សីហនុនិយម" ដែរទេបាទ? តើពាក្យនេះសំដៅទៅលើអ្វីបាទ? ហើយបង្កើតឡើងដោយនរណា ហើយយ៉ាងដូចម្ដេច ក្នុងន័យបង្កើតដើម្បីផលប្រយោជន៍អ្វីបាទ?

**ឆ៖** ពាក្យនោះ ខ្ញុំធ្លាប់ឮដែរ ហើយខ្ញុំក៏មិនបានដឹងថានរណាជាបង្កើតពាក្យនេះដែរ ប៉ុន្តែតាមខ្ញុំយល់គឺជាអ្នកដែលស្រឡាញ់ គោរព ហើយដើរតាមមាគ៌ារបស់សម្ដេច នរោត្តម សីហនុ។ ហើយមាគ៌ានេះច្បាស់ គឺថាប្រទេសកម្ពុជាត្រូវប្រកាន់យកនយោបាយអព្យាក្រឹត។ នយោបាយអព្យាក្រឹតក្រៅប្រទេស ហើយក្នុងប្រទេស ក៏ជានយោបាយកណ្ដាលដែរ ផ្លូវកណ្ដាលដែរ។ ផ្លូវកណ្ដាលមានន័យថា រួបរួមជាតិកម្ពុជា ហើយមិនបែងចែកខាងឆ្វេង ឬខាងស្ដាំទេ តាមខ្ញុំយល់បាទ។

[១៥:០៩:១៩]

**ស៖** អរគុណបាទ។ ចុះពាក្យ -- តើលោកធ្លាប់បានដឹងឮពាក្យថា "កម្លាំងយុទ្ធសាស្ត្រ" ដែលបារាំងគេហៅថា *"ហ្វ័ស ស្ត្រាស្ទ្រីហ្សុីក"* ហើយនិង "កម្លាំងតាក់ទិក" ហើយបារាំងគេហៅថា *"ឡាហ្វ័ស តាក់ទិគៈ"* តើពាក្យហ្នឹងបង្កើតឡើងក្នុងន័យអ្វី? ហើយវាខុសគ្នាយ៉ាងដូចម្ដេចបាទ?

**ឆ៖** តាមខ្ញុំយល់គឺនេះជាយុទ្ធវិធី ឬជាកិច្ចដំណើរការរបស់បក្សកុម្មុយនីស្តកម្ពុជា។ គឺកម្លាំងយុទ្ធសាស្ត្រ គឺកម្លាំងយូរអង្វែង។ បើយើងនិយាយពីវណ្ណៈ គឺថាវណ្ណៈកម្មករ និងកសិករ ហើយកម្លាំងយុទ្ធសាស្ត្រ យុទ្ធវិធី គឺកម្លាំងគេហៅថា "សម្ព័ន្ធមិត្តតាមកាលៈទេសៈប្រវត្តិសាស្ត្រជាក់ស្ដែង"។ បើបារាំងថា *"ឡេកុំប៉ាញ៉ុង ដឺរូតៈ"* បាទ។ កម្លាំងនេះ គឺអាស្រ័យលើការវិវត្តន៍នៃការតស៊ូ។ នៅក្នុងរយៈពេលការតស៊ូរំដោះជាតិ គឺកម្លាំងនេះនៅជាមួយនឹងកម្លាំងយុទ្ធសាស្ត្រ។ ប៉ុន្តែដល់ចូលក្នុងរយៈកាលបដិវត្តន៍សង្គមនិយម កម្លាំងនេះ គឺគេៗខ្ចាក់ចោលហើយបាទ។ គឺគេប្រមូលផ្ដុំទៅលើកម្លាំងយុទ្ធសាស្ត្រដែលមានវណ្ណៈកម្មករនិងកសិករ ជាកម្លាំងដឹកនាំ ហើយជាកម្លាំងស្នូលបាទ។

[១៥:១១:០៩]

**ស៖** បាទ សូមអរគុណ។ ដើម្បីឈានទៅកាន់កាប់អំណាចតាមបំណងរបស់ខ្លួន តើបក្សកុម្មុយនីស្តកម្ពុជា លោកបានធ្លាប់ដឹងឮ ថាតើបក្សកុម្មុយនីស្តកម្ពុជាធ្លាប់បានធ្វើផែនការយ៉ាងដូចម្ដេច

ដើម្បីបែងចែកឲ្យដាច់រវាងអ្នកគាំទ្រខាងសម្ដេច នរោត្ដម សីហនុ គេហៅថា "សីហនុនិយម" និងអ្នកប្រកាន់បក្សកុម្មុយនីស្ដកម្ពុជា? សូមលោកបញ្ជាក់ចំណុចនេះ បើសិនជាលោកចងចាំបាទ។

**ឆ៖** តាមខ្ញុំយល់ គឺកម្លាំងសម្ដេច សីហនុ ហ្នឹងគឺថាជាកម្លាំងយុទ្ធវិធី។ ប៉ុន្ដែក្នុងកម្លាំងយុទ្ធវិធីហ្នឹង គឺបក្សកុម្មុយនីស្ដកម្ពុជាក៏ជ្រើសរើសបុគ្គល ជាបុគ្គលមួយចំនួនដែលអាចនឹងរួមដំណើរជាមួយបក្ស រហូតដល់ទីចុងបញ្ចប់ដែរ។ ណោះ គឺថាក្នុងឋានៈជាក្រុម ជាពួក គឺជាកម្លាំងយុទ្ធវិធី កម្លាំងដែលបន្ទាប់បន្សំទេ ប៉ុន្ដែក្នុងឋានៈជាបុគ្គល ក៏មានបុគ្គលខ្លះអាចធ្វើដំណើរទៅវែងឆ្ងាយដែរបាទ តាមខ្ញុំយល់។

**ស៖** សូមអរគុណ បាទ។ សំណួរជាបន្ដនេះ ខ្ញុំសូមសួរលោកទាក់ទិនទៅនឹងការកាន់កាប់មុខតំណែងជាក់ស្ដែង ដែលកើតមាននៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ឬក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ តើអស់លោកមួយចំនួន ដែលខ្ញុំរៀបរាប់ឈ្មោះជាបន្ដទៅនេះ តើលោកចងចាំ អាចបញ្ជាក់ជូនអង្គសវនាការជ្រាបបានដែរទេ ថាគាត់កាន់មុខតំណែងអ្វីខ្លះបាទ? គឺទី១ គឺលោក សារិន ឆាក។

[១៥:១៣:១០]

**ឆ៖** លោក សារិន ឆាក គាត់ជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា ហើយក៏ជារដ្ឋមន្ដ្រីក្រសួងការបរទេសនៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

**ស៖** អរគុណ។ ទី២ លោក ហួត សម្បត្តិ?

**ឆ៖** លោក ហួត សម្បត្តិ ក៏ជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា ហើយជារដ្ឋមន្ដ្រីរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែរបាទ។

**ស៖** បាទ អរគុណ។ សូមលោកជួយបញ្ជាក់ឲ្យច្បាស់បន្ដិច ថាតើគាត់កាន់មុខតំណែងរដ្ឋមន្ដ្រីអ្វីបាទ? ដូចលោក សារិន ឆាក តើគាត់កាន់មុខតំណែងជារដ្ឋមន្ដ្រីអ្វី? ហើយ ហួត សម្បត្តិ តើគាត់កាន់មុខតំណែងរដ្ឋមន្ដ្រីទទួលបន្ទុកក្រសួងណាបាទ? សូមបញ្ជាក់ឈ្មោះក្រសួងឲ្យបានច្បាស់បាទ។

**ឆ៖** ខ្ញុំចាំច្បាស់ គឺលោក សារិន ឆាក គាត់កាន់តំណែងជារដ្ឋមន្ដ្រីក្រសួងការបទេស។ ឯលោក ហួត សម្បត្តិ ខ្ញុំចាំមិនច្បាស់ទេ គឺ--

[១៥:១៤:១៩]

**ស៖** អរគុណបាទ។ ទី៣ គឺលោក ចាន់ យូរ៉ាន់ បាទ?

**ឆ៖** លោក ចាន់ យូរ៉ាន់ ក៏ជាសមាជិកនៃការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា ហើយជារដ្ឋមន្ដ្រីក្រសួងអប់រំនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

**ស៖** អរគុណបាទ។ ទី៤ លោក ជា សាន?

**ឆ៖** លោក ជា សាន ក៏ជាសមាជិកនៃការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា ហើយជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាបាទ។

**ស៖** ទី៥ លោក គាត ឈន់?

**ឆ៖** លោក គាត ឈន់ ជាសមាជិកបម្រុងនៃរណសិរ្ស -- នៃការិយាល័យនយោបាយ នៃរណសិរ្សរួបរួមជាតិកម្ពុជា ហើយជារដ្ឋមន្ត្រីអមទីស្តីការនាយករដ្ឋន្ត្រី នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

**ស៖** បាទ អរគុណ។ ទី៦ លោក ជួន ប្រសិទ្ធិ?

**ឆ៖** លោក ជួន ប្រាសិទ្ធិ ជាសមាជិកបម្រុង នៃការិយាល័យនយោបាយ នៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីសម្របសម្រួលការងារតស៊ូ នៃរាជរដ្ឋាភិបាលកម្ពុជា។

**ស៖** ទី៧ លោក វ៉ាន់ ពីនី?

[១៥:១៦:០២]

**ឆ៖** លោក វ៉ាន់ ពីនី ជាអនុរដ្ឋមន្ត្រីនៃក្រសួងការបរទេស នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

**ស៖** អរគុណ។ ទី៨ លោក កែវ មាស?

**ឆ៖** លោកប្រធាន ខ្ញុំសូមឲ្យលោកព្រះរាជអាជ្ញាបញ្ជាក់ថា លោក កែវ មាស ឬលោក កែ មាស?

**ស៖** លោក កែវ មាសៗ។

**ឆ៖** លោក កែវ មាស គឺថាជាអតីតមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាបាទ។

**ស៖** ទី៩ លោក អ៊ីស៊ុប គន្ធីៗ?

**ឆ៖** លោក អ៊ីស៊ុប គន្ធី ជាភារធារីស្តីទីនៃស្ថានទូតកម្ពុជាប្រចាំប្រទេសអាល់បានី។

**ស៖** តើគាត់ជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** មិនៗទេបាទ។

**ស៖** អរគុណ។ ទី១០ លោក ចៅ សេង?

**ឆ៖** លោក ចៅ សេង ជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា ហើយជារដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

[១៥:១៧:៤៣]

**ស៖** ទី១១ លោកឧត្តមសេនីយ៍ ដួង សំអុល?

**ឆ៖** លោកឧត្តមសេនីយ៍ ដួង សំអុល ក៏ជាសមាជិកនៃការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីសព្វាវុធនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

**ស៖** ទី១២ លោក ជួន មុំ?

**ឆ៖** លោក ជួន មុំ ក៏ជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា ហើយជារដ្ឋមន្ត្រីហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

**ស៖** អរគុណ។ ឈ្មោះអ្នកចុងក្រោយគឺ ទី១៣ គឺលោក អ៊ិន សុខាន់ៗ បាទ។

**ឆ៖** លោកប្រធាន បែប អ៊ិន សុកាន ទេដឹងឈ្មោះ?

**ស៖** បាទ អ៊ិន សូកាន បាទ។

[១៥:១៨:៤៨]

**ឆ៖** បាទ លោក អ៊ិន សូកាន ជាតំណាង នៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រចាំប្រទេសបារាំង។

**ស៖** អរគុណលោក សួង ស៊ីគឿន។ ខ្ញុំសូមបញ្ជាក់ ខ្ញុំសំណួរសួរបន្តទៅទៀត។ ថាតើក្នុងចំណោមអស់លោកខាងលើជារដ្ឋមន្ត្រី និងជាអ្នកការទូតរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលខ្ញុំបានបញ្ជាក់ឈ្មោះ ជម្រាបជូនលោកអម្បាញ់មិញនេះ ថាតើក្នុងចំណោមអស់លោកទាំងអស់នោះ ធ្វើការស្ថិតនៅក្រោមការគ្រប់គ្រងរបស់សម័យកាលឆ្នាំ១៩៧៥ ដល់៧៩ ហ្នឹងមានបញ្ហានៃការចាប់ខ្លួនពួកគាត់ដែរឬទេ? បើមានតើបុគ្គលណាខ្លះត្រូវចាប់ខ្លួន? ហើយដោយមូលហេតុអី?

**ឆ៖** ចំពោះការចាប់ខ្លួនខ្ញុំមិនបានដឹងទេ បាទ។

**ស៖** អរគុណ។ តើក្នុងចំណោមអស់លោកជារដ្ឋមន្ត្រី និងអ្នកការទូត ដែលខ្ញុំរៀបរាប់អម្បាញ់មិញនេះ មានអស់លោកណាខ្លះ ដែលធ្វើការស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់លោក អៀង សារី បាទ?

[១៥:២០:២៨]

**ឆ៖** ក្នុងចំណោមឥស្សរជនទាំង១៣ ដែលលោកព្រះរាជអាជ្ញាបានរៀបរាប់នេះ គឺមានតែ

លោក គាត ឈន់ ហើយនិងលោក ជួន ប្រសិទ្ធិ ទេ ដែលធ្វើការនៅក្រសួងការបរទេស ក្រោមការដឹកនាំរបស់លោក អៀង សារី បាទ។

**ស៖** អរគុណលោក សួង ស៊ីគឿន។ ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត ទាក់ទងនឹងគណៈប្រតិភូរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅឯបរទេសបាទ។ សំណួរបន្តនេះ សូមសួរលោកថា តើលោក អៀង សារី និងលោក ខៀវ សំផន ធ្លាប់បានធ្វើទស្សនកិច្ចនៅទ្វីបអឺរ៉ុប តើនៅទ្វីបអឺរ៉ុបនោះនៅប្រទេសណាខ្លះបាទ? ហើយនៅពេលណាបាទ? នៅឆ្នាំណាបាទ?

**ឆ៖** នៅខែ នៅដើមខែមេសា ឆ្នាំ១៩៧៤ លោក ខៀវ សំផន និងលោក អៀង សារី បានដឹកនាំគណៈប្រតិភូរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិទៅទស្សកិច្ចប្រទេសយូហ្គោស្លាវី រ៉ូម៉ានី និងអាល់បានី បាទ។

[១៥:២១:៤៩]

**ស៖** អរគុណ។ ចុះទៅទ្វីបអាហ្វ្រិក តើមានដំណើរទស្សនកិច្ចរបស់លោកទាំងពីរនោះ ទៅទ្វីបអាហ្វ្រិកដែរឬទេ? ហើយទៅនៅពេលណា? ហើយទៅប្រទេសណាខ្លះបាទ?

**ឆ៖** តាមខ្ញុំចាំ ដូចទៅប្រទេសអាល់ហ្សេរី ម៉ូរីតានី ហើយនិងអេហ្ស៊ីប។ ប៉ុន្តែអាចមានប្រទេសមួយពីរទៀត ដែលខ្ញុំមិនបានចាំបាទ។

**ស៖** បាទ អរគុណ។ តើក្នុងដំណើរទស្សនកិច្ចទៅទ្វីបទាំងពីរនោះ លោកបានអម -- ធ្លាប់បានអមដំណើរជាមួយលោកទាំងពីរនាក់នោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានអមដំណើរក្នុងឋានៈជាជំនួយការនៃគណៈប្រតិភូ ដែលដឹកនាំដោយលោក ខៀវ សំផន និងលោក អៀង សារី បាទ។

[១៥:២២:៤៨]

**ស៖** តើដំណើរទស្សនកិច្ចនោះមានគោលបំណងអ្វីខ្លះបាទ?

**ឆ៖** ដំណើរទស្សនកិច្ចនេះ គឺដើម្បីនិយាយជូនព័ត៌មានទៅប្រទេសជាមិត្តទាំងនោះ ដែលគាំទ្រការតស៊ូរបស់ប្រជាជនកម្ពុជា អំពីជំហររបស់រាជរដ្ឋាភិបាលកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា ចំពោះកិច្ចសន្និសីទ សន្និសីទសន្តិភាពនៅទីក្រុងប៉ារីស ហើយប្រមូលការគាំទ្រនៃប្រទេសទាំងនោះចំពោះការតស៊ូរបស់ប្រជាជនកម្ពុជា។

**ស៖** បាទអរគុណ។ ខ្ញុំចង់ដឹងការងាររបស់លោកនៅក្នុងអតីតកាល ថាតើក្នុងបក្សកុម្មុយនីស្ត

កម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា ក្នុងស្ថាប័នទាំងពីរនេះ តើលោកបានធ្វើការក្នុងស្ថាប័នណាច្រើនជាងគេ? ដោយមូលហេតុអ្វីបាទ?

**ឆ៖** យើងមិនអាចបែងចែក គឺការងាររវាងអង្គការហ្នឹងទាំងពីរទេ ព្រោះក្នុងខណៈជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា គឺទិសដៅរបស់យើង គោលបំណងរបស់ម្នាក់ៗ គឺរបស់បក្ខជនម្នាក់ៗ គឺបំពេញការងារជាជនកុម្មុយនីស្តនៅក្នុងអង្គការនីមួយៗឲ្យបានតាមមាគ៌ារបស់បក្សបាទ។ ដូច្នោះយើងបែងចែកមុខការងារទាំងពីរនេះមិនបានទេបាទ។

**សៈ** អរគុណបាទ។ តើនៅពេលណាដែលលោកបានចាកចេញពីប្រទេសចិន នាពេលចុងក្រោយបំផុតមកប្រទេសកម្ពុជានោះ? តើនៅពេលណាដែលលោកបានចាកចេញពីប្រទេសចិន នាដំណាក់កាលចុងក្រោយបាទ?

[១៥:២៤:៥៨]

**ឆ៖** ខ្ញុំចាកចេញពីប្រទេសចិន នៅឆ្នាំ១៩៧៤បាទ។

**សៈ** តើលោកចាកចេញពីប្រទេសចិនក្នុងគោលបំណងទៅណាដែរ?

**ឆ៖** គឺពេលនោះ គឺក្នុងឋានៈជាសមាជិករបស់បក្ស ហើយជាកិត្តិយសរបស់អ្នកតស៊ូម្នាក់ៗ។ ជាពិសេសចំពោះបញ្ញាជនដែលបានត្រូវអប់រំ និងរស់នៅយូរឆ្នាំនៅក្រៅប្រទេស។ គោលបំណងខ្ពស់បំផុតរបស់យើង គឺចូលមកក្នុងប្រទេសរួមសុខរួមទុក្ខជាមួយនឹងប្រជាជន ដើម្បីឲ្យ ដើម្បីរួមចំណែកដល់ការតស៊ូរបស់ប្រជាជនតាមក្រោមការដឹកនាំរបស់បក្ស។

**សៈ** អរគុណបាទ។ លោកបានបញ្ជាក់អម្បាញ់មិញថា លោកបានចាកចេញពីប្រទេសចិននៅឆ្នាំ១៩៧៤ តើលោកអាចចងចាំបានទេ ថានៅថ្ងៃខែណាដែរ?

**ឆ៖** គឺនៅដើមខែឧសភា ក្រោយពីទស្សនកិច្ចរបស់គណៈប្រតិភូកម្ពុជាដឹកនាំដោយលោក ខៀវ សំផន និងលោក អៀង សារី ទៅប្រទេសអាហ្វ្រិក និងប្រទេសអឺរ៉ុបខាងលិច -- ខាងកើត គឺនៅដើមតាមខ្ញុំចាំ គឺថានៅដើមខែឧសភា ឆ្នាំ១៩៧៤។

**សៈ** អរគុណ។ តើលោកធ្លាប់បានធ្វើដំណើរទៅប្រទេសវៀតណាមដែរឬទេ? ឬក៏ធ្លាប់ទៅប្រទេសណាផ្សេងទៀតដែរឬទេ បន្ទាប់ពីវិលត្រឡប់ពីប្រទេសចិន?

[១៥:២៦:៥៨]

**ឆ៖** ខ្ញុំបានធ្វើដំណើរទៅប្រទេសវៀតណាម នៅឆ្នាំមួយពាន់ប្រាំបួន -- នៅខែឧសភា ឆ្នាំ១៩៧០

ជាមួយនឹង អមដំណើរសម្តេចព្រះនរោត្តម សីហនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជាទៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។ ហើយបន្ទាប់មក ខ្ញុំក៏ ក្នុងដំណើររបស់ខ្ញុំមកប្រទេសនៅខែឧសភា ឆ្នាំ ១៩៧៤ ខ្ញុំក៏បានស្នាក់នៅមួយរយៈនៅទីក្រុងហាណូយ។

**ស៖** បាទ អរគុណ។ នៅពេលដែលលោកទៅដល់ប្រទេសវៀតណាម តើលោកបានឃើញលោក អៀង សារី និង ខៀវ សំផន នៅទីនោះដែរឬទេ?

**ឆ៖** នៅឆ្នាំ១៩៧៤ដែលខ្ញុំមកប្រទេសវៀតណាម ខ្ញុំធ្វើដំណើរជាមួយលោកទាំងពីរនេះតែម្តង។

**ស៖** បាទ ការធ្វើដំណើររបស់លោកជាមួយលោក អៀង សារី និងខៀវ សំផន នោះគឺចាកចេញទៅប្រទេសវៀតណាមនៅកាលបរិច្ឆេទណាដែលច្បាស់លាស់? សូមលោកមានការបញ្ជាក់បន្តិច។

**ឆ៖** គឺនៅខែឧសភា ឆ្នាំ១៩៧៤ ក្រោយពីទស្សនកិច្ចនៅប្រទេសលាវ នៅតំបន់រំដោះ ប្រទេសលាវ ហើយនៅតំបន់រំដោះវៀតណាមខាងត្បូង។

**ស៖** អរគុណ។ តើដំណើរទស្សនកិច្ចនៅវៀតណាម មានប៉ុន្មានថ្ងៃ?

[១៥:២៨:៤៩]

**ឆ៖** ដំណើរទស្សនកិច្ចនៅវៀតណាម ខ្ញុំចាំមិនច្បាស់ទេ។ ប៉ុន មិន១ជាតិចថ្ងៃទេ។ ឧបមាថាមួយអាទិត្យ ព្រោះវាមានសារៈសំខាន់ក្នុងការតស៊ូរបស់យើង។

**ស៖** បាទ អរគុណ។ នៅប្រទេសវៀតណាម តើលោកបានឃើញលោក អៀង សារី និងលោក ខៀវ សំផន បានធ្វើអ្វីខ្លះនៅទីនោះ?

**ឆ៖** ខ្ញុំបានចូលរួមសកម្មភាពរបស់គាត់ដែរ ក្នុងការដូចថា ចរចាជាផ្លូវការជាមួយនឹងអ្នកដឹកនាំវៀតណាម ហើយក្នុងពិធីជប់លៀងអីអ៊ីចឹង ក្នុងការធ្វើមីទ្ទីងជាមួយនិស្សិត ជាមួយអ៊ីចឹង។ ប៉ុន្តែកិច្ចការសំខាន់ៗ ខ្ញុំមិនបានដឹងទេ។

**ស៖** បាទ អរគុណ។ តើលោកធ្លាប់ឮទេ ពាក្យថា "តំបន់រំដោះ" ពាក្យថា "តំបន់រំដោះរបស់កម្ពុជា" តើស្ថិតនៅទីតាំងណាដែរ?

**ឆ៖** តំបន់រំដោះពេលនោះ បើនៅឆ្នាំដែលខ្ញុំចូលមក គឺមែនទែន វាទូទាំងប្រទេស លើកលែងតែនៅជុំវិញរាជធានីភ្នំពេញ ហើយនិងទីក្រុងមួយចំនួនបាទ។

**ស៖** តើលោកធ្លាប់បានធ្វើដំណើរទៅតំបន់រំដោះនោះដែរឬទេ?

**ឆ៖** ខ្ញុំចូលមក ខ្ញុំនៅក្នុងតំបន់ហ្នឹង មុននឹង១ភ្នំពេញរំដោះនៅថ្ងៃទី១៧ មេសា ១៩៧៥។

**សៈ** អរគុណ។ តើលោកធ្លាប់បានឃើញដែរឬទេ ថាលោក អៀង សារី និងលោក ខៀវ សំផន ធ្លាប់បានធ្វើដំណើរឆ្ពោះទៅតំបន់រំដោះរបស់កម្ពុជាដែរឬទេ នាសម័យកាលនោះ?

[១៥:៣០:៥៨]

**ផៈ** គឺនៅខែឧសភា ឆ្នាំ១៩៧៤ ក្រោយពីទស្សនកិច្ចគណៈប្រតិភូដឹកនាំដោយលោក ខៀវ សំផន និង លោក អៀង សារី នៅតំបន់រំដោះលាវ និងតំបន់រំដោះវៀតណាខាងត្បូង គឺខ្ញុំ និងលោកស្រី អៀង ធីរិទ្ធ វិលត្រឡប់មកហាណូយវិញ ដើម្បីនឹងបន្តការងារនៅស្ថានីយ៍វិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា។ ចំណែក លោក អៀង សារី និងលោក ខៀវ សំផន លោកទាំងពីរក៏វិលត្រឡប់ទៅក្នុងប្រទេសវិញ ទៅក្នុងតំបន់រំដោះប្រទេសវិញ។

**សៈ** បាទ អ៊ីចឹងមានន័យថា លោក អៀង សារី និងលោក ខៀវ សំផន បានបន្តដំណើរទៅតំបន់រំដោះរបស់កម្ពុជាហ្នឹង ក្រោយពេលដែលលោកទាំងពីរវិលត្រឡប់មកពីប្រទេសវៀតណាម។ តើមែនឬទេ? លោកបញ្ជាក់អម្បាញ់មិញ មានន័យថាអ៊ីចឹង?

**ផៈ** បាទ គឺអ៊ីចឹងមែន។

**សៈ** អរគុណបាទ។ ខ្ញុំសួរបន្តទៀតថា តើប៉ុន្មានថ្ងៃក្រោយពីអ្នកទាំងពីរ គឺលោក អៀង សារី និងលោក ខៀវ សំផន បានចាកចេញពីទីក្រុងប៉េកាំងមកកម្ពុជា។ តើគាត់ចាកចេញពីទីក្រុងប៉េកាំងមកកម្ពុជានោះ គឺក្នុងបំណងអ្វីសំខាន់?

**ផៈ** ពេលនោះ គឺសង្គ្រាមកំពុងតែឆាបឆេះរវាងកម្លាំងតស៊ូដែលរួបរួមគ្នាក្នុងរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកម្លាំងនៃសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ លន់ នល់ គាំទ្រដោយសហអាមេរិក។ សង្គ្រាមកំពុងឆាបឆេះ ក្នុងឋានៈជាអ្នកដឹកនាំការតស៊ូ លោកទាំងពីរមានកាតព្វកិច្ចវិលត្រឡប់មកដឹកនាំការតស៊ូនៅក្នុងប្រទេសវិញ។

**សៈ** បាទ អរគុណ។ សូមលោកជួយបញ្ជាក់បន្ថែមទៀត ថាក្រោយពេលដែលលោក អៀង សារី និង ខៀវ សំផន សម្រេចចិត្តវិលមកប្រទេសវិញ គឺចូលទៅក្នុងតំបន់រំដោះរបស់កម្ពុជា។ តើការធ្វើដំណើររបស់គាត់តាមមធ្យោបាយណា? ហើយឆ្លងកាត់ទីតាំងណាខ្លះ ពីប្រទេសវៀតណាមចូលមកកម្ពុជានោះ?

[១៥:៣៣:៣៨]

**ផៈ** សូមទោស ខ្ញុំមិនអាចដឹងបានទេ បាទ។

**ស៖** អរគុណ។ តើលោកអាចបញ្ជាក់បានទេថា ហេតុ -- តើមានហេតុផលអ្វីបានជាលោក អៀង សារី និងលោក ខៀវ សំផន សុខចិត្តរង់ចាំអស់រយៈពេលដ៏យូរនៅឯតំបន់រំដោះ ហើយចង់ចូលមកប្រទេសកម្ពុជា ប៉ុន្តែគាត់មិនបានចូលដោយឆាប់ទេ។ តើមានហេតុផលអីបានជាគាត់រង់ចាំយូរម្ល៉ឹងៗ មុននឹងគាត់បានចូលមកប្រទេសនោះ?

**ឆ៖** លោកប្រធាន ខ្ញុំសូមលោកព្រះរាជអាជ្ញាបញ្ជាក់បន្តិច ខ្ញុំដូចមិនសូវយល់សំណួរនេះ។

**ស៖** អរគុណ។ ខ្ញុំសូមសួរសង្ខេបបន្តិចបាទ។ ខ្ញុំចង់ដឹងថា តើមូលហេតុអីបានជាលោក អៀង សារី លោក ខៀវ សំផន រង់ចាំ ប្រើពេលរង់ចាំដ៏យូរនៅឯតំបន់រំដោះនៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែគាត់ចង់ចូលមកក្នុងផ្ទៃក្នុងកម្ពុជាកាន់តែជ្រៅៗ ប៉ុន្តែគាត់មិនបានចូលដោយឆាប់ៗទេ។ តើមូលហេតុអី បានជាគាត់សុខចិត្តរង់ចាំប្រើពេលយ៉ាងយូរដូច្នេះ?

[១៥:៣៥:០០]

**ឆ៖** ខ្ញុំសូមអភ័យទោសលោកព្រះរាជអាជ្ញា លោកប្រធាន ប៉ុន្តែ -- គឺខ្ញុំក៏នៅតែមិនយល់ពីសំណួរលោកព្រះរាជអាជ្ញាដែរ។ ព្រោះថាកម្ពុជាពេលនោះបែងចែកជាពីរផ្នែក មួយផ្នែកជាតំបន់រំដោះ មួយផ្នែកជាតំបន់ដែលគ្រប់គ្រងដោយសាធារណរដ្ឋខ្មែរ។ ឥឡូវ សូមលោកព្រះរាជអាជ្ញា សូមលោកប្រធាន សូមឲ្យបញ្ជាក់សំណួរនេះឡើងវិញឲ្យច្បាស់ទៀតបាទ។

**លោក ច័ន្ទ តារាស្មី៖**

លោកប្រធាន ខ្ញុំសូមបន្តទៅសំណួរផ្សេងវិញបាទ ដោយសារតែសំណួរនេះខ្ញុំគិតថាមិនសូវជាមានសារៈសំខាន់ទេ អ៊ីចឹងខ្ញុំសូមបន្តទៅសំណួរផ្សេងមួយទៀតបាទ។ លោកប្រធាន ប្រធានបទជាបន្តនេះ គឺខ្ញុំសូមសួរទៅលោកសាក្សីទាក់ទិននឹងប្រធានបទ "វិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងហាណូយ"។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក សួង ស៊ីគឿន តើលោកអាចបញ្ជាក់បានទេថា មានហេតុផលអ្វីបានជាបង្កើតវិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងហាណូយនោះ?

[១៥:៣៦:១៨]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំមិនសូវដឹងហេតុផលអ្វីទេ ប៉ុន្តែថាដូចខ្ញុំបានជម្រាបពីលើកមុន គឺការតស៊ូរបស់យើង

ពេលនោះគឺប្រជាជនកម្ពុជា ប្រជាជនវៀតណាម ប្រជាជនឡាវប្រឈមមុខនឹងសត្រូវរួម។ លោកប្រធានខ្ញុំនិយាយនេះជាប្រវត្តិសាស្ត្រមិនមែនជាការ ជារឿងផ្សេងទេបាទ។ ប្រឈមមុខនឹងសត្រូវរួមរបបដែលនៅក្នុងប្រទេសទាំងបីហ្នឹងជារបប ពេលហ្នឹងគេហៅថាជារបប “អាយ៉ងៗចក្រពត្តិអាមេរិក” ដូច្នេះវាជាការចាំបាច់នៃការតស៊ូរួមរបស់យើង របស់ប្រជាជនយើងទាំងបី និងឧបត្ថម្ភគ្នាទៅវិញទៅមក។ ហើយរូបភាពមួយនៃការឧបត្ថម្ភរបស់បក្សកុម្មុយនីស្តវៀតណាម ចំពោះបក្សកុម្មុយនីស្តកម្ពុជា គឺអនុញ្ញាតឱ្យសំឡេងរណសិរ្សរួបរួមជាតិកម្ពុជាហ្នឹង គឺមានទីតាំងនៅលើទឹកដីនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមបាទ។

**ស៖** បាទ អរគុណ។ តើលោកអាចបញ្ជាក់បានទេថា ការបង្កើតវិទ្យុនៅទីក្រុងហាណូយនេះ តើឧបត្ថម្ភគាំទ្រដោយផ្នែកណា? ពីអ្នកណាដែរបាទ?

**ឆ៖** តាមខ្ញុំដឹងគឺប្រទេសវៀតណាមពេលនុ៎ងបានផ្តល់តែទឹកដី ហើយបុគ្គលិកជាដូចថាជាពេទ្យជាអ្នកបច្ចេកទេសមួយចំនួនតូចទេ។ ប៉ុន្តែកិច្ចការទាក់ទងនឹងការតស៊ូរបស់កម្ពុជា គឺវៀតណាមទុកឱ្យកម្ពុជាដំណើរការដោយអធិបតេយ្យភាពបាទ។

[១៥:៣៨:៣៧]

**ស៖** បាទ អរគុណ។ តើបុគ្គលិកខ្មែរ ដែលបម្រើការនៅក្នុង វិទ្យុនោះៗ តើជ្រើសរើសមកពីប្រភពណាខ្លះបាទ?

**ឆ៖** បុគ្គលិកខ្មែរបំពេញភារកិច្ចនៅវិទ្យុនោះ រណសិរ្សរួបរួមជាតិកម្ពុជានេះ គឺមានអ្នកតស៊ូចាស់។ ក្នុងចំណោមអ្នកតស៊ូចាស់ហ្នឹង គឺថាមានឯកឧត្តម ជា សុត គាត់ជាអ្នកដែលនិយាយសំខាន់ ដូចថាជាអ្នកតស៊ូជំនាន់បារាំង។ អាហ្នឹងមួយផ្នែក។ មួយផ្នែកជាអ្នកមកពីក្នុងប្រទេស ជាពិសេសក្រុមសិល្បៈ។ ហើយមួយផ្នែកទៀតជាបញ្ញាជនដោយរួមទាំងខ្ញុំបាទផងហ្នឹង គឺថាជាបញ្ញាជនស្នេហាជាតិដែលសុំចូលមកក្នុងប្រទេស ប៉ុន្តែក្នុងការចាំបាច់នៃក្នុងកិច្ច បម្រើការនៅក្នុងសំឡេង នៅក្នុងវិទ្យុនេះ ក៏បញ្ញាជនទាំងនោះមកស្នាក់នៅជួយការងារនៅវិទ្យុនោះ នៅកន្លែងវិទ្យុនោះបាទ។

**ស៖** បាទ អរគុណ។ តើបុគ្គលិកខ្មែរដែលធ្វើការនៅទីនោះ ត្រូវតែជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ឬជាសមាជិករបស់រណសិរ្សរួបរួមជាតិកម្ពុជា ទើបអាចធ្វើការនៅទីនោះបាន ឬក៏មិនមែនទេបាទ?

[១៥:៤០:២៣]

**ឆ៖** មួយចំនួនធំ តាមដែលខ្ញុំដឹង គឺជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា។ ក៏ប៉ុន្តែក៏មានមួយចំនួនតូចដែរ មិនមែនជាសមាជិកដែរ។ បើក្នុងវចនានុក្រម -- ក្នុងស្នូររបស់ចលនាកុម្មុយនីស្តកម្ពុជា គឺគេហៅថា អ្នកដែលមាន សមានចិត្ត សមានជន បាទ។

[១៥:៤០:៤៩]

**ស៖** អរគុណលោក។ តើវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាមានឈ្មោះ លេខកូដ គឺឈ្មោះអ្វីដែរ? តើលោកអាចចាំទេ? បញ្ជាក់បានទេបាទ?

**ឆ៖** មិនបានដឹងទេបាទ ខ្ញុំមិនបានដឹងទេ។ ខ្ញុំដឹងថាជាផ្លូវការ វិទ្យុហ្នឹងមានឈ្មោះថា "សំឡេងរណសិរ្សរួបរួមជាតិកម្ពុជា"។

**ស៖** បាទ អរគុណ។ តើកម្មវិធីផ្សព្វផ្សាយតាមវិទ្យុនោះ ត្រូវបានផលិតដោយមានការត្រួតពិនិត្យពីខាងណាខ្លះបាទ? អ្នកណាខ្លះជាអ្នកទទួលខុសត្រូវក្នុងការត្រួតពិនិត្យកម្មវិធីផ្សាយរបស់វិទ្យុរៀងរាល់ពេលនោះបាទ?

**ឆ៖** គឺថាវិចារណកថា ឬអត្ថបទសំខាន់ៗ គឺផ្ញើពីខាងក្នុងប្រទេស ហើយអត្ថបទមួយចំនួនដែលដូចជាពាក់ព័ន្ធនឹងកិច្ចការងារបរទេស គឺថាផលិតផ្ទាល់នៅនឹងកន្លែង។ ហើយអ្នកដែលត្រួតពិនិត្យនៅផ្នែកក្រៅប្រទេសហ្នឹង គឺថាលោកស្រី អៀង សារី ដែលគាត់ជាចាងហ្វាងវិទ្យុនេះបាទ។

[១៥:៤២:០៣]

**ស៖** បាទ អរគុណ។ អ៊ីចឹងតាមចម្លើយ -- តាមការបញ្ជាក់បំភ្លឺរបស់លោកអម្បាញ់មិញថា លោកស្រី អៀង ធីរិទ្ធ១ គឺជាចាងហ្វាងវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជានោះ។ អ៊ីចឹងមានន័យថាគាត់ គឺជាអ្នកទទួលខុសត្រូវខ្ពស់ជាងគេបំផុតចំពោះវិទ្យុនោះ មែនទេបាទ?

**ឆ៖** បើនិយាយពីតួនាទីនយោបាយរបស់វិទ្យុ ជាទូទៅគាត់មិនមែនជាអ្នកទទួលខុសត្រូវ តាមខ្ញុំដឹង។ គាត់ទទួលខុសត្រូវតែផ្នែកមួយ ដែលនៅធ្វើការងារផ្ទាល់ជាមួយគាត់ តែប៉ុណ្ណឹងទេបាទ។

**ស៖** បាទ សូមអរគុណ។ តើវិទ្យុនេះបង្កើតឡើងមកក្នុងគោលដៅសំខាន់ ការផ្សព្វផ្សាយគឺដើម្បីប្រជាជនខ្មែរ ឬក៏អ្នកចលនាតស៊ូខ្មែរនៅក្នុងប្រទេសមែនទេ? ឬក៏សម្រាប់អ្នកណាផ្សេងទៀតបាទ?

**ឆ៖** វិទ្យុនេះ គឺជាសំឡេងតំណាងឲ្យចលនាតស៊ូរបស់ប្រជាជនកម្ពុជានៅពេលនោះ ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស បាទ។

[១៥:៤៣:៣២]

**ស៖** អរគុណ។ តើវិទ្យុហ្នឹងមានផ្សព្វផ្សាយជាភាសាអ្វីខ្លះ?

**ឆ៖** មានផ្សព្វផ្សាយតែភាសាខ្មែរទេបាទ តាមខ្ញុំដឹង។

**ស៖** នៅក្នុងកម្មវិធីវិទ្យុដែលត្រូវផ្សព្វផ្សាយជាភាសាខ្មែរនោះ តើលោកទទួលខុសត្រូវផ្នែកណាបាទ?

**ឆ៖** ខ្ញុំទទួលខុសត្រូវខាងព័ត៌មានអន្តរជាតិបាទ។

**ស៖** បាទ មុននឹងចេញផ្សាយអត្ថបទសារព័ត៌មានអន្តរជាតិរបស់លោក តើមានអ្នកណានៅពីលើក្នុងការត្រួតពិនិត្យខ្លឹមសារនៃព័ត៌មានមុនធ្វើការផ្សព្វផ្សាយនោះបាទ?

**ឆ៖** គឺលោកស្រី អៀង ធីរិទ្ធ ដែលគាត់ពិនិត្យអត្ថបទដែលខ្ញុំបានសរសេរដើម្បីផ្សាយនោះបាទ។

**ស៖** អរគុណ។ តើលោក អៀង សារី និងលោក ខៀវ សំផន មានធ្លាប់ដែលណែនាំលោកទាក់ទិននឹងការផ្សាយព័ត៌មាននៅក្នុងវិទ្យុនោះដែរឬទេ? ឬក៏គាត់ធ្លាប់ណែនាំទៅបុគ្គលិកណាផ្សេងទៀតក្នុងការផ្សព្វផ្សាយព័ត៌មានតាមវិទ្យុនោះដែរឬទេ ក្នុងសម័យកាលនោះ?

[១៥:៤៥:០០]

**ឆ៖** តាមមើលទៅដូចមិនមានទេ ព្រោះមិនមែនជាក្នុងក្របខ័ណ្ឌភារកិច្ចរបស់លោកទាំងពីរទេ។

**ស៖** តើវិទ្យុនេះផ្សាយរហូតដល់ពេលណា ទើបបញ្ចប់កម្មវិធីផ្សាយវិទ្យុនោះនៅប្រទេសវៀតណាម?

**ឆ៖** ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា វិទ្យុនេះផ្សាយរហូតដល់ថ្ងៃទី១៧ មេសា ១៩៧៥ ពេលនុ៎ងខ្ញុំត្រឡប់មកក្នុងប្រទេសវិញហើយបាទ ប៉ុន្តែវិទ្យុហ្នឹងនៅផ្សាយ។ ផ្សាយពីជ័យជម្នះថ្ងៃ១៧ មេសា ១៩៧៥។

[១៥:៤៥:៥៣]

**ស៖** បាទ អរគុណ។ តើលោកអាចចាំបានទេ ថាវិទ្យុនេះបានជ្រើសរើសហ្វ្រេកង់ផ្សាយជាសាធារណៈហ្នឹងគឺហ្វ្រេកង់ប្រភេទណា ហើយសម្រេចដោយអ្នកណាដែរ?

**ឆ៖** ចំពោះហ្វ្រេកង់ ខ្ញុំមិនបានចាំទេបាទ។ ចំពោះអ្នកណាសម្រេចអី គឺខ្ញុំមិនបានដឹងទេ។

**ស៖** តើព័ត៌មានជាទូទៅ និងជាសំខាន់ភាគច្រើន តើការផ្សាយនោះផ្ដោតទៅលើខ្លឹមសារអ្វីខ្លះ?

**ឆ៖** សំខាន់គឺថា មានបទវិចារណកថា ជាអត្ថបទស្នូល ហើយនិងដំណឹងពីសមរភូមិ។

**ស៖** អរគុណ។ តើព័ត៌មានដែលលោក ឬក៏ក្រុមការងារលោកនៅក្នុងវិទ្យុនោះ ផ្សព្វផ្សាយភាគច្រើនបានព័ត៌មានមកពីប្រភពណា? ហើយបានមកយ៉ាងដូចម្ដេច?

[១៥:៤៧:១០]

**ឆ៖** បទវិចារណកថា ហើយនិងដំណឹងសមរភូមិ គឺធ្វើពីក្នុងប្រទេស តាមមធ្យោបាយកូដ*ម័ស៍* បាទ។

**ស៖** បាទ អរគុណ។ តើអ្នកណាខ្លះជាអ្នកបកប្រែអត្ថបទភាសា -- ព័ត៌មានភាសាបរទេសមុននឹងធ្វើការផ្សព្វផ្សាយជាភាសាខ្មែរ តើលោក ហើយនិងអ្នកណាផ្សេងទៀត ដែលរួមការងារជាមួយលោក?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ! សំណួរហ្នឹងឆ្ងាយពីភាពពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលចោទប្រកាន់ឆ្ងាយណាស់។ កាន់តែឆ្ងាយទៅ អត់ធ្លុត់មិនបានទេ។

**លោក ច័ន្ទ តាារស្មី៖**

អរគុណលោកប្រធាន។ ខ្ញុំសូមបន្តទៅសួរបន្តទៀត។

**សួរដោយលោក ច័ន្ទ តាារស្មី៖**

**ស៖** ទាក់ទងនឹងការ--

**ប្រធានអង្គជំនុំ៖**

ខិតខំព្យាយាមធ្វើម៉េចឲ្យចូលនៅក្នុង ពាក់ព័ន្ធនឹងអង្គហេតុដែលសំខាន់ មិនមែនពេលវេលាហើយចេញឆ្ងាយមួយរសៀលនេះហើយ។

**លោក ច័ន្ទ តាារស្មី៖**

បាទ អរគុណ។ ខ្ញុំសូមបន្តទៅប្រធានបទចុងមួយទៀត គឺប្រធានបទទាក់ទងនឹងការវិលត្រឡប់មកកម្ពុជា បន្ទាប់ពីស្នាក់នៅទីក្រុងហាណូយ និងការធ្វើការនៅប-២០។

[១៥:៤៨:២២]

**សួរដោយលោក ច័ន្ទ តាារស្មី៖**

**ស៖** លោកសាក្សីតើលោកអាចបញ្ជាក់បានទេ ប-២០ គឺជាអ្វី?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ក្នុងរយៈពេលដែលខ្ញុំស្នាក់នៅប-២០ហ្នឹង គឺជាមន្ទីរដែលកម្មាភិបាល ដែលមកពីក្រៅប្រទេសហ្នឹងស្នាក់នៅមួយរយៈ ហើយបន្តទៅកន្លែងផ្សេងទៀត។ តាមដែលខ្ញុំដឹងតែប៉ុណ្ណឹងទេ។ ខ្ញុំមិនបានដឹងអីជ្រៅជ្រះពីហ្នឹងទេ។

**ស៖** តើប-២០ នោះស្ថិតនៅទីតាំងកន្លែងណាដែរបាទ? ហើយមានមុខងារធ្វើអ្វី?

**ឆ៖** ប-២០ ហ្នឹងនៅស្រុកស្ទឹងត្រង់ ហើយកន្លែងហ្នឹងជាកន្លែងបង្កបង្កើនផល មានដើមឈើច្រើន មានចេក មានធរ៉េន មានចំប៉ាដក់ មានស្វាយ មានអីបាទ។ ដីហ្នឹងមានជីជាតិ។ ដូច្នោះផលដំណាំក៏ល្អគួរលាស់ល្អ ផ្លែឈើក៏បានច្រើនដែរ។

[១៥:៤៩:៥២]

**ស៖** តើប-២០ នោះ អ្នកណាគេជាប្រធាន?

**ឆ៖** ខ្ញុំមិនបានចាំទេបាទ។ ក្នុងពេលដែលខ្ញុំទៅហ្នឹង ខ្ញុំឃើញប្រធានហ្នឹង ខ្ញុំភ្លេចឈ្មោះ ខ្ញុំន៉ែនេះបាទ ខ្ញុំភ្លេចឈ្មោះ គឺថាអាចបន្តិចទៀត ឬស្អីមិនដឹង ខ្ញុំចាំឈ្មោះ ប៉ុន្តែខ្ញុំភ្លេចឈ្មោះ។

**ស៖** អរគុណ។ នៅពេលដែលលោកចូលទៅស្នាក់នៅៗប-២០ នោះ តើលោកឃើញអ្នកណាខ្លះធ្វើការនៅទីនោះបាទ?

[១៥:៥០:៣៩]

**ឆ៖** ពេលដែលខ្ញុំស្នាក់នៅពេលនោះ ខ្ញុំមិនបានឃើញអ្នកណាទេបាទ ដែលខ្ញុំស្គាល់ទេ ឃើញ-- ហើយមនុស្សក៏មិនសូវច្រើនដែរបាទ។

**ស៖** បាទ នៅពេលដែលលោកមកដល់ប្រទេសកម្ពុជា តើអ្នកណាជាអ្នកបញ្ជូនលោកទៅធ្វើការទៅស្នាក់នៅប-២០ នោះ?

**ឆ៖** តាមខ្ញុំយល់គឺ បញ្ហាវាគឺថា ជាខ្សែរយៈធម្មតា អ្នកដែលត្រូវចូលក្នុងប្រទេស ត្រូវស្នាក់នៅទីនោះ។ ដូច្នោះ បញ្ហាហ្នឹងគឺថា មកពីខាងលើជាការដឹកនាំរួម នៃចលនាតស៊ូនៅពេលនោះតែម្តងបាទ។

**ស៖** បាទ អរគុណ។ តើប-២០ នេះ គេបង្កើតឡើងក្នុងបំណងពិតប្រាកដ ដើម្បីអ្វីបាទ?

**ឆ៖** ខ្ញុំមិនបានដឹងទេ តាមមើលទៅមិនមានទិសដៅអី ជាជម្រៅទេ ព្រោះតាមខ្ញុំស្នាក់នៅទីនោះគឺមិនមានការអប់រំ រៀនសូត្រនយោបាយអីទេ គ្រាន់តែការប្រជុំ ហើយការប្រជុំនេះ ជាការប្រជុំការងារប្រចាំអាទិត្យ មិនមានការធ្វើការស្វ័យទិតៀន ឬទិតៀន ដូចថា ជ្រៅជ្រះអីទេបាទ។

**សៈ** បាទ អរគុណ។ តើលោកធ្លាប់ឃើញទេថា និស្សិតខ្មែរ បញ្ញវន្តខ្មែរដែលវិលត្រឡប់មកពីបរទេសត្រូវបានគេបញ្ជូនទៅទីណា?

**ឆៈ** ខ្ញុំមិនបានដឹងទេបាទ។

**សៈ** បាទអរគុណ។ តើមានធ្លាប់គេបញ្ជូនទៅប-២០ ដែរឬទេ ចំពោះបញ្ញវន្ត ដែលវិលត្រឡប់មកពីបរទេសនោះបាទ?

**ឆៈ** ពេលដែលខ្ញុំឆ្លងកាត់ហ្នឹង ក្រៅពីក្រុមពួកខ្ញុំហ្នឹង ដូចខ្ញុំមិនបានឃើញមាននិស្សិត ឬបញ្ញវន្តពីបរទេស ដែលបញ្ជូននៅទីនោះទេបាទ។

**សៈ** បាទអរគុណ។ បន្ទាប់ពីលោកធ្វើការនៅប-២០ តើគេបញ្ជូនលោកធ្វើការនៅទីណាទៀតបាទ?

[១៥:៥៣:០៩]

**ឆៈ** ក្រោយពីប-២០ ខ្ញុំបានមកស្នាក់នៅផ្ទះ គេហៅថា ផ្ទះពណ៌កូលាប នៃ *មេសុងរ៉ូស* គឺថាផ្ទះនេះនៅមុខវាំង នៅមាត់ទន្លេ ហើយជារបស់ព្រះក្សត្រី នលក្ខណ៍។ ព្រះមហាក្សត្រី នលក្ខណ៍ ហ្នឹងជាព្រះរាជអគ្គមហេសី របស់ព្រះបាទសម្តេច នរោត្តម សីហនុ បាទ។

**សៈ** អរគុណ លោក ស៊ីគឿន។

**លោក ច័ន្ទ តារាស្មី៖**

លោកប្រធាន ខ្ញុំមានសំណួរប្រាំទៀត មុននឹងបញ្ចប់ការសួររបស់ខ្ញុំនៅល្ងាចនេះ ហើយខ្ញុំសូមអនុញ្ញាតសួរសំណួរប្រាំទៀត ដើម្បីបញ្ចប់ ហើយថ្ងៃស្អែកសូមបន្តទៅលោក វាំងសង់ ដែលជាសហការីរបស់ខ្ញុំបាទ។ បើសិនលោកប្រធានអនុញ្ញាត សូមអរគុណបាទ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**សៈ** លោក ស៊ីគឿន ខ្ញុំសូមសួរលោកទាក់ទងទៅនឹងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ តើលោកឃើញមានការជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយយ៉ាងដូចម្តេច ពីទីក្រុងភ្នំពេញបាទ? តើលោកធ្លាប់បានឃើញដែរឬទេ?

**លោក សួង ស៊ីគឿន៖**

**ឆៈ** ពេលដែលខ្ញុំឡើងមកភ្នំពេញហ្នឹង គឺចរន្តនៃការជម្លៀសហ្នឹង គឺដូចចង់ផុតហើយបាទ ព្រោះខ្ញុំមកភ្នំពេញហ្នឹង ដល់ថ្ងៃ២០ ខែឧសភា ឆ្នាំ១៩៧៥ ហើយបាទ។

**សៈ** អរគុណ។ សំណួរទី២ ថាតើមានហេតុផលអ្វីបានជាមានការជម្លៀសប្រជាជន? ហើយនយោបាយនៃការជម្លៀសប្រជាជននេះ សម្រេចដោយអ្នកណា? ដោយស្ថាប័នណា? ថ្នាក់ណាបាទ?

[១៥:៥៤:៥៧]

**ឆៈ** ទិសដៅនៃការជម្លៀសហ្នឹង ខ្ញុំគេប្រាប់ខ្ញុំគឺថា ទីមួយ អាមេរិកាំងមានផែនការទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ។ ទីពីរ បើប្រជាជនទាំងអស់នៅភ្នំពេញ មុខតែអត់បាយហើយ ព្រោះមិនមានអង្ករ មានស្បៀងផ្គត់ផ្គង់ទីក្រុងដែលមានប្រជាជនច្រើនរាប់លានយ៉ាងនេះទេ។ ហើយទីបី គឺការជម្លៀសចេញពីភ្នំពេញនេះ គឺដើម្បីនឹងបំបែកបណ្ដាញចារកម្មរបស់ខ្មាំង។

**សៈ** បាទ សូមអរគុណ។ សំណួរទី៣ សូមសួរថា តើលោកបានដឹងទេថា នៅពេលដែលជម្លៀសពីទីក្រុងភ្នំពេញ ទៅតំបន់ជនបទ តើប្រជាជននៅតំបន់ជនបទបានស្វាគមន៍ចំពោះប្រជាជនថ្មីដែលជម្លៀសចេញពីទីក្រុងភ្នំពេញដែរឬទេ?

**ឆៈ** ខ្ញុំមិនអាចដឹងទេ ពីព្រោះខ្ញុំនៅក្នុងទីក្រុងបាទ។

**សៈ** សូមអរគុណសំណួរទី៤ ខ្ញុំសូមសួរទាក់ទិនទៅនឹង ប៉ុល ពត។ បាទ លោក ប៉ុល ពត និងលោក អៀង សារី និងលោក ខៀវ សំផន។ ជាសំណួរចុង -- បន្ទាប់ពីចុងក្រោយរបស់ខ្ញុំ គឺថាតើលោកធ្លាប់បានដឹងឮថា លោក ប៉ុល ពត ធ្លាប់បានណែនាំអ្វីខ្លះដល់លោក អៀង សារី ក្នុងនាមគាត់ធ្វើជារដ្ឋមន្ត្រីក្រសួងការបរទេស អំពីគោលនយោបាយ មាគ៌ានយោបាយទាក់ទិននឹងការបរទេសរបស់របបកម្ពុជាប្រជាធិបតេយ្យ ឬរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រជាធិបតេយ្យ។

**ឆៈ** ខ្ញុំមិនបានដឹងទេ បាទ ព្រោះរឿងនេះវារវាងគឺថាលោកទាំងពីរ។

**សៈ** អរគុណ សំណួរចុងក្រោយ គឺសំណួរទី៥។ ខ្ញុំសួរថាតើលោកក្រៅពីលោក ប៉ុល ពត តើមានការប្រជុំជាមួយនឹងកម្មាភិបាលថ្នាក់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យហ្នឹងយ៉ាងដូចម្ដេចទាក់ទិនទៅនឹងនយោបាយការបរទេស ដែលលោក អៀង សារី ធ្វើជារដ្ឋមន្ត្រី។ ឧទាហរណ៍ដូចជាលោក ខៀវ សំផន, លោក នួន ជា និងអ្នកផ្សេងទៀត តើមានការប្រជុំទាក់ទងនឹងការកំណត់មាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាយ៉ាងដូចម្ដេចទាក់ទិននឹងការបរទេសនេះ? សូមអរគុណ។

[១៥:៥៧:៤៦]

**ឆៈ** ខ្ញុំមិនបានដឹងទេ បាទ ព្រោះពេលនោះខ្ញុំធ្វើការនៅក្រសួងការបរទេស ហើយលោកទាំងបីលោកមានភារកិច្ច ហើយនិងស្នាក់នៅកន្លែងផ្សេង ហើយការងាររបស់លោក ខ្ញុំមិនបាន -- ខ្ញុំមិនមាន

សិទ្ធិអីដឹងទេ។

**លោក ច័ន្ទ តាវារស្មី៖**

បាទ សូមអរគុណលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំសួរសំណួរនៅថ្ងៃនេះ។ សូមអរគុណលោក សួង ស៊ីគឿន ដែលបានចំណាយដែលដ៏មានតម្លៃក្នុងការឆ្លើយសំណួររបស់ខ្ញុំនៅពេលនេះ។ សូមអរគុណបាទ។ សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ចប់ការសួររបស់ខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណសាក្សី។ ឥឡូវនេះ លោកសាក្សី លោក សួង ស៊ីគឿន ការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ ហើយសវនាការត្រូវបន្តធ្វើនៅថ្ងៃចន្ទ ទី០៦ ខែសីហា ឆ្នាំ២០១២ ដើមសប្ដាហ៍ក្រោយទៀត។ ដូច្នេះ អង្គជំនុំជម្រះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃចន្ទសប្ដាហ៍ក្រោយទៀត។ ហើយមេធាវីប្រឹក្សាសាក្សីដូចគ្នានឹងសាក្សីដែរ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅព្រឹកថ្ងៃចន្ទ សប្ដាហ៍ក្រោយនៅវេលាម៉ោងប្រាំបួន។

កិច្ចដំណើរការសម្រាប់ថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ។ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០៦ ខែសីហា ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

សវនាការនៅថ្ងៃចន្ទ សប្ដាហ៍ក្រោយនេះនឹងបន្តផ្ដល់ស្ដាប់សក្ខីកម្មសាក្សី សួង ស៊ីគឿន ដែលនឹងសួរដេញដោលដោលសហព្រះរាជអាជ្ញា។ ហើយសូមភាគី និងសាធារណជនជ្រាប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះវិញនៅថ្ងៃចន្ទ សប្ដាហ៍ក្រោយឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥៩នាទី)*